ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យន្តការគាំទ្រ សាលាមធ្យមសិក្សាឱ្យក្លាយជា សាលារៀនគំរូ




ក្រសួងអប់រំ យុវជន និងកីឡា
២០២៤

# យន្តការគាំទ្រ
# សាលាមធ្យមសិក្សាឱ្យក្លាយជា
# សាលារៀនគំរូ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# បុព្វកថា

រាជរដ្ឋាភិបាល កំណត់ចក្ខុវិស័យប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ឆ្ពោះទៅសម្រេចឱ្យបានជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកំណត់យកអាទិភាពគន្លឹះចំនួន៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។ ការអភិវឌ្ឍមូលធនមនុស្សជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងភាពធន់។

ដើម្បីរួមចំណែកក្នុងការសម្រេចចក្ខុវិស័យប្រកបដោយមហិច្ឆិតានេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការក្នុងការលើកកម្ពស់គុណភាពអប់រំ តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ ដែលជាផ្នែកមួយនៃកំណែទម្រង់វិស័យអប់រំ និងធានានូវការអប់រំប្រកបដោយគុណភាព សមត្ថភាព សីលធម៌ ប្រកួតប្រជែង និងឧត្តមភាពប្រៀបធៀបជាមួយបណ្តាប្រទេសក្នុងតំបន់និងពិភពលោក។

សៀវភៅណែនាំប្រតិបត្តិ «**យន្តការគាំទ្រសាលាមធ្យមសិក្សាឱ្យក្លាយជាសាលារៀនគំរូ**» ត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវក្របខណ្ឌគំនិតក្នុងការអនុវត្តដល់សាលារៀនសាធារណៈឱ្យក្លាយជាសាលារៀនគំរូ ដោយបង្ហាញនូវគោលការណ៍ណែនាំ វិធីសាស្ត្រ កិច្ចគាំទ្រកម្មវិធីអភិវឌ្ឍន៍សាលាមធ្យមសិក្សា ការចូលរួមណែនាំប្រតិបត្តិ ការលើកកម្ពស់ស្តង់ដានៃលទ្ធផលសិក្សារបស់សិស្ស ដំណើរការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន និងគណនេយ្យភាពរបស់សាលារៀន។

សៀវភៅណែនាំប្រតិបត្តិនេះនឹងជួយត្រួសត្រាយផ្លូវសាលារៀនសាធារណៈក្នុងការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍសាលារៀនតាមលំនាំឯកភាពគ្នាមួយ ប្រកបដោយភាពជាក់លាក់និងអាចបត់បែនបាន។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានរៀបចំសៀវភៅណែនាំប្រតិបត្តិនេះឡើង ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ក្រសួងអប់រំ យុវជន និងកីឡា មានជំនឿយ៉ាងមុតមាំថា គ្រប់តួអង្គពាក់ព័ន្ធនឹងចូលរួមគាំទ្រនិងអនុវត្តស្តង់ដាសាលារៀនគំរូឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃចន្ទ ៣ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា

**១. សេចក្តីផ្តើម** ១

**២. ស្តង់ដាសាលាមធ្យមសិក្សាគំរូ** ២

ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស ..... ៥

ស្តង់ដាទី២៖ ដំណើរការបង្រៀន និងរៀន ..... ៥

ស្តង់ដាទី ៣៖ ការចូលរួមរបស់សហគមន៍ ..... ៨

ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន ..... ១០

ស្តង់ដាទី ៥៖ គណនេយ្យភាព ..... ១១

**៣. ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៅតាមសាលារៀន** ១២

៣.១ សេចក្តីផ្តើម ..... ១២

៣.២ ប្រព័ន្ធអេកូគរុកោសល្យ ..... ១៣

៣.៣ អភិបាលកិច្ចសាលារៀន ..... ១៦

៣.៤ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ..... ១៧

៣.៥ បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន ..... ១៨

៣.៦ ការចូលរួមសហគមន៍ ..... ២០

**៤. គណៈកម្មការដឹកនាំ និងគណៈកម្មការបច្ចេកទេសការអនុវត្តស្តង់ដា** ២១

៤.១ គណៈកម្មការដឹកនាំ ..... ២២

៤.២ គណៈកម្មការបច្ចេកទេស ..... ២២

៤.៣ លេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំ ..... ២៤

**៥. ក្រុមគ្រូបង្គោល** ២៤

៥.១ សមាសភាពក្រុមគ្រូបង្គោល ..... ២៤

៥.២ ភារកិច្ចរបស់ក្រុមគ្រូបង្គោល ..... ២៥

៥.៣ សមាសភាពក្រុមគ្រូបង្គោលនៅថ្នាក់សាលារៀន ..... ២៥

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**៦. យន្តការចុះជួយគាំទ្រដល់សាលាគោលដៅ** ២៦

៦.១ ការចុះជួយគាំទ្រសាលារៀនផ្ទាល់ ........ ២៦

៦.២ ការជួយគាំទ្រសាលារៀនគោលដៅតាមរយៈការជួបប្រជុំតាមប្រព័ន្ធអនឡាញ ........ ២៨

**៧. គោលការណ៍ណែនាំប្រតិបត្តិក្នុងការគាំទ្រសាលារៀន** ២៩

៧.១ ហេតុវិនិច្ឆ័យសាលារៀន ឬការធ្វើស្វ័យវាយតម្លៃ ........ ២៩

៧.១.១ ការវាយតម្លៃដើមគ្រាដោយផ្អែកលើសូចនាករ ៨៣ ២៩

៧.១.២ ការវិភាគបញ្ហាតាម SWOT ការស្រាវជ្រាវប្រតិបត្តិ ការធ្វើហេតុវិនិច្ឆ័យ និងធ្វើការឆ្លុះបញ្ចាំង ៣០

៧.១.៣ ការរៀបចំព្រឹត្តិបត្រព័ត៌មានសាលារៀន ( School's Profile ) ៣៣

៧.២ ការធ្វើតេស្តស្តង់ដា ........ ៣៤

៧.២.១ តេស្តប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៣៤

៧.២.២ មុនពេលធ្វើតេស្ត ៣៤

៧.២.៣ អំឡុងពេលធ្វើតេស្ត ៣៦

៧.២.៤ ក្រោយពេលធ្វើតេស្ត ៣៧

៧.២.៥ ការវិភាគលទ្ធផលដែលទទួលបានពីការធ្វើតេស្ត ៣៧

៧.២.៦ ការប្រើប្រាស់លទ្ធផលតេស្ត ៣៨

៧.២.៧ តេស្តដើមឆ្នាំ ៣៨

៧.២.៨ អំណានស្ទាត់ ៣៩

៧.៣ ការរៀបចំផែនការសាលារៀន ........ ៤១

៧.៣.១ យន្តការនៃការរៀបចំផែនការសាលារៀន ៤២

៧.៣.២ ទម្រង់ផែនការសាលារៀន ៤២

៧.៤ ការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន ........ ៥០

៧.៤.១ ការរៀបចំផែនការថវិកាសាលារៀន ៥០

៧.៥ ផែនការរៀនសូត្រសិស្ស និងផែនការបង្រៀនរបស់គ្រូ ........ ៥៣

៧.៦ ក្របខណ្ឌការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នេម ........ ៥៨

៧.៧ វិធីសាស្ត្របង្រៀនតាមបែបបញ្ញត្តិ ........................................ ៥៩
៧.៨ ការសិក្សាបែបគម្រោង ផែនការបង្រៀនសម្រាប់អ្នកសម្របសម្រួល ........................................ ៧០
៧.៩ ការលើកកម្ពស់ស្តង់ដាសាលារៀនគំរូដោយវិធីបង្រៀនតាមបែបថ្នាក់រៀនត្រឡប់ និងវិធីសាស្ត្របង្រៀនតាមទ្រឹស្តីអប់រំស្ថាបនានិយម........................................ ៧១
៧.១០ ការណែនាំសិស្សឱ្យចេះបង្កើតកាលវិភាគរៀន ជាលក្ខណៈបុគ្គល ........................................ ៧៩
៧.១១ សកម្មភាពបន្ថែមក្រៅម៉ោងសិក្សា........................................ ៨១
៧.១២ ផែនការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន កិច្ចព្រមព្រៀងការងារ និងគន្លងអាជីពគ្រូបង្រៀន.......... ៨៦
៧.១៣ ការអប់រំសីលធម៌ ........................................ ៩២
៧.១៤ ការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ ........................................ ១០១
៧.១៥ ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភរបស់សិស្ស ........................................ ១០៨
៧.១៦ ការគ្រប់គ្រងទិន្នន័យអប់រំសាលារៀន........................................ ១១០

**៨. របៀបនៃការអនុវត្តស្តង់ដាសាលាគំរូមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ សម្រាប់ឆ្នាំ២០២៣-២០២៤ និងឆ្នាំបន្តបន្ទាប់** ១១៣
៨.១ ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស........................................ ១១៣
៨.២ ស្តង់ដាទី២៖ ដំណើរការបង្រៀន និងរៀន ........................................ ១២៩
៨.៣ ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍........................................ ១៥៩
៨.៤ ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន ........................................ ១៦៦
៨.៥ ស្តង់ដាទី៥៖ គណនេយ្យភាព........................................ ១៩២

**៩. ការវិភាគការងារសាលាមធ្យមសិក្សាចំណេះទូទៅ** ១៩៧

**ឯកសារយោង** ២០១

**ឧបសម្ព័ន្ធ** ២០៤

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១. សេចក្ដីផ្ដើម

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់វិស័យអប់រំជាបន្តបន្ទាប់ក្នុងគោលដៅជំរុញការអភិវឌ្ឍ និងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំ តាមរយៈការអនុវត្តគោលនយោបាយអប់រំនៅកម្រិតសាលារៀន។ ក្នុងន័យនេះ សាលារៀនគឺជាគោលដៅនៃការផ្លាស់ប្ដូរ។ ទន្ទឹមនឹងនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានដាក់អាទិភាពខ្ពស់លើការអភិវឌ្ឍវិស័យអប់រំដើម្បីធានាប្រសិទ្ធភាពនៃការអប់រំ និងការផលិតនូវមូលធនមនុស្សប្រកបដោយសក្ដានុពល និងភាពប្រកួតប្រជែង។

យោងតាមស្មារតីប្រជុំដំបូងរបស់គណៈរដ្ឋមន្ត្រីនីតិកាលទី៧ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ចេញវិធានការគន្លឹះចំនួន៤ ដើម្បីពង្រឹងគុណភាពគ្រឹះស្ថានសិក្សារដ្ឋ ចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សា រួមមាន៖ (១) ការពង្រឹងអភិបាលកិច្ចសាលារៀន (២) ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ដើម្បីពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស (៣) ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន និង (៤) ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីលើកកម្ពស់ការអប់រំតាមរយៈការជំរុញនិងលើកទឹកចិត្តការចូលរួមរបស់មាតាបិតាអ្នកអាណាព្យាបាលនិងសហគមន៍ក្នុងការអប់រំស្របតាមពាក្យស្លោក«ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ»។

ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់ចេញនូវវិធានគន្លឹះចំនួន៤ ដែលត្រូវបញ្ជ្រាបក្នុងការអនុវត្ត «ស្ដង់ដាសាលារៀនគំរូ» និង «ពានរង្វាន់សាលារៀនគំរូ» ដោយផ្ដោតលើលទ្ធផលការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និងគណនេយ្យភាពរបស់សាលារៀន។

គោលបំណងនៃការរៀបចំយន្តការគាំទ្រសាលាមធ្យមសិក្សាឱ្យក្លាយជាសាលារៀនគំរូគឺ៖

១.បង្ហាញពីធាតុសំខាន់ៗនៃស្ដង់ដាសាលារៀនគំរូដោយរួមបញ្ចូលកម្រិតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលកម្រិតពិន្ទុវាយតម្លៃស្ដង់ដា និងយុទ្ធសាស្ត្រគោលនៃការអនុវត្ត

២.រៀបចំគណៈកម្មការដឹកនាំ និងគណៈកម្មការបច្ចេកទេសការអនុវត្តស្ដង់ដាគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ ប្រចាំតំបន់ និងប្រចាំខេត្ត ក្នុងការគាំទ្រនិងវាយតម្លៃលើការអនុវត្តស្ដង់ដាសាលារៀនគំរូ

៣.រៀបចំគ្រូបង្គោលដើម្បីផ្ដល់ការប្រឹក្សាយោបល់គាំទ្រនិងពង្រឹងការអនុវត្តស្ដង់ដាសាលារៀនគំរូ

៤.បង្ហាញពីគោលការណ៍ណែនាំប្រតិបត្តិលម្អិតក្នុងការគាំទ្រសាលារៀន ផ្អែកលើការរៀបចំឯកសារគាំទ្រនិងវាយតម្លៃស្ដង់ដាសាលាមធ្យមសិក្សាគំរូនេះ។

ដើម្បីអនុវត្តគោលនយោបាយនានាមានប្រសិទ្ធភាពនៅសាលារៀន ទាមទារឱ្យមាននូវការរៀបចំ

ប្រព័ន្ធអនុវត្តរួមមួយ ប្រកបដោយឯកសណ្ឋានភាព និងស្តង់ដាគុណភាពខ្ពស់។ ក្នុងស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំស្តង់ដាសាលាមធ្យមសិក្សាគំរូ ដើម្បីលើកកម្ពស់គុណភាពសិក្សាទាំងចំណេះដឹង ជំនាញ និងឥរិយាបថ និងការផ្លាស់ប្តូរដារិជ្ជមាននូវការគ្រប់គ្រង ការដឹកនាំ និងការផ្តល់សេវាអប់រំប្រកបដោយទំនួលខុសត្រូវ និងភាពជាម្ចាស់។

សាលាមធ្យមសិក្សាគំរូ គឺជានាបាននូវគណនេយ្យភាពរបស់សាលារៀនចំពោះសហគមន៍ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ លក្ខណសម្បត្តិនៃសាលាមធ្យមសិក្សាគំរូរួមមាន សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ សម្រេចបានស្តង់ដាសាលារៀនគំរូ មានស្វ័យភាពក្នុងការងារផែនការកែលម្អសាលារៀន គណៈគ្រប់គ្រងនិងគ្រូបង្រៀន សិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្តដើម្បីកែលម្អការបង្រៀន ការបង្កើតសកម្មភាពក្រៅម៉ោងសិក្សាដើម្បីការអប់រំសីលធម៌ ចរិយាធម៌ ការយកចិត្តទុកដាក់ដល់សុខភាពសិក្សា និងការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាលនិងសហគមន៍ក្នុងការគាំទ្រនិងអភិវឌ្ឍសាលារៀន។

ក្រសួងអប់រំ យុវជន និងកីឡាមានការរំពឹងទុកថា ថ្នាក់ដឹកនាំ នាយកដ្ឋានពាក់ព័ន្ធនានា ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សហគមន៍ អង្គការដៃគូនានា៖

១.សិក្សាឈ្វេងយល់លម្អិតឱ្យបានកាន់តែស៊ីជម្រៅ និងច្បាស់លាស់ និងយកចិត្តទុកដាក់ខ្ពស់លើខ្លឹមសារទាំងមូលនៃយន្តការគាំទ្រសាលាមធ្យមសិក្សាគំរូនេះ ដោយឯកសារនេះគឺជាឯកសារស្នូលសម្រាប់ការពង្រឹងការអនុវត្តស្តង់ដាសាលារៀនគំរូឱ្យទទួលបានជោគជ័យ។

២.ចូលរួមអនុវត្តផែនការប្រកបដោយការទទួលខុសត្រូវ ផ្តោតលើលទ្ធផលជាប្រចាំ ដើម្បីជំរុញឱ្យសាលារៀនអាចប្រែក្លាយជាសាលារៀនគំរូបាន ឆ្លើយតបទៅនឹងចក្ខុវិស័យអប់រំនិងអភិវឌ្ឍសមត្ថភាពសិស្សឱ្យទទួលបានចំណេះដឹង ដែលអាចដោះស្រាយបញ្ហា បំពេញតម្រូវការគ្រួសារ និងសង្គមអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ និងពង្រឹងស្មារតីរស់នៅប្រកបដោយគុណធម៌ សីលធម៌ សុជីវធម៌ និងមានសេចក្តីស្រឡាញ់ចំពោះខ្លួនឯង គ្រួសារ សង្គមជាតិ និងធម្មជាតិទាំងឡាយប្រកបដោយភាពសុខដុមរមនា។

## ២. ស្តង់ដាសាលាមធ្យមសិក្សាគំរូ

ដើម្បីជំរុញការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព ស្របតាមអាទិភាពនៃកម្មវិធីកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់គុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នូវស្តង់ដាសាលាមធ្យមសិក្សាគំរូចំនួន៥ដូចខាងក្រោម៖

**ស្តង់ដាទី១. លទ្ធផលសិក្សារបស់សិស្ស**

**ស្តង់ដាទី២. ការបង្រៀននិងរៀន**

**ស្តង់ដាទី៣. ការចូលរួមរបស់សហគមន៍**



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ស្តង់ដាទី៤. ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន**

**ស្តង់ដាទី៥. គណនេយ្យភាពរបស់សាលារៀន។**

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករ៨២ សម្រាប់មធ្យមសិក្សាបឋមភូមិ និង សូចនាករ៨៣ សម្រាប់មធ្យមសិក្សាទុតិយភូមិ ដែលក្នុងនោះ ស្តង់ដាទី១ មានសូចនាករគោល៥ និង សូចនាកររង២០ (នៅមធ្យមសិក្សាបឋមភូមិ)២១ (នៅមធ្យមសិក្សាទុតិយភូមិ) ស្តង់ដាទី២ មាន សូចនាករគោល៩ និងសូចនាកររង២៩ ស្តង់ដាទី៣ មានសូចនាករគោល៣ និងសូចនាកររង៦ ស្តង់ដាទី៤ មានសូចនាករគោល៦ និងសូចនាកររង២៣ ស្តង់ដាទី៥ មានសូចនាករគោល៣ និងសូចនាកររង៤។

កម្រិតផ្ទៀងផ្ទាត់សូចនាករ ជាការកំណត់ពីលទ្ធផលតាមបែបគុណវិស័យ ឬបរិមាណវិស័យ ស្របតាមទិដ្ឋភាពជាក់ស្តែងនិងជាការបង្ហាញភស្តុតាងនៃការអនុវត្តសូចនាករនីមួយៗដើម្បីចង្អុលបង្ហាញ ពីកម្រិតវាស់វែងការអនុវត្តសូចនាករ ដូចមានបង្ហាញក្នុងតារាងស្តង់ដាសាលា មធ្យមសិក្សាគំរូខាងក្រោម។

ការផ្ទៀងផ្ទាត់លទ្ធផលគឺជាការវាយតម្លៃលើការអនុវត្តកម្រិតសូចនាករទាំង៨២ ឬ៨៣ ដោយ ដាក់ពិន្ទុផ្អែកលើភស្តុតាងសូចនាករនីមួយៗដែលមានពិន្ទុសរុប៤១០ ឬ៤១៥ ពិន្ទុ ស្មើនឹង ១០០%។ ការកំណត់ថា មានឬមិនទាន់មានលក្ខណៈគំរូត្រូវបានកំណត់ដូចខាងក្រោម៖

- សាលាមធ្យមសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី៩៥% ឡើងទៅនឹងត្រូវចាត់ទុកថា មាន ស្តង់ដាពេញលេញ
- សាលាមធ្យមសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី៨០% ដល់តិចជាង៩៥% ត្រូវចាត់ទុកថា មានស្តង់ដា
- សាលាមធ្យមសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី៦០% ដល់តិចជាង៨០% ត្រូវចាត់ទុកថា មានស្តង់ដាអប្បបរមា។
- សាលាមធ្យមសិក្សាដែលទទួលលទ្ធផលចាប់ពីស្តង់ដាអប្បបរមាឡើងទៅមានការទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា។ ការផ្ទៀងផ្ទាត់លទ្ធផលត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖
  - **ជំហានទី១.** ពិនិត្យផ្ទៀងផ្ទាត់ផ្អែកលើភស្តុតាងជាកំណត់ត្រាលទ្ធផលជាក់ស្តែងនៃ លទ្ធផលសូចនាករនីមួយៗ។
  - **ជំហានទី២.** របៀបដាក់ពិន្ទុ ប្រសិនបើភស្តុតាងធៀបទៅនឹងកម្រិតផ្ទៀងផ្ទាត់សូចនាករ បានគ្រប់ចំណុច និងត្រឹមត្រូវ នោះនឹងទទួលបាន៥ពិន្ទុ តាមសូចនាករនោះ។

តារាងពិន្ទុវាយតម្លៃគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិសាធារណៈគំរូ

| ស្តង់ដា | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុប |
|---|---|---|---|---|---|---|
| | លទ្ធផលសិក្សារបស់សិស្ស | ដំណើរការបង្រៀននិងរៀន | ការចូលរួមរបស់សហគមន៍ | ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន | គណនេយ្យភាព | |
| ចំនួនសូចនាករ | ២០ | ២៩ | ៦ | ២៣ | ៤ | ៨២ |
| ពិន្ទុអតិបរមា | ១០០ | ១៤៥ | ៣០ | ១១៥ | ២០ | ៤១០ |
| ពិន្ទុជាប់ស្តង់ដា (៦០%) | ៦០ | ៨៧ | ១៨ | ៦៩ | ១២ | ២៤៦ |

តារាងពិន្ទុវាយតម្លៃគ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិសាធារណៈគំរូ

| ស្តង់ដា | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុប |
|---|---|---|---|---|---|---|
| | លទ្ធផលសិក្សារបស់សិស្ស | ដំណើរការបង្រៀននិងរៀន | ការចូលរួមរបស់សហគមន៍ | ដំណើរការប្រតិបត្តិនិងរដ្ឋបាលសាលារៀន | គណនេយ្យភាព | |
| ចំនួនសូចនាករ | ២១ | ២៩ | ៦ | ២៣ | ៤ | ៨៣ |
| ពិន្ទុអតិបរមា | ១០៥ | ១៤៥ | ៣០ | ១១៥ | ២០ | ៤១៥ |
| ពិន្ទុជាប់ស្តង់ដា (៦០%) | ៦៣ | ៨៧ | ១៨ | ៦៩ | ១២ | ២៤៩ |

***ឧបសម្ព័ន្ធទី១៖*** *ស្តង់ដាសាលាមធ្យមសិក្សាគំរូ*

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស

### យុទ្ធសាស្ត្រទី១.១៖ ធ្វើកំណែទម្រង់នៃការប្រឡងឱ្យស្របនឹងបរិបទអប់រំបែបថ្មី(ដែលមានរៀបរាប់ក្នុងស្តង់ដាទី២ ខាងក្រោម)

**សកម្មភាពទី១.១.១៖** កែប្រែទម្រង់ប្រឡងបែបសំណេរផ្អែកលើបញ្ញត្តិអរូបី (Abstract) មកជាការប្រឡងបែបអនុវត្តផ្ទាល់ និង/ឬ ការធ្វើបទបង្ហាញជាក់ស្តែងពីគម្រោងណាមួយ (ជាក្រុមផងជាបុគ្គលម្នាក់ៗផង)

**សកម្មភាពទី១.១.២៖** រៀបចំបំពាក់នូវឧបករណ៍ក៏ដូចជា ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រឡងបែបថ្មីនេះ តាមរយៈមធ្យោបាយនានា

### យុទ្ធសាស្ត្រទី១.២៖ ស្វែងរកនូវកិច្ចសហប្រតិបត្តិការពីសំណាក់អ្នកពាក់ព័ន្ធចម្បងៗក្នុងការបំពេញនូវចន្លោះខ្វះខាតរបស់សាលារៀនក្នុងការរៀន និងបង្រៀនបែបឌីជីថល

**សកម្មភាពទី១.២.១៖** លើកកម្ពស់ការយល់ដឹងពីការអប់រំបែបឌីជីថលថ្មីដល់សហគមន៍ និងប្រសិនបើអាចរៀបចំជាការបណ្តុះបណ្តាល ពិសេស សម្រាប់សហគមន៍អំពីប្រព័ន្ធអប់រំបែបឌីជីថល និងវិធីសាស្ត្របង្រៀន និងវាយតម្លៃការសិក្សាបែបឌីជីថលដល់សហគមន៍ ដើម្បីពួកគាត់អាចចូលរួមក្នុងការអប់រំឌីជីថលនេះបាន។

**សកម្មភាពទី១.២.២៖** ស្វែងរកកិច្ចសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួនដូចជា អាជ្ញាធរដែនដី ក្រសួង មន្ទីរពាក់ព័ន្ធ និងអង្គការដៃគូនានា ក្នុងសកម្មភាពអប់រំឌីជីថលនេះ ឧទាហរណ៍៖ អាជ្ញាធរដែនដីអាចនឹងរួមចំណែក (តាមរយៈកងកម្លាំងនគរបាល) ក្នុងការចាប់អារម្មណ៍លើសកម្មភាពសិស្សគេចសាលានិងអាចធ្វើសេចក្តីរាយការណ៍ដល់សហគមន៍ ឬ/និងសាលារៀនដើម្បីទទួលបានព័ត៌មាន ឬក៏អាចណែនាំដល់សិស្សទាំងនោះ។

## ស្តង់ដាទី២៖ ដំណើរការបង្រៀន និងរៀន

ដំណើរការនៃសកម្មភាពការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែមក្រៅម៉ោងសិក្សា (Extra-Curricular STEM Skills) គឺដើម្បីផ្តល់មួយម៉ោងយ៉ាងតិចដល់សិស្សដែលកំពុងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិស្របតាមចំណង់ចំណូលចិត្ត ទេពកោសល្យរបស់ខ្លួននិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារជាក់ស្តែងនៅក្នុងសហគមន៍ និងជួយតម្រង់ទិសការសិក្សារបស់សិស្សផ្នែកស្ទែមទៅកាន់ភូមិសិក្សាបន្ទាប់។

សកម្មភាពដែលអនុវត្តដើម្បីគាំទ្រនូវការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែមរួមមាន៖

- បង្កើតគណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែម ដើម្បីធានាប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការបណ្តុះបណ្តាលមុខជំនាញបន្ថែមផ្នែកស្ទែមដល់អ្នកសិក្សា។
- ការរៀបចំដំណើរការបណ្តុះបណ្តាលជំនាញ ដោយសិក្សាពីសមត្ថភាពគ្រូ ទីតាំង សម្ភារៈ និងកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាល។
- ការវាយតម្លៃការបណ្តុះបណ្តាលជំនាញ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវផ្តោតទៅលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។
- ថវិកាសម្រាប់ការបណ្តុះបណ្តាលជំនាញ ត្រូវបានសម្រេចរួមគ្នា ដោយគណៈកម្មការដឹកនាំគ្រប់គ្រងការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែម និងរៀបចំផែនការសកម្មភាព និងផែនការថវិកា។

យុទ្ធសាស្ត្រទី២.១៖ ការអភិវឌ្ឍនូវវិធីសាស្ត្របង្រៀនបែបថ្មីនិងរួមបញ្ចូលនូវបច្ចេកវិទ្យាឌីជីថល

ក្នុងន័យនេះ វាជាករណីយកិច្ចយ៉ាងសំខាន់ ដែលប្រព័ន្ធអប់រំត្រូវអភិវឌ្ឍនូវវិធីសាស្ត្របង្រៀនបែបថ្មីនិងស្របតាមការវិវត្តនៃពិភពលោកទៅរកបច្ចេកវិទ្យាឌីជីថល។ ការបង្រៀនបែបថ្មីដោយផ្អែកលើបច្ចេកវិទ្យាឌីជីថលគឺជាគន្លឹះក្នុងការធានានូវប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការអប់រំ ដោយសិស្សានុសិស្សអាចនឹងមានការយល់ច្បាស់ពីខ្លឹមសារមេរៀនជាក់ស្តែង ជាពិសេស ការអប់រំស្ទែម ឧទាហរណ៍ ជាមួយនឹងការបង្រៀននូវមេរៀនបែបឌីជីថលនៃទម្រង់កោសិកា សិស្សអាចនឹងយល់ច្បាស់ពីសមាសភាពនៃជាតុកោសិកា មុខងារ និងការប្រព្រឹត្តទៅផ្សេងៗទៀតនៃកោសិកា ដោយការបង្រៀនឱ្យមើលឃើញផ្ទាល់នឹងភ្នែក (Concrete) ជាជាងការបង្រៀនតាមសៀវភៅដែលពឹងផ្អែកលើការស្រមៃមិនជាក់ស្តែង (Abstract) លើមេរៀនដែលនាំឱ្យយល់មេរៀនមិនច្បាស់ ខាតពេលវេលាច្រើន និងជាបន្ទុកធ្ងន់ដែលមិនចាំបាច់សម្រាប់គ្រូ និងសិស្ស។

សកម្មភាពដែលគួរអនុវត្តដើម្បីគាំទ្រនូវយុទ្ធសាស្ត្រនេះរួមមាន៖

**សកម្មភាពទី២.១.១៖** អភិវឌ្ឍនូវមេរៀនថ្មីៗដែលមានទម្រង់ជាឌីជីថលទំនើបសម្រាប់បង្រៀននិងរៀន

**សកម្មភាពទី២.១.២៖** បំប្លែងមាតិកាមេរៀនដែលមានស្រាប់ (ជាពិសេសមេរៀនស្ទែម) ពីទម្រង់សៀវភៅឱ្យទៅជាទម្រង់ឌីជីថលដែលរស់រវើកស្របនឹងការរៀនបែបឌីជីថលរបស់សិស្ស

**សកម្មភាពទី២.១.៣៖** កែទម្រង់នូវការប្រឡងដោយជំនួសទម្រង់ប្រឡងបែបប្រពៃណីពឹងផ្អែកលើការគិតបែបអរូបី ពីសៀវភៅសិក្សាគោលមកជាទម្រង់ឌីជីថលជាក់ស្តែងមានសង្គតិភាពទៅនឹងមេរៀនឌីជីថល



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**សកម្មភាពទី២.១.៤៖** បណ្តុះបណ្តាលគ្រូបង្រៀនជំនាន់មុនៗដែលមិនបានស្គាល់ពីប្រព័ន្ធអប់រំបែបឌីជីថលឱ្យយល់ដឹងច្បាស់ពីឌីជីថល និងព័ត៌មានវិទ្យា

**សកម្មភាពទី២.១.៥៖** រាជរដ្ឋាភិបាលគួររៀបចំកញ្ចប់ថវិកា ពិសេសសម្រាប់វិនិយោគលើឧបករណ៍ឌីជីថលដែលបម្រើដល់ការបង្រៀនបែបថ្មីនេះ (មានជម្រើសមួយចំនួនសម្រាប់សកម្មភាពនេះ ដោយរដ្ឋអាចនឹងស្នើជាកម្ចីដល់ប្រទេសជាមិត្ត ឬអង្គការអន្តរជាតិនានា ឬស្នើសុំសម្ភារៈឌីជីថលចាស់ៗតែនៅប្រើបាន ពីបណ្តាប្រទេសជាមិត្តនានា ឬរដ្ឋាភិបាលអាចនឹងផ្តល់ឱកាសដល់សិស្សានុសិស្សចុះឈ្វេងយល់ពីការងារបែបឌីជីថលតាមក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាល)។

### យុទ្ធសាស្ត្រទី២.២៖ ការអភិវឌ្ឍ និងត្រៀមលក្ខណៈនៃប្រព័ន្ធអប់រំកម្ពុជាក្នុងដំណើរការអប់រំបែបឌីជីថល

ជាការពិតណាស់ ប្រទេសយើងត្រូវតាមឱ្យទាន់នូវបរិវត្តកម្មឌីជីថល ដែលពិភពលោកកំពុងឈានទៅដល់។ ក្នុងន័យនេះ ការអប់រំឌីជីថលគឺជាគន្លឹះមិនអាចខ្វះបានសម្រាប់បេសកកម្មនេះ ហេតុនេះ យើងត្រូវចាប់ផ្តើមឌីជីថលជាមួយនឹងការប្រែក្លាយប្រព័ន្ធអប់រំឱ្យទៅជាប្រព័ន្ធអប់រំបែបឌីជីថល។ ដើម្បីសម្រេចនូវគោលដៅនេះយើងត្រូវមានសកម្មភាពមួយចំនួនដូចជា៖

**សកម្មភាពទី២.២.១៖** ធ្វើឌីជីថលូបនីយកម្មលើប្រព័ន្ធបណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀននៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

**សកម្មភាពទី២.២.២៖** វិនិយោគ និងកៀរគរជំនួយលើវិស័យឌីជីថល

**សកម្មភាពទី២.២.៣៖** បំពាក់នូវឧបករណ៍ឌីជីថលឱ្យបានគ្រប់គ្រាន់ឬសមស្របតាមសាលារៀននានាដោយអាចចាប់ផ្តើមជាមួយនឹងសាលាគោលដៅដែលចង់ប្រែក្លាយជាសាលាមធ្យមសិក្សាគំរូ។

**សកម្មភាពទី២.២.៤៖** គួរពិចារណា និងរៀបចំនូវផែនការយុទ្ធសាស្ត្រជាបណ្តើរៗសម្រាប់ពង្រីកឌីជីថលូបនីយកម្មនៅកម្រិតបឋមសិក្សា និងមត្តេយ្យសិក្សាដែលតាមពិតទៅ សឹងតែមានអាទិភាពក្នុងការទទួលបាននូវសកម្មភាពនេះមុនគេបង្អស់(ការអនុវត្តនូវសាលារៀនស្តង់ដានឹងកាន់តែងាយស្រួលខ្លាំងប្រសិនបើចាប់ផ្តើមពី កម្រិតបឋមសិក្សា)

**សកម្មភាពទី២.២.៥៖** ដោយសហការជាមួយនឹងសហគមន៍ អាជ្ញាធរដែនដីនិងក្រសួង ស្ថាប័នពាក់ព័ន្ធ គួរលើកកម្ពស់ការយល់ដឹងអំពីឌីជីថលដល់សហគមន៍ ដើម្បីទទួលបានការសហការនិងជំនួយគាំទ្រពីសហគមន៍។

យុទ្ធសាស្ត្រទី២.៣៖ ការបង្កើតបរិយាកាសអប់រំដែលទាក់ទាញ មានបែបផែនជាការកម្សាន្ត និងលើកកម្ពស់ការចូលរួមនិងការប្រើប្រាជ្ញារបស់សិស្សានុសិស្ស

**សកម្មភាពទី២.៣.១៖** យុទ្ធនាការបញ្ជូនគ្រូបង្រៀន និងបុគ្គលិកអប់រំទៅធ្វើទស្សនកិច្ចសិក្សា និងដកស្រង់នូវបទពិសោធជោគជ័យនៃការបង្រៀនបែបថ្មី តាមបណ្តាប្រទេសនានា ដែលមានប្រព័ន្ធអប់រំល្អ ប៉ុន្តែត្រូវមានលក្ខខណ្ឌម៉ឺងម៉ាត់ ដោយអ្នកដែលទៅធ្វើទស្សនកិច្ចទាំងនោះ ត្រូវមានជាធាតុចេញ (Output) និងលទ្ធផលថ្មីៗដែលជួយគាំទ្រដល់វិធីសាស្ត្របង្រៀនថ្មី។

**សកម្មភាពទី២.៣.២៖** បំប្លែងបរិយាកាសថ្នាក់រៀនបែបប្រពៃណីដែលដាក់សម្ពាធលើសិស្សមកជាថ្នាក់រៀនបែបមេត្រីភាពនិងការកម្សាន្ត។ ក្នុងន័យនេះ គ្រូបង្រៀនគឺជាអ្នកចាត់ចែងល្បែងកម្សាន្តសម្រាប់ការសិក្សា (ដូចជា ល្បែងល្បងប្រាជ្ញាបែបតក្កវិទ្យា ឬល្បែងនានាដែលទាមទារឱ្យសិស្សមានចំណេះដឹងលើគណិតវិទ្យា ទើបអាចដោះស្រាយបាន) គ្រូជាអ្នកលើកទឹកចិត្តនិងបំផុសគំនិតដល់សិស្ស និងជាអ្នកសម្របសម្រួលក្នុងសកម្មភាពបង្រៀនបែបកម្សាន្តនេះ។

**សកម្មភាពទី២.៣.៣៖** ការលើកទឹកចិត្តសិស្សឱ្យបង្កើនការរៀនដោយមធ្យោបាយនានា ដូចជា ការបង្កើតជាក្លឹបសិក្សា ការផ្តល់ពិន្ទុពិសេសដល់សិស្សដែលចូលរួមក្នុងក្លឹបសិក្សាក៏ដូចជា បានអានសៀវភៅពីបណ្ណាល័យ ការចូលរួមក្នុងសកម្មភាពសាលារៀនជាដើម។

**សកម្មភាពទី ២.៣.៤៖** រាជរដ្ឋាភិបាលដែលមានក្រសួងអយក. ជាសេនាធិការគួររៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀនក្នុងថ្នាក់រៀន និងនៅផ្នែកផ្សេងៗទៀតនៃសាលារៀនដូចជា បណ្ណាល័យជាដើម ឱ្យមានបរិយាកាសមេត្រីភាព មានភាពទាក់ទាញ និងលើកកម្ពស់ការប្រើប្រាជ្ញារបស់សិស្ស ក៏ដូចជាការផ្តល់នូវភាពសប្បាយរីករាយ និងលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងប្រព័ន្ធអប់រំថ្មីនេះ។

## ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍

យុទ្ធសាស្ត្រទី៣.១៖ បង្កើតជាយន្តការអន្តរក្រសួង ដើម្បីលើកកម្ពស់សេដ្ឋកិច្ចសង្គមនៃសហគមន៍

**សកម្មភាពទី៣.១.១៖** យន្តការអន្តរក្រសួងត្រូវធ្វើការសិក្សាលម្អិតលើចរិតលក្ខណៈ (Profile) របស់សហគមន៍នីមួយៗតាមតំបន់រៀងៗខ្លួនក្នុងកម្រិតឃុំ ឬបើអាចគឺកម្រិតភូមិ

**សកម្មភាពទី៣.១.២៖** ឈ្វេងយល់ពីធនធាន(ធម្មជាតិ មនុស្ស វប្បធម៌ជាដើម)ដែលសហគមន៍មាន

**សកម្មភាពទី៣.១.៣៖** កំណត់នូវបណ្តាផលិតផល ឬសេវាកម្ម ដែលសហគមន៍មានសក្តានុពលក្នុងការផលិត ឬផ្តល់ជូន ឧទាហរណ៍៖ ផលិតផលគ្រឿងសមុទ្រ ឬសេវាកម្មទេសចរណ៍



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**សកម្មភាពទី៣.១.៤៖** យន្តការអន្តរក្រសួងត្រូវធ្វើអន្តរាគមន៍បង្កើតឱ្យខានតែបាននូវខ្សែសង្វាក់តម្លៃ (Value Chain) នៃផលិតផល ឬសេវាកម្មដែលសហគមន៍ផលិត ឬផ្តល់ឱ្យបាន (ឧទាហរណ៍៖ ភ្ជាប់ខ្សែសង្វាក់តម្លៃទៅនឹងទីផ្សារដែលមានសក្តានុពលធំ និងតម្លៃបន្ថែមខ្ពស់ (High Value-added)

**សកម្មភាពទី៣.១.៥៖**ផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈដែលចាំបាច់ក្នុងសហគមន៍ដើម្បីពួកគាត់អាចចូលរួមក្នុងខ្សែសង្វាក់តម្លៃបាន (ឧទាហរណ៍៖សមត្ថភាពផលិត សមត្ថភាពធ្វើពាណិជ្ជកម្ម សមត្ថភាពក្នុងជំនាញគណនេយ្យជាដើម)។

យុទ្ធសាស្ត្រទី៣.២៖ ធ្វើកំណែទម្រង់សាលារៀនដែលអាចបំពេញនូវតម្រូវការសហគមន៍ និងទាក់ទាញការចូលរួម និងគាំទ្រពីសហគមន៍

**សកម្មភាពទី៣.២.១៖** កែទម្រង់សាលារៀនដោយចាប់ផ្តើមនូវការបញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននូវសកម្មភាពទាំងឡាយណា ដែលមានផលជះដល់សហគមន៍ ក៏ដូចជាការងារដែលតម្រូវឱ្យមានការចូលរួមពីសហគមន៍ (ឧទាហរណ៍៖ ការដឹកនាំសិស្សានុសិស្សទៅកាន់សហគមន៍របស់ពួកគេ ហើយអនុវត្តនូវខ្លឹមសារមេរៀនដោយផ្តោតលើករណីសហគមន៍ ដែលសិស្សរស់នៅតែម្តងហើយ បើអាចគម្រោងអនុវត្តខ្លឹមសារមេរៀនគួរតែបន្សល់ទុកនូវអ្វីមួយដល់សហគមន៍ ដូចជា ថ្នាលដាំដុះ ឬវត្ថុដែលផលិតបានដោយសិស្សដូចជា ផលិតផលសិប្បកម្មសាមញ្ញៗជាដើម)។

**សកម្មភាពទី៣.២.២៖** អញ្ជើញសហគមន៍ឱ្យចូលរួមគ្រប់កិច្ចប្រជុំដែលពាក់ព័ន្ធទាំងអស់ធ្វើខ្ទង់ចំណូលចំណាយប្រកបដោយតម្លាភាព បង្ហាញពីលទ្ធផលជាក់ស្តែងដែលសាលាសម្រេចបានទៅកាន់សហគមន៍។ សាលារៀនក៏អាចនឹងដើរតួនាទីជាអ្នកគាំទ្រសហគមន៍នៅពេលមានតម្រូវការជំនួយ ឧទាហរណ៍ សាលាអាចនឹងរៀបចំជាថ្នាក់អក្ខរកម្មដល់មាតាបិតាសិស្ស ដែលមិនចេះអក្សរឬអាចនឹងជួយបណ្តុះបណ្តាលសហគមន៍នូវចំណេះដឹងនានា ដែលសហគមន៍ត្រូវការដើម្បីដំណើរការខ្សែសង្វាក់តម្លៃរបស់ខ្លួន។

**សកម្មភាពទី៣.២.៣៖** លើកកម្ពស់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ ឧទាហរណ៍៖ តាមរយៈការផ្តល់ព័ត៌មានទៅវិញទៅមកអំពីព័ត៌មានរបស់សិស្ស (នៅសាលានិងនៅសហគមន៍) ការសិក្សារបស់សិស្ស សកម្មភាពសិស្ស បញ្ហារបស់សិស្សជាដើម។ ប្រសិនបើអាច ស្នើឱ្យមាតាបិតាសិស្សប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការតាមដានសិស្ស ក៏ដូចជាជួយបង្រៀនសិស្ស។ ឧទាហរណ៍មួយទៀត គឺការគាំទ្រផ្នែកហិរញ្ញវត្ថុទៅវិញទៅមកក្នុងពេលអាសន្នជាបន្ទាន់នៅក្នុងសាលារៀន និងនៅសហគមន៍។

**សកម្មភាពទី៣.២.៤៖** ប្រែក្លាយសាលារៀនឱ្យក្លាយជាអង្គភាពដែលអាចរកថវិកាបាន។ ឧទាហរណ៍ ការបង្កើតសួនបន្លែនិងកសិដ្ឋានក្នុងសាលារៀនដែលមានអត្ថប្រយោជន៍សម្រាប់ការអនុវត្តរបស់សិស្សផង និងអាចផ្តល់នូវផលិតផលសម្រាប់លក់ទៅទីផ្សារ ហើយចំណូលដែលទទួលបានគឺទុកជាថវិកាសម្រាប់បម្រុងរបស់សាលារៀន ។

ស្តង់ដារទី៤៖ ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន

យុទ្ធសាស្ត្រទី៤.១៖ ឌីជីថលូបនីយកម្មលើដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន

**សកម្មភាពទី៤.១.១៖** បង្កើតជាប្រព័ន្ធទិន្នន័យរួមមួយសម្រាប់សាលារៀនផ្តល់នូវទិន្នន័យដល់អង្គភាពនានានៃក្រសួងអប់រំ យុវជន និងកីឡា ដោយទាមទារនូវការបញ្ចូលទិន្នន័យតែម្តងជាការស្រេច (One for All)

**សកម្មភាពទី៤.១.២៖** ការបំពាក់នូវឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលដល់សាលារៀន និងអង្គភាពអប់រំទាំងអស់ដោយរួមទាំងការផ្តល់សេវាអ៊ីនធឺណែតដែលមិនរអាក់រអួលនិងមាននិរន្តរភាព

**សកម្មភាពទី៤.១.៣៖** បណ្តុះបណ្តាលក្នុងក្របខ័ណ្ឌទូទាំងប្រទេសដល់គ្រប់បុគ្គលិកអប់រំទាំងអស់ ទាំងអ្នកបង្រៀន និងមិនបង្រៀននូវចំណេះដឹង និងជំនាញឌីជីថល

**សកម្មភាពទី៤.១.៤៖** ធ្វើការកៀរគរជំនួយពីអ្នកពាក់ព័ន្ធទាំងអស់លើបច្ចេកវិទ្យាឌីជីថលមិនថាជំនួយជាសម្ភារៈ ជាចំណេះដឹង ឬជាការគាំទ្រនានានោះទេ

យុទ្ធសាស្ត្រទី៤.២៖ ពង្រឹងរដ្ឋបាល និងប្រតិបត្តិការសាលាឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល

**សកម្មភាពទី៤.២.១៖** អនុវត្តនូវគោលការណ៍អភិបាលកិច្ចល្អនៅកម្រិតសាលារៀន ក៏ដូចជាកម្រិតអង្គភាពអប់រំនានា

**សកម្មភាពទី៤.២.២៖** អនុវត្តយ៉ាងខ្ជាប់ខ្ជួននូវក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ដោយនាយកសាលាត្រូវទាមទារនូវគុណវុឌ្ឍិរបស់នាយកសាលា

**សកម្មភាពទី៤.២.៣៖** បែងចែកឱ្យច្បាស់នូវមុខងារបុគ្គលិកអប់រំទាំងអស់ក្នុងសាលា ជាពិសេសគឺរវាងបុគ្គលិកបង្រៀន និងមិនបង្រៀន និងថ្នាក់ដឹកនាំសាលា ។

**សកម្មភាពទី៤.២.៤៖** គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគួរបង្កើតនូវជំនាញថ្មីមួយទៀតគឺរដ្ឋបាលអប់រំ ដើម្បីបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលដែលមិនបង្រៀនឱ្យមានជំនាញបំពេញការងារ

**សកម្មភាពទី៤.២.៥៖** ផ្គត់ផ្គង់បុគ្គលិកបង្រៀននិងមិនបង្រៀនឱ្យបានគ្រប់គ្រាន់ពេលគឺដើម្បីជៀសវាងការចាត់តាំងបុគ្គលិកមិនបង្រៀនឱ្យទៅបង្រៀនដោយសារខ្វះគ្រូ

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ស្តង់ដាទី៥៖ គណនេយ្យភាព

យុទ្ធសាស្ត្រទី៥.១៖ ធ្វើឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតបុគ្គលិកអប់រំឱ្យមានទម្លាប់ធ្វើការប្រកបដោយគណនេយ្យភាពតាមគ្រប់វិធានការណ៍

**សកម្មភាពទី៥.១.១៖** ផ្តល់ការលើកទឹកចិត្តសមស្របដល់បុគ្គលិកអប់រំទៅតាមលក្ខណសម្បត្តិ (គុណវុឌ្ឍិ អាកប្បកិរិយា ទំហំការងារ និងជាពិសេសគឺលទ្ធផលដែលសម្រេចបាន)ឧទាហរណ៍៖ ការលើកទឹកចិត្តក្រោមទម្រង់ជាហិរញ្ញវត្ថុ (រួមមានទាំងការបង្កើនបៀវត្សរ៍ផងដែរ)ឱកាសបណ្តុះបណ្តាល ឬទស្សនកិច្ច ការសរសើរ មេដាយ និងតារាងកិត្តិយសជាដើម

**សកម្មភាពទី៥.១.២៖** បង្កើតនូវយន្តការគតិយុត្តដែលកំណត់ច្បាស់ពីទំនួលខុសត្រូវការលើកទឹកចិត្ត និងការពិន័យ វិធានការណ៍រដ្ឋបាល និងគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

យុទ្ធសាស្ត្រទី៥.២៖ លើកកម្ពស់ជីវភាពបុគ្គលិកអប់រំតាមគ្រប់មធ្យោបាយ

**សកម្មភាពទី៥.២.១៖** ជួយគាំទ្រសាលាឱ្យក្លាយជាអង្គភាពមានប្រាក់ចំណូលបែបអសកម្ម ( Passive Income ) ឧទាហរណ៍៖ ជួលទីតាំង សួនបន្លែនិងកសិដ្ឋាន ឬផ្តល់ជាទីតាំងសម្រាប់ទេសចរណ៍ ( ក្នុងករណីសមស្រប ) ជាដើម។

**សកម្មភាពទី៥.២.២៖** បន្តអភិវឌ្ឍសាលារៀនឱ្យក្លាយជាសាលាគំរូ និងមានផលជះគ្រប់គ្រាន់ដើម្បីទាក់ទាញជំនួយឧបត្ថម្ភ ( ជាពិសេសគឺហិរញ្ញវត្ថុ ) ពីភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស សហគមន៍ អង្គការដៃគូ វិស័យឯកជន និងភ្នាក់ងារផ្តល់ជំនួយអន្តរជាតិជាដើម។

*ឧបសម្ព័ន្ធទី១៖ ស្តង់ដាសាលាមធ្យមសិក្សាគំរូ*

## ៣. ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៅតាមសាលារៀន

### ៣.១ សេចក្តីផ្តើម

ការកែលម្អសាលារៀនបានជោគជ័យ កើតចេញមួយផ្នែកពីការអនុវត្តវិធីសាស្ត្របង្រៀនថ្មី ប៉ុន្តែបើគ្មានបរិយាកាសអំណោយផលទេ ការអនុវត្តការបង្រៀននិងការសិក្សាតាមគំរូថ្មីៗ ក៏មិនអាចរីកចម្រើនបានដែរ។ ផ្អែកតាមគំរូអនុវត្តនៅសាលារៀនជំនាន់ថ្មី (NGS) មានធាតុផ្សំផ្សេងៗរបស់ប្រព័ន្ធអេកូគរុកោសល្យ ដែលក្នុងនោះធាតុសំខាន់គឺអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ប៉ុន្តែក៏មានយន្តការគាំទ្រដោយផ្ទាល់ដល់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន រួមទាំងការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន (PLC) ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ( CPD) និងប្រព័ន្ធប្រឹក្សាគរុកោសល្យ។ ធាតុទាំងនេះរួមបញ្ចូលគ្នាដើម្បីផ្តល់ឥទ្ធិពលវិជ្ជមានដល់ការសិក្សារបស់សិស្ស។ សូមអានបន្ថែមក្របខណ្ឌគរុកោសល្យសតវត្សទី២១សម្រាប់ប្រទេសកម្ពុជាតាមតំណនេះ៖

***ឧបសម្ពន្ធទី២៖*** *ក្របខណ្ឌគរុកោសល្យសតវត្សទី២១ សម្រាប់ប្រទេសកម្ពុជា*

នៅក្នុងអត្ថបទនេះ អ្នកអប់រំនឹងអាច៖

- ពិពណ៌នាអំពីធាតុសំខាន់ៗនៃប្រព័ន្ធអេកូគរុកោសល្យ។
- ពន្យល់ពីសារៈសំខាន់នៃបរិយាកាសគាំទ្រសម្រាប់ការពង្រឹងការអនុវត្តការបង្រៀន។
- ពិពណ៌នាអំពីធាតុសំខាន់ៗនៃអភិបាលកិច្ចល្អនៅក្នុងសាលា។
- រំឭកឡើងវិញនូវមធ្យោបាយមានប្រសិទ្ធភាពក្នុងការជំរុញការចូលរួមសហគមន៍នៅតាមសាលារៀន និងវិធីបង្កើតការជឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការ។

អ្នកអប់រំក៏អាចឆ្លុះបញ្ចាំងផ្ទាល់ខ្លួនអំពីការអនុវត្ត ទៅនឹងទ្រឹស្តីមួយចំនួនខាងក្រោម៖

- ឆ្លុះបញ្ចាំងពីសុពលភាពនៃគំរូ ៧០-២០-១០ នៅក្នុងការអនុវត្តតាមសាលារៀន។
- ឆ្លុះបញ្ចាំងទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព និងការអនុវត្តរបស់សាលា។
- បានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ជាមួយសាលារៀន។
- បានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការបង្កើតទំនុកចិត្ត។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.២ ប្រព័ន្ធអេកូគរុកោសល្យ

ជារឿយៗ សាលារៀនមិនមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីចែករំលែកវិជ្ជាសម្បទាដល់សហការី របស់ខ្លួនទេ ដោយមានហេតុផលផ្សេងៗ រួមមាន កង្វះពេលវេលា គ្មានពេលដាក់លាក់ទុកសម្រាប់កិច្ចការចែករំលែកនេះ មានចំណាប់អារម្មណ៍តិចតួច និងមានការប្តេជ្ញាចិត្តតិចតួច។ ទន្ទឹមនេះ កាលណាមានគ្រូបង្រៀនណាមួយណែនាំវិធីសាស្ត្រសិក្សាបែបថ្មីទៅក្នុងសាលារៀន សហការី ឬនាយកសាលារៀននៅតាមសាលារៀននោះ មិនសូវជាស្វាគមន៍គំនិតថ្មីនេះទេ។ ជាទូទៅមិនសូវមានការយល់ដឹងគ្នាច្រើននោះទេ ពេលខ្លះ គណៈគ្រប់គ្រងគ្រាន់តែចង់ឱ្យគ្រប់គ្នាសប្បាយចិត្តប៉ុណ្ណោះ មិនសូវខ្វល់ពីគំនិតផ្តួចផ្តើម ឬឱ្យតម្លៃគំនិតនេះឡើយ។

កត្តាទាំងអស់នេះ ផ្សារភ្ជាប់ទៅនឹងកង្វះបរិយាកាសគាំទ្រនៅតាមសាលារៀននាំឱ្យសាលារៀនមិនមានភាពជោគជ័យ។ កាលណាទិដ្ឋភាពផ្សេងៗនៃការបង្រៀន និងការរៀនមិនទទួលបានការគាំទ្រត្រឹមត្រូវទេនោះ ការបណ្តុះបណ្តាលបែបនេះក៏មិនមានប្រសិទ្ធភាពអ្វីដែរ។ ដូច្នេះ សាលារៀនត្រូវយល់ដឹងពីរបៀបបង្កើតបរិយាកាសគាំទ្រនៅតាមសាលារៀននិងការអនុវត្តដោយខ្លួនឯងនៅក្នុងសាលារៀន។

**គំរូសិក្សា ៧០-២០-១០**




ដ្យាក្រាមខាងលើគឺជារូបមន្តមួយដែលគេទទួលស្គាល់ច្រើន យកទៅប្រើក្នុងការហ្វឹកហាត់ការងារ។ រូបមន្តនេះ មានកំណើតពីការស្រាវជ្រាវរបស់សហរដ្ឋអាមេរិកកាលពីទស្សវត្សរ៍ឆ្នាំ១៩៨០ លើការសិក្សាពីប្រភពសំខាន់ៗចេញពីអ្នកគ្រប់គ្រងជោគជ័យចំនួន២០០នាក់។

ការស្រាវជ្រាវនេះរកឃើញថា៖

- លទ្ធផល៧០%នៃការសិក្សាទទួលបានពីបទពិសោធផ្ទាល់ នៅពេលបុគ្គលិកជួបបញ្ហាជាក់ស្តែងក្នុងការងារ ហើយទទួលបានមតិត្រឡប់ភ្លាមៗ អំពីការបំពេញការងាររបស់ខ្លួន ពីអ្នកគ្រប់គ្រង និងអ្នកប្រឹក្សាគរុកោសល្យ
- លទ្ធផល២០% នៃការសិក្សា ទទួលបានពីការទំនាក់ទំនង និងកិច្ចសហការជាមួយសហការីមិត្តភក្តិ គ្រូបង្វឹក និងអ្នកប្រឹក្សាគរុកោសល្យ ដែលបានលើកទឹកចិត្ត និងផ្តល់មតិត្រឡប់។
- លទ្ធផល១០% នៃការអភិវឌ្ឍការងារ ទទួលបានពីការបង្រៀនតាមបែបប្រពៃណី និងបានពីកម្មវិធីបំប៉នផ្សេងៗ។

ការសិក្សាទូទៅ និងការបង្រៀនបែបប្រពៃណីតែប៉ុណ្ណឹង មិនមានឥទ្ធិពលផ្ទាល់ និងភ្លាមៗលើកិច្ចការរបស់គ្រូបង្រៀនទេ។ នៅចំណុចនេះ គ្រូបង្រៀនត្រូវប្រមូលសកម្មភាព ហើយស្វែងយល់ជាមុនសិនទើបចាប់ផ្តើមអនុវត្ត និងហ៊ានប្រឈមនឹងបញ្ហាជាក់ស្តែង រៀនសម្របសម្រួលដោះស្រាយបញ្ហានោះ បង្កើតបទពិសោធដោយខ្លួនឯង ដើម្បីទទួលបានវិជ្ជានិងបំណិនសម្បទាថ្មីៗ។ បញ្ហានេះ កើតឡើងចំពោះយើងទាំងអស់គ្នា។ នៅក្នុងវគ្គបណ្តុះបណ្តាល យើងគិតថា យើងយល់ ប៉ុន្តែមានតែពេលអនុវត្តជាក់ស្តែងទេ ដែលអាចបញ្ជាក់ថា យើងបានយល់ដឹងឬមិនសូវយល់ដឹង។

ការកែលម្អសាលារៀនបានជោគជ័យគឺមួយផ្នែកកើតចេញពីការអនុវត្តនូវគរុកោសល្យថ្មីៗចំពោះការសិក្សា សិស្សប៉ុណ្ណោះ ហើយតាមការដកស្រង់ឃ្លាមួយ លើកឡើងថា "**គ្រាប់ពូជមួយអាចដុះលូតលាស់ទៅជារុក្ខជាតិដែលមានសុខភាពល្អបាន ចាំបាច់ត្រូវមានបរិស្ថានគាំទ្រ**"។

ចំណុចខាងលើនេះមានន័យថា ប្រព័ន្ធទាំងអស់ បរិស្ថានទាំងអស់នៅតាមសាលាត្រូវមានសុខភាពល្អ និងដំណើរការបានត្រឹមត្រូវ។ ឧទាហរណ៍ សាលារៀនអាចមានគ្រូបង្រៀនដែលមានសមត្ថភាពច្រើន ប៉ុន្តែប្រសិនបើអ្នកដឹកនាំមិនផ្តល់តម្លៃដល់ពួកគេ ហើយមិនជួយសម្រួលការងាររបស់ពួកគេ គ្រូបង្រៀននឹងមិនអាចធ្វើការងារប្រកបដោយគុណភាព និងឈានដល់សក្តានុពលពេញលេញរបស់ពួកគេឡើយ។ ឧទាហរណ៍មួយទៀតអាចត្រូវបានគេមើលឃើញនៅពេលដែលសាលាមិនអាចបង្កើតទំនាក់ទំនងល្អជាមួយសហគមន៍។

ក្នុងករណីនេះនឹងមិនមានការរួមចំណែកនិងការសហការគ្នាដើម្បីការរៀនសូត្ររបស់សិស្សឡើយ ហើយសិស្សនឹងមិនទទួលបានការជួយពេញលេញដែលនឹងប៉ះពាល់ដល់ដំណើរសិក្សាទាំងមូលរបស់ពួកគេ។

អភិបាលកិច្ចខ្សោយនៅតាមសាលាដែលនឹងប៉ះពាល់ដល់ការសិក្សារបស់សិស្ស។ ខាងក្រោមនេះ គឺជាកត្តាសំខាន់ៗដែលសាលារៀនត្រូវពិចារណា៖

- ការគាំទ្រពីនាយកសាលា និងសហការីផ្សេងទៀត មានភាពចាំបាច់ចំពោះវិធីនាំការរៀនសូត្រថ្មីៗនៅតាមថ្នាក់រៀន។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- យន្តការគាំទ្រដ៏មានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀន ដែលមានទម្រង់ជាការប្រឹក្សាគរុកោសល្យអាចមានប្រសិទ្ធភាពសម្រាប់គ្រូដែលណែនាំវិធីសាស្ត្រថ្មីៗ។ អ្នកប្រឹក្សាគរុកោសល្យនេះអាចជាគ្រូបង្រៀន នាយករងផ្សេងទៀត ឬជាអ្នកប្រឹក្សាគរុកោសល្យដែលបានទទួលការបណ្តុះបណ្តាលពីអង្គការក្រៅរដ្ឋាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា។
- វាមានសារៈសំខាន់ក្នុងការទទួលបានតម្លៃ និងការទទួលស្គាល់ការងាររបស់គ្រូបង្រៀន។
- វាមានសារៈសំខាន់ណាស់ក្នុងការទទួលបានធនធានចាំបាច់សម្រាប់អនុវត្តវិធីសាស្ត្រថ្មីៗ (ទីធ្លា មន្ទីរពិសោធន៍ សម្ភារៈធនធាន និងពេលវេលា)
- កង្វះការគាំទ្រនិងការចាប់អារម្មណ៍នៅក្នុងសាលារៀននឹងបង្អាក់គ្រូបង្រៀនពីការអនុវត្តគំនិតថ្មីៗ។ គ្មានការបែងចែកធនធាន នឹងធ្វើឱ្យលទ្ធភាពក្នុងការស្វែងរកគំនិតថ្មី ជួបផលលំបាក។

បញ្ញត្តិនៃប្រព័ន្ធអេកូគរុកោសល្យគឺសំដៅលើប្រព័ន្ធគាំទ្រដែលអាចឱ្យវិធីសាស្ត្របង្រៀនថ្មីមានការអនុវត្តរីកចម្រើននៅតាមសាលារៀន និងជះឥទ្ធិពលជាវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្ស។ ខាងក្រោមនេះ គឺជារូបភាពនៃប្រព័ន្ធអេកូគរុកោសល្យដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី។ គ្រូបង្រៀនអាចសង្កេតមើលថា តើមានភាពខុសគ្នាអ្វីខ្លះរវាងប្រព័ន្ធអេកូគរុកោសល្យនៅក្នុងសាលារៀនរបស់ខ្លួន និងសាលាជំនាន់ថ្មី?




| | |
|---|---|
| ១.អភិបាលកិច្ចល្អ<br>២.វិធីសាស្ត្របង្រៀនថ្មី<br>៣.បណ្ណាល័យសតវត្សទី២១<br>៤.សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន | ៥.ការរចនាថ្នាក់រៀន និងសម្ភារៈសិក្សា<br>៦.ប្រព័ន្ធប្រឹក្សាគរុកោសល្យគ្រូបង្រៀន<br>៧.បច្ចេកវិទ្យា |

នេះគឺជារូបមន្តរបស់សាលារៀនជំនាន់ថ្មី ហើយរូបមន្តនេះអាចវិវឌ្ឍ និងអាចបន្ថែមជាតុផ្សំផ្សេងទៀតទៅតាមពេលវេលា ដោយអាស្រ័យលើតម្រូវការ និងធនធានដែលមាន ហើយអ្នកអាចកំណត់អាទិភាព និងជ្រើសរើសជាតុមួយចំនួនសម្រាប់សាលារៀនរបស់អ្នក។

### ៣.៣ អភិបាលកិច្ចសាលារៀន

យើងចាប់ផ្តើមមើលទៅលើអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៅក្នុងសាលារៀន ក្រោមទស្សនទាននៃភាពជាអ្នកដឹកនាំសាលារៀនល្អ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីសហគមន៍។ អភិបាលកិច្ចល្អ ត្រូវបានអ្នកជំនាញអប់រំភាគច្រើនចាត់ទុកថាជាបុរេលក្ខខណ្ឌសម្រាប់ផ្តល់សេវាអប់រំប្រកបដោយគុណភាពដល់សិស្ស។

**តើអ្វីជាអភិបាលកិច្ចល្អនៅតាមសាលា?**

អភិបាលកិច្ចល្អរួមមានបញ្ញត្តិសំខាន់ៗដូចជា៖ ភាពជាអ្នកដឹកនាំល្អ ការចូលរួមរបស់សហគមន៍ តម្លាភាព កិច្ចសហប្រតិបត្តិការល្អ យុទ្ធសាស្ត្រ ចក្ខុវិស័យសាលារៀន ការទទួលខុសត្រូវ ការប្រើប្រាស់ធនធានប្រកបដោយតម្លាភាព គ្មានអំពើពុករលួយក្នុងសាលារៀន គណនេយ្យភាពការងាររបស់បុគ្គលិកសាលាទាំងអស់ចំពោះមាតាបិតា និងសហគមន៍ ដើម្បីធានានូវសេវាកម្មអប់រំប្រកបដោយគុណភាព។

ការក្លាយជាអ្នកដឹកនាំល្អ និងមានភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព អាចជាចំណុចចាប់ផ្តើមចេញពីអភិបាលកិច្ចល្អនៅសាលា។

**តើភាពជាអ្នកដឹកនាំមានន័យយ៉ាងណាចំពោះអ្នក?**

អ្នកដឹកនាំល្អបំផុសគំនិតឱ្យមនុស្សរីកចម្រើន មានការគាំទ្រ និងថ្លៃប្រឌិត ហើយផ្តល់ការទទួលស្គាល់ចំពោះការរួមចំណែករបស់បុគ្គលិក។ លក្ខណៈទាំងអស់នេះ ចាំបាច់ក្នុងការលើកកម្ពស់កិច្ចសហការ និងការគាំទ្របរិស្ថាននៅក្នុងសាលារៀន។

**តើភាពជាអ្នកដឹកនាំល្អមានទំនាក់ទំនងនឹងគុណភាពនៃការបង្រៀននិងការរៀនយ៉ាងដូចម្តេច?**

ការស្រាវជ្រាវមួយចំនួនបង្ហាញថា ការកែលម្អគុណភាពនៃការបង្រៀន និងរៀនគឺអាស្រ័យទៅលើគុណភាពនៃភាពជាអ្នកដឹកនាំ។ នៅក្នុងគោលនយោបាយសកម្មភាពវិជ្ជាជីវៈគ្រូបង្រៀន ២០២៤-២០៣០ ដែលបានធ្វើបច្ចុប្បន្នភាព កំណត់ចំណុចយុទ្ធសាស្ត្រចំនួន៤ ។ ចំណុចយុទ្ធសាស្ត្រទី២ **គឺការប្រែក្លាយភាពជាអ្នកដឹកនាំ៖** ការប្រែក្លាយភាពជាអ្នកដឹកនាំផ្តោតលើអ្នកដឹកនាំផ្តល់ការអប់រំ តាមរយៈការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អនុវត្តប្រកបដោយភាពច្នៃប្រឌិត និងរួមបញ្ចូលការពង្រឹងស្វ័យភាព ពង្រីក និងលើកកម្ពស់ផលប្រយោជន៍របស់បុគ្គលិក បង្កើតការយល់ដឹង និងការទទួលយកគោលបំណង និងបេសកកម្មនៃការអប់រំ និងជំរុញបុគ្គលិករបស់ពួកគេឱ្យមើលទៅហួសពីខ្លួនឯងដើម្បីជាប្រយោជន៍ដល់អ្នកដែលទទួលផល។ ភាពផ្លាស់ប្រែជាអ្នកដឹកនាំត្រូវបានគាំទ្រតាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។

ខាងក្រោមនេះ គឺជាការសង្ខេបនូវបញ្ញត្តិសំខាន់ៗទាក់ទងនឹងការផ្សារភ្ជាប់គ្នារវាងភាពជាអ្នកដឹកនាំល្អ និងគុណភាពនៃការបង្រៀន និងការរៀន៖

- **ចក្ខុវិស័យ និងគោលដៅ៖** អ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពបង្កើតចក្ខុវិស័យ និងគោលដៅច្បាស់លាស់សម្រាប់ស្ថាប័ន ដោយផ្តល់ទិសដៅ និងគោលបំណងសម្រាប់ការបង្រៀន និងរៀន។
- **កិច្ចគាំទ្រ និងធនធាន៖** អ្នកដឹកនាំល្អផ្តល់ការគាំទ្រ និងធនធានចាំបាច់ដល់គ្រូ និងសិស្សអនុញ្ញាតឱ្យពួកគេចែកចាយ និងចូលរួមក្នុងការបង្រៀននិងការរៀនប្រកបដោយគុណភាពខ្ពស់។
- **ការសហការ និងសហគមន៍សិក្សាវិជ្ជាជីវៈ៖** អ្នកដឹកនាំជំរុញឱ្យមានវប្បធម៌នៃការសហការគ្នាក្នុងចំណោមគ្រូបង្រៀន លើកទឹកចិត្តឱ្យមានការចែករំលែកការអនុវត្តប្រសើរ និងបង្កើនវិជ្ជាជីវៈជួយពង្រឹងយុទ្ធសាស្ត្របង្រៀន និងការអភិវឌ្ឍកម្មវិធីសិក្សា។
- **គណនេយ្យភាព និងការវាយតម្លៃ៖** អ្នកដឹកនាំបង្កើតប្រព័ន្ធសម្រាប់គណនេយ្យភាព និងការវាយតម្លៃ កំណត់ការរំពឹងទុកសម្រាប់គ្រូបង្រៀន ការផ្តល់មតិកែលម្អ និងការប្រើប្រាស់ទិន្នន័យដើម្បីកែលម្អការបង្រៀន និងការរៀនជាប្រចាំ។
- **វប្បធម៌សាលាវិជ្ជមាន៖** អ្នកដឹកនាំល្អបង្កើតវប្បធម៌សាលាប្រកបដោយភាពវិជ្ជមាន ជំរុញឱ្យមានសេចក្តីស្រឡាញ់ចំពោះការសិក្សា បរិយាបន្ន និងការគោរពគ្នាទៅវិញទៅមក បង្កើតបរិយាកាសអំណោយផលដល់ការបង្រៀន និងការសិក្សាប្រកបដោយប្រសិទ្ធភាព។

ជាការកត់សម្គាល់ ទោះបីជាការដឹកនាំល្អមានសារៈសំខាន់ក៏ដោយ ក៏នៅមានកត្តាផ្សេងទៀតដូចជា ជំនាញគ្រូ ការរចនាកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សនិងការចូលរួមរបស់មាតាបិតា ក៏រួមចំណែកដល់គុណភាពអប់រំទាំងមូលផងដែរ។

## ៣.៤ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព

*"សាលាដែលមានភាពខ្លាំង គេប្រើធនធានជាយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវការផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ និងជួយបង្កើនលទ្ធផលសិក្សារបស់សិស្ស"*

ការប្រើប្រាស់ធនធានក្នុងសាលាប្រកបដោយប្រសិទ្ធភាព រួមចំណែកក្នុងការផ្តល់នូវការបង្រៀន និងការរៀនប្រកបដោយគុណភាព។ ប៉ុន្តែតើធនធានរបស់សាលាមានអ្វីខ្លះ?

ខាងក្រោមនេះគឺជាប្រភេទធនធានផ្សេងៗដែលមាននៅក្នុងសាលា និងក្នុងសហគមន៍៖

- ធនធានរូបវន្ត៖ សៀវភៅ សម្ភារៈបង្រៀន និងសិក្សា បន្ទប់ពិសោធន៍ បណ្ណាល័យ ហេដ្ឋារចនាសម្ព័ន្ធ
- ធនធានមនុស្ស៖ គ្រូបង្រៀន នាយក បុគ្គលិករដ្ឋបាល (i/e. បណ្ណារក្ស) សហគមន៍
- ធនធានហិរញ្ញវត្ថុ៖ មូលនិធិ ផែនការកែលម្អយុទ្ធសាស្ត្រ ការផ្តល់មូលនិធិពីភ្នាក់ងារខាងក្រៅ ការបរិច្ចាគរបស់សហគមន៍

ធនធានយុទ្ធសាស្ត្រគឺជាការរៀបចំគោលដៅនៃធនធាន ឱ្យត្រូវនឹងគំនិតផ្តួចផ្តើមរបស់សាលារៀន ដើម្បីធានាបាននូវផលឥទ្ធិពលជាអតិបរមាលើលទ្ធផលសិក្សារបស់សិស្ស។

ការរៀបចំផែនការកែលម្អសាលារៀន ហៅកាត់ថា (SIP) របស់សាលារៀន នឹងជួយកំណត់អំពីតម្រូវការបុគ្គលិកសាលា និងធនធានផ្សេងទៀតដែលត្រូវការដើម្បីសម្រេចបាននូវឥទ្ធិពលដែលចង់បាន។ សាលារៀនរបស់អ្នកគួរតាមដាននិងកែតម្រូវការបែងចែកធនធានជាប្រចាំដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការកែលម្អសាលារៀន(SIP)។

### តើការប្រើប្រាស់ធនធានមានប្រសិទ្ធភាពមានន័យយ៉ាងណា?

ខាងក្រោមគឺជាបញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន និងជាឯកសារយោងដែលសាលារៀនអាចប្រើប្រាស់ដើម្បីពិនិត្យមើលថា ខ្លួនបានបំពេញគ្រប់ដំណាក់កាលដើម្បីត្រួតពិនិត្យធនធានរបស់ពួកគេ។

### ៣.៥ បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន

**សេចក្តីណែនាំ៖** សូមប្រើបញ្ជីត្រួតពិនិត្យនេះ ដើម្បីធានាថាសាលារៀនបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវធនធានរបស់ខ្លួន ដើម្បីគាំទ្រដល់ការរៀនសូត្រ និងសមិទ្ធផលការសិក្សារបស់សិស្ស។

**តារាងត្រួតពិនិត្យ**

| ល. | បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន | រួចរាល់ | បន្ត | មិនទាន់ធ្វើ |
|---|---|---|---|---|
| ១ | **ធ្វើការវាយតម្លៃតម្រូវការដែលពាក់ព័ន្ធនឹងគ្រូ ឪពុកម្តាយ និងសហគមន៍៖** | | | |
| | ចូលរួមជាមួយភាគីពាក់ព័ន្ធក្នុងការកំណត់តម្រូវការធនធានជាក់លាក់របស់សាលា។ | | | |
| | ពិចារណាលើកត្តាមួយចំនួនដូចជា ចំនួនសិស្ស តម្រូវការកម្មវិធីសិក្សា ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា និងការអភិវឌ្ឍបុគ្គលិក។ | | | |
| ២ | **បង្កើតថវិកាដោយផ្អែកលើតម្រូវការដែលបានកំណត់ និងកំណត់អាទិភាពធនធានសម្រាប់ផលប៉ះពាល់ជាអតិបរមាលើការសិក្សារបស់សិស្ស៖** | | | |
| | បង្កើតថវិកាជាក់ស្តែងស្របតាមតម្រូវការដែលបានកំណត់។ | | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | |
|---|---|---|---|---|
| | ចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការរៀបចំផែនការថវិកា។ | | | |
| | ផ្តល់អាទិភាពដល់ធនធានដោយផ្អែកលើផលប៉ះពាល់សក្តានុពលរបស់ពួកគេលើលទ្ធផលសិក្សារបស់សិស្ស។ | | | |
| ៣ | **បែងចែកធនធានដោយស្មើភាព គិតពីតម្រូវការផ្សេងៗគ្នារបស់សិស្ស ៖** | | | |
| | ចែកចាយធនធានដោយសមធម៌ ដើម្បីដោះស្រាយតម្រូវការចម្រុះរបស់សិស្ស។ | | | |
| | ផ្តល់ការគាំទ្របន្ថែមសម្រាប់សិស្សដែលជួបការលំបាក រួមទាំងអន្តរាគមន៍ និងជំនួយតាមគោលដៅ។ | | | |
| | ផ្តល់ឱកាសបន្ថែមសម្រាប់សិស្សដែលទទួលបានជោគជ័យខ្ពស់ក្នុងការបន្តការសិក្សារបស់ពួកគេ។ | | | |
| ៤ | **ប្រើទិន្នន័យដូចជា ពិន្ទុតេស្ត និងការចូលរួម ដើម្បីកំណត់អាទិភាពនៃការបែងចែកធនធាន៖** | | | |
| | វិភាគទិន្នន័យសមិទ្ធផលរបស់សិស្សឱ្យទៀងទាត់ និងរង្វាស់ពាក់ព័ន្ធផ្សេងទៀត។ | | | |
| | កំណត់ផ្នែកដែលត្រូវការធនធានបន្ថែម ឬអន្តរាគមន៍ | | | |
| | ដឹកនាំធនធានទៅកាន់តំបន់ដែលមានតម្រូវការ និងសក្តានុពលបំផុតសម្រាប់ការកែលម្អ។ | | | |
| | វិភាគទិន្នន័យសមិទ្ធិផលរបស់សិស្សទៀងទាត់ និងរង្វាស់ដែលពាក់ព័ន្ធផ្សេងទៀត។ | | | |
| ៥ | **បង្កើតភាពជាដៃគូជាមួយធុរកិច្ច និងអង្គការក្នុងស្រុក ដើម្បីចូលប្រើធនធាន និងជំនួយបន្ថែម៖** | | | |
| | សហការជាមួយអង្គការខាងក្រៅ អាជីវកម្ម និងអ្នកពាក់ព័ន្ធសហគមន៍។ | | | |
| | ស្វែងរកការបរិច្ចាគ ជំនួយ ឬការឧបត្ថម្ភ ដើម្បីបង្កើនមូលដ្ឋានធនធានរបស់សាលា។ | | | |
| | ប្រើប្រាស់ធនធានសហគមន៍ ដើម្បីផ្តល់ឱកាសសិក្សាតែមួយគត់សម្រាប់សិស្ស | | | |
| ៦ | **ផ្តល់ឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន ដើម្បីបង្កើនជំនាញរបស់ពួកគេ និងបង្កើនការប្រើប្រាស់ធនធាន៖** | | | |
| | ផ្តល់ជូនកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈដែលកំពុងដំណើរការ ស្របតាមតម្រូវការដែលបានកំណត់។ | | | |
| | ផ្តោតលើការអនុវត្តការបង្រៀន ការរួមបញ្ចូលបច្ចេកវិទ្យា និងផ្នែកផ្សេងទៀតនៃការរីកចម្រើន។ | | | |
| | ផ្តល់អំណាចដល់គ្រូបង្រៀនក្នុងការប្រើប្រាស់ធនធានដែលមាន ប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការរៀនសូត្ររបស់សិស្ស។ | | | |
| ៧ | **ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីសម្រួលការងាររដ្ឋបាល និងលើកកម្ពស់ការបង្រៀន និងរៀន៖** | | | |
| | កំណត់ដំណោះស្រាយបច្ចេកវិទ្យាដែលមានប្រសិទ្ធភាពចំណាយសម្រាប់ការងាររដ្ឋបាល។ | | | |

| | | | | |
|---|---|---|---|---|
| | ស្វែងរកឧបករណ៍បច្ចេកវិទ្យាអប់រំ ដើម្បីគាំទ្រការបង្រៀន និងស្វ័យសិក្សា។ | | | |
| | ធានាថា គ្រូបង្រៀន និងសិស្សមានលទ្ធភាពទទួលបានធនធានបច្ចេកវិទ្យាសមស្រប។ | | | |
| ៨ | **អនុវត្តផែនការថែទាំយ៉ាងសកម្ម ដើម្បីធានាសុវត្ថិភាព និងភាពជាប់បានយូរនៃហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍សាលារៀន៖** | | | |
| | បង្កើតកាលវិភាគថែទាំសម្រាប់ការត្រួតពិនិត្យ ជួសជុល និងកែលម្អជាប្រចាំ។ | | | |
| | ផ្តល់អាទិភាពដល់វិធានការសុវត្ថិភាពក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធ។ | | | |
| | រក្សាឧបករណ៍និងគ្រឿងបរិក្ខារមានសណ្តាប់ធ្នាប់ល្អ ដើម្បីជៀសវាងការរំខាន។ | | | |
| ៩ | **តាមដាន និងវាយតម្លៃជាប្រចាំនូវប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគ្រប់គ្រងធនធាន និងធ្វើការកែតម្រូវតាមតម្រូវការ៖** | | | |
| | បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃការបែងចែកធនធាន និងការប្រើប្រាស់។ | | | |
| | ប្រមូលមតិកែលម្អពីគ្រូបង្រៀន សិស្សានុសិស្ស និងមាតាបិតាអំពីផលប៉ះពាល់នៃធនធាន។ | | | |
| | ប្រើលទ្ធផលវាយតម្លៃដើម្បីជូនដំណឹងដល់ការសម្រេចចិត្ត និងធ្វើការកែតម្រូវចាំបាច់។ | | | |

### ៣.៦ ការចូលរួមសហគមន៍

*«នៅពេលដែលសាលាសហការគ្នារៀបចំផែនការ អនុវត្តសកម្មភាពចូលរួមរបស់សហគមន៍ និងមាតាបិតាសិស្ស ធ្វើជាយុទ្ធសាស្ត្រឈានមុខ នោះសាលានឹងទទួលបានអត្ថប្រយោជន៍ និងរួមចំណែកផ្តល់នូវចំណេះដឹង បទពិសោធ សមត្ថភាព និងបណ្តាញគ្រួសារដល់ក្រុមគ្រួសារទាំងនោះវិញ។ សរុបមក នេះគឺជាការជំរុញការសិក្សាពេញមួយជីវិត និងការពង្រឹងសហគមន៍»*[1]

ការចូលរួមរបស់សហគមន៍គឺជាធាតុសំខាន់មួយដើម្បីកែលម្អសាលារៀន និងធានាឱ្យមានការសិក្សាកាន់តែប្រសើរឡើងសម្រាប់សិស្ស។ តាមពិតសហគមន៍អាចគាំទ្រសាលារៀនតាមរបៀបផ្សេងៗ។

ថ្នាក់ដឹកនាំសាលា និងសមាជិកសហគមន៍សន្ទនា និងស្តាប់សមាជិកសហគមន៍។ ⟷ សហគមន៍ចូលរួមក្នុងសកម្មភាពដើម្បីធ្វើឱ្យសាលារៀននិងការសិក្សាកាន់តែប្រសើរ។

[1] ដកស្រង់ពី “Key Driver of Leadership Effectiveness: Community Engagement” , NSW Department of Education © 2022 NSW Department of Education - School Leadership Institute.



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទាំងសាលារៀន និងសហគមន៍អាចទទួលបានអត្ថប្រយោជន៍ពីទំនាក់ទំនងរបស់ពួកគេ។ ខាងក្រោមនេះគឺមូលហេតុសំខាន់ៗនៃការចូលរួមរបស់សហគមន៍ដែលមានប្រយោជន៍ទាំងសាលារៀន និងសហគមន៍៖

- កសាងទំនុកចិត្ត និងទំនាក់ទំនងគាំទ្រ
- គាំទ្រការអប់រំដល់កុមារ និងយុវជនទាំងអស់
- នាំសហគមន៍រួមគ្នាជួយសាលារៀន
- ជួយស្វែងរកមធ្យោបាយដើម្បីរក្សាសុវត្ថិភាពសិស្ស និងគ្រូ និង
- គាំទ្រការសិក្សារបស់សិស្ស។

តើយើងកសាងទំនុកចិត្តជាមួយសហគមន៍ដោយរបៀបណា?

ការជឿទុកចិត្តអាចជាជំហានដំបូងក្នុងការបង្កើតទំនាក់ទំនងណាមួយ ហើយទំនាក់ទំនងរវាងសាលារៀន និងសហគមន៍មិនមែនជាករណីលើកលែងនោះទេ។ ខាងក្រោមនេះគឺជាហេតុផលមួយចំនួនដែលបង្កើតការទុកចិត្ត និងការមិនទុកចិត្តគ្នា៖

| ការទុកចិត្ត | ការមិនទុកចិត្ត |
|---|---|
| ស្តាប់ដោយយកចិត្តទុកដាក់ | មិនស្តាប់ |
| រក្សាការសន្យារបស់គាត់ | មិនរក្សាការសន្យា |
| សកម្មភាពត្រូវនឹងពាក្យ | មិនធ្វើដូចដែលនិយាយ |
| ទុកជាឯកជន | គ្មានឯកជនភាពទេ |
| តម្លាភាព | មិនច្បាស់លាស់/មិនតម្លាភាពក្នុងសកម្មភាព |

គេត្រូវការពេលវេលាដើម្បីកសាងទំនុកចិត្ត ហើយចំណុចនេះកើតឡើងលុះត្រាតែទាំងនាយកសាលា គ្រូបង្រៀន និងសហគមន៍អនុវត្តសកម្មភាពសមស្របមួយចំនួន។ ការធ្វើបែបនេះមានសុពលភាពនៅគ្រប់ប្រភេទទំនាក់ទំនងទាំងអស់ ហើយសហគមន៍មិនមែនជាករណីខុសពីគេនោះទេ។

## ៤. គណៈកម្មការដឹកនាំ និងគណៈកម្មការបច្ចេកទេសការអនុវត្តស្តង់ដា

គណៈកម្មការដឹកនាំនិងគណៈកម្មការបច្ចេកទេសការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ ប្រចាំតំបន់ និងប្រចាំខេត្ត ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេច លេខ ៤៦ អយក.សសរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២៣ ដែលមានសមាសភាពជាថ្នាក់ដឹកនាំក្រសួង ប្រធានអង្គភាព

ចំណុះទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងតំណាងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលាមធ្យមសិក្សាចំណេះទូទៅគោលដៅច្បាស់លាស់សម្រាប់ជាជំនួយការបច្ចេកទេសរបស់ក្រសួង អប់រំ យុវជន និងកីឡា និងអនុវត្តដំណើរការការងាររបស់ខ្លួនក្រោមការដឹកនាំរបស់ប្រធាននៃគណៈកម្មការនីមួយៗ។ ខាងក្រោមនេះ ជាតួនាទីនិងភារកិច្ចរបស់គណៈកម្មការនីមួយៗ៖

### ៤.១ គណៈកម្មការដឹកនាំ

គណៈកម្មការដឹកនាំការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំការអនុវត្តស្តង់ដាគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- ដាក់ចេញវិធានការគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- កំណត់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ តាមសំណើរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- លើកសំណើប្រកាសទទួលស្គាល់ជាស្តង់ដាគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូដាក់ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ស្តីពី ការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ និងកិច្ចសហការផ្សេងៗ ដើម្បីផ្តល់អនុសាសន៍ និងលើកសំណើដំណោះស្រាយពាក់ព័ន្ធនឹងការវាយតម្លៃស្តង់ដាគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាពិនិត្យ និងសម្រេច
- ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងអប់រំ យុវជន និងកីឡាប្រគល់ជូន។

### ៤.២ គណៈកម្មការបច្ចេកទេស

គណៈកម្មការបច្ចេកទេសអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូត្រូវបានបែងចែកក្រុមការងារជាប្រាំតំបន់ដើម្បីមានភាពងាយស្រួលដល់ការងារគ្រប់គ្រងដឹកនាំនិងចុះអន្តរាគមន៍ដូចខាងក្រោម៖

- **តំបន់១៖** ខេត្តបាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ បន្ទាយមានជ័យ ប៉ៃលិននិងខេត្តឧត្តរមានជ័យ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **តំបន់២៖** ខេត្តកោះកុង ព្រះសីហនុ កំពត កែប និងខេត្តតាកែវ
- **តំបន់៣៖** ខេត្តកណ្តាល ស្វាយរៀង ត្បូងឃ្មុំ រតនគិរី និងខេត្តមណ្ឌលគិរី
- **តំបន់៤៖** ខេត្តកំពង់ស្ពឺ កំពង់ចាម ក្រចេះ ស្ទឹងត្រែង និងរាជធានីភ្នំពេញ
- **តំបន់៥៖** ខេត្តព្រៃវែង កំពង់ធំ ព្រះវិហារ និងខេត្តសៀមរាប។

***ឧបសម្ព័ន្ធទី ៣៖*** *ប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូ និងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគណៈកម្មការបច្ចេកទេសការអនុវត្តស្តង់ដា សាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ*

មានតួនាទី និងភារកិច្ចដូចតទៅ៖

- ចូលរួមសម្របសម្រួលអនុវត្តផ្ទាល់នូវគោលនយោបាយក្របខ័ណ្ឌកម្មវិធីផែនការយុទ្ធសាស្ត្រ ដើម្បីប្រែក្លាយជាស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- ចូលរួមដឹកនាំ និងសហការជាមួយបុគ្គលិកអប់រំនៅកម្រិតគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ ដើម្បីរៀបចំបច្ចេកទេសអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- រៀបចំផែនការសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ លើការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- វាយតម្លៃផលប៉ះពាល់ និងធ្វើរបាយការណ៍ស្តីពីយន្តការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ ជូនគណៈកម្មការដឹកនាំគ្រប់គ្រងវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលគណៈកម្មការដឹកនាំគ្រប់គ្រងវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូប្រគល់ជូន។

### ៤.៣ លេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំ

លេខាធិការដ្ឋាន នៃគណៈកម្មការដឹកនាំការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសម្របសម្រួលកិច្ចប្រជុំ និងសិក្ខាសាលាពាក់ព័ន្ធការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- រៀបចំ និងរក្សាទុកដាក់ឯកសារ កំណត់ហេតុ និងរបាយការណ៍នៃកិច្ចប្រជុំនានា
- សម្របសម្រួលយន្តការអនុវត្តរបស់គណៈកម្មការដឹកនាំគ្រប់គ្រងអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- បូកសរុបរបាយការណ៍ស្តីពីវឌ្ឍនភាពនៃដំណើរអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានគណៈកម្មការដឹកនាំការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ ប្រគល់ជូន។

## ៥. ក្រុមគ្រូបង្គោល

ក្រុមគ្រូបង្គោលត្រូវបានបង្កើតឡើងក្រោមការដឹកនាំ គាំទ្រ និងណែនាំពីក្រុមការងារដឹកនាំ និងក្រុមការងារ បច្ចេកទេស យោងតាមលិខិតឧទ្ទេសនាមលេខ៦៣៨ អយក.ឧទន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារដឹកនាំ ក្រុមការងារបច្ចេកទេស និងក្រុមគ្រូបង្គោល ដើម្បីជួយវិទ្យាល័យធនធាន និងបណ្តាញ ក្នុងការអនុវត្តស្តង់ដាសាលារៀនគំរូ តាមរយៈការជួយបង្វឹក និងគាំទ្រដល់ក្រុមការងារ ថ្នាក់តំបន់ និងថ្នាក់រាជធានី ខេត្ត ដោយមានសមាសភាពចម្រុះមកពីនាយកដ្ឋានជំនាញពាក់ព័ន្ធ វិទ្យាស្ថានជាតិអប់រំ និងនាយកសាលា ដែលមានបទពិសោធក្នុងការអនុវត្តជោគជ័យការគ្រប់គ្រងតាមសាលារៀន នៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP II) និងយុទ្ធសាស្ត្រសហគមន៍សាលារៀននៃគម្រោងកែលម្អវិស័យអប់រំទូទៅ (GEIP)។

### ៥.១ សមាសភាពក្រុមគ្រូបង្គោល

- តំណាងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- តំណាងនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
- តំណាងនាយកដ្ឋានធានាគុណភាពអប់រំ
- តំណាងនាយកដ្ឋានបុគ្គលិក



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តំណាងនាយកដ្ឋានហិរញ្ញវត្ថុ
- នាយកដ្ឋានគោលនយោបាយ
- នាយកដ្ឋានផែនការ
- តំណាងវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាគរុកោសល្យ និងវិក្រឹតការភូមិភាគ និងខេត្ត
- គ្រូប្រឹក្សាគរុកោសល្យ
- គ្រូប្រឹក្សាសាលារៀន នៃកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការប្រឹក្សា
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ទូតសុធន្នៈស្ទែម (STEM Ambassadors)
- នាយកសាលារៀនល្អ
- តំណាងមន្ទីរ អយក.ខេត្ត (ទាំង២៥រាជធានីខេត្ត) មានការិយាល័យមធ្យមសិក្សា ចំណេះទូទៅ ការិយាល័យអធិការកិច្ច ការិយាល័យផែនការ ការិយាល័យយុវជនជាដើម។
- នាយក នាយករង សាលារៀនល្អ
- គ្រូបង្រៀនល្អ និង
- ក្រុមការងារ IT Team។

## ៥.២ ភារកិច្ចរបស់ក្រុមគ្រូបង្គោល

- ទទួលការណែនាំពីក្រុមការងារដឹកនាំ និងក្រុមការងារបច្ចេកទេសអំពីយន្តការ និងកិច្ចការគាំទ្រសាលារៀន
- ចុះពិនិត្យតាមដានសាលារៀនគោលដៅ និងកំណត់ឱ្យឃើញច្បាស់នូវផ្នែកជួយគាំទ្រសាលារៀន
- ជួយគាំទ្រឱ្យសាលារៀនគោលដៅ ឱ្យមានឯកសារគ្រប់សម្រាប់អនុវត្តកម្មវិធីសាលារៀនមានប្រសិទ្ធភាព
- រៀបចំកម្មវិធីជួយគាំទ្រសាលារៀន និងមានកិច្ចព្រមព្រៀងលទ្ធផល និង
- រៀបចំរបាយការណ៍លទ្ធផលការងារតាមត្រីមាស ឆមាស និងប្រចាំឆ្នាំ។

## ៥.៣ សមាសភាពក្រុមគ្រូបង្គោលនៅថ្នាក់សាលារៀន

ក្រុមគ្រូបង្គោលនៅសាលារៀន

- មន្ទីរអេយក.រាជធានី ខេត្ត គាំទ្រការអនុវត្ត
- មន្ទីរអេយក.រាជធានី ខេត្ត ត្រូវចុះកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយក្រសួងអយក
- បង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) តាមសាលារៀនប្រើយន្តការក្រុមគ្រូមុខវិជ្ជាទាំង ១០ និងគ្រូបង្គោលតាមសាលារៀន និងអាចបន្ថែមសមាជិកមកពី៖ វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គ្រូប្រឹក្សាសាលារៀននៃកម្មវិធីមគ្គុទេសក៍អាជីពនិងការប្រឹក្សា ទូតសុធន្ធៈស្ទែម (STEM Ambassadors)នាយកសាលារៀនល្អ គ្រូល្អនៅតាមសាលារៀន និងប្រធានក្រុមបច្ចេកទេសនៅតាមសាលារៀន។

## ៦. យន្តការចុះជួយគាំទ្រដល់សាលាគោលដៅ

### ៦.១ ការចុះជួយគាំទ្រសាលារៀនផ្ទាល់

ការជួយគាំទ្រដល់សាលារៀន អនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូ គឺជាសកម្មភាពដែលត្រូវអនុវត្តជាប់ជាប្រចាំដើម្បីពង្រឹងស្វ័យភាពនិងភាពជាម្ចាស់របស់សាលារៀន និងសហគមន៍ក្នុងការកែលម្អសាលារៀនជាប់ជាប្រចាំ បំពេញបានពេញលេញ និងជោគជ័យស្តង់ដាសាលាមធ្យមសិក្សាគំរូទាំង៥ស្តង់ដា និង៨៣សូចនាករ តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ការទំនាក់ទំនង និងកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ នៅកម្រិតសាលារៀន និងសហគមន៍។ ការជួយគាំទ្រសាលារៀនអាចអនុវត្តបានជាប្រចាំតាមរយៈការចុះជួយដោយផ្ទាល់ និងជួយតាមប្រព័ន្ធអនឡាញ។

ការចុះជួយគាំទ្រដោយផ្ទាល់ដល់សាលារៀន អនុវត្តដោយក្រុមការងារប្រចាំតំបន់ទាំង៥ រួមជាមួយមន្ទីរ អយក.រាជធានី ខេត្ត ដើម្បីជួយគាំទ្រការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូ។ ក្រុមការងារចុះជួយគាំទ្រសាលារៀន ជាក្រុមការងារចម្រុះសមាសភាព និងជំនាញឆ្លើយតបបានពេញលេញនូវតម្រូវការរបស់សាលារៀនដូចជា ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ រដ្ឋបាល និងផែនការសាលារៀន ការគ្រប់គ្រងការរៀននិងបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស ការរៀបចំផែនការបង្រៀន ការធ្វើអធិការកិច្ចថ្នាក់រៀន ការពង្រឹងការអប់រំ STEM ការប្រើប្រាស់បន្ទប់ពិសោធន៍ បន្ទប់ ICT បណ្ណាល័យ មគ្គុទេសក៍អាជីពនិងការផ្តល់ការប្រឹក្សា កម្មវិធីក្រៅម៉ោង ដើម្បីពង្រឹងបំណិនវិន័យ សីលធម៌ដល់សិស្សជាដើម។

មុនពេលចុះគាំទ្រសាលាគោលដៅនីមួយៗ ក្រុមគ្រូបង្គោល និងក្រុមការងារតាមតំបន់ទាំង៥ ត្រូវកំណត់ឱ្យបាននូវចំណុចខ្លាំង និងចំណុចខ្សោយរបស់សាលា ដើម្បីរៀបចំផែនការសមិទ្ធកម្ម ឬផែនការចុះជួយគាំទ្រ បង្វឹក ដើម្បីឆ្លើយតបទៅនឹងតម្រូវរបស់សាលា។ ការចុះជួយគាំទ្រសាលារៀនត្រូវធានាឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធរួមទាំង ក្រុមការងារទទួលបន្ទុកតាមរាជធានី ខេត្តគោលដៅ



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ក្នុងតំបន់នីមួយៗ ដោយធានាថា ៥ឆ្នាំក្រោយ សាលានឹងមានស្វ័យភាព និងនិរន្តរភាព អាចដើរបាន ដោយខ្លួនឯងក្នុងការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូជាមួយការគាំទ្រតិចតួចពីក្រុមគ្រូបង្គោល និង ក្រុមការងារតាមតំបន់ជាមួយនឹងការគាំទ្រកាន់តែប្រសើរ និងមានប្រសិទ្ធភាពពីមន្ទីរអយក.រាជធានី ខេត្ត និងការិយាល័យ អយក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**របៀបជួយគាំទ្រសាលារៀន**

- **ផ្តល់ឯកសារគាំទ្រ និងឧបករណ៍នានា**
- **ពន្យល់ និងណែនាំអំពីរបៀបអនុវត្ត (តាមអនឡាញ និងដោយផ្ទាល់)៖**
  - **របៀបទី១៖** ក្រុមការងារបង្វឹក បង្ហាញគំរូឧទាហរណ៍ជាក់ស្តែងដល់គណៈគ្រប់គ្រង និង អ្នកពាក់ព័ន្ធនៅសាលារៀន (កិច្ចការថ្មី ដែលសាលារៀនមិនធ្លាប់បានអនុវត្តកន្លងមក) (អនឡាញ ឬដោយផ្ទាល់)
  - **របៀបទី២៖** ចំពោះកិច្ចការណាដែលសាលារៀនបានធ្វើនិងអនុវត្តកន្លងមកក្នុងកម្រិតណាមួយ ប៉ុន្តែសាលារៀនមិនដឹងច្បាស់ថា កិច្ចការនោះត្រឹមត្រូវកម្រិតណា។ កិច្ចការប្រភេទនេះ ក្រុម បង្វឹក ត្រូវធ្វើការកែលម្អកិច្ចការនោះជាមួយសាលា (អនឡាញ ឬដោយផ្ទាល់)
  - **របៀបទី៣៖** សាលាអាចធ្វើកិច្ចការ ដោយខ្លួនឯងកន្លងមកបានត្រឹមត្រូវគួរសមហើយក្រុមបង្វឹក ត្រូវពិនិត្យនិងសង្កេតមើលអំពីរបៀបនិងដំណើរការនៃការធ្វើសកម្មភាពតាមលំដាប់លំដោយ។ (អនឡាញ ឬដោយផ្ទាល់)
  - **របៀបទី៤៖** សាលារៀន អាចធ្វើកិច្ចការបានដោយខ្លួនឯងប្រកបដោយគុណភាព។ ក្រុម ការងារ ពិនិត្យ ផ្ទៀងផ្ទាត់ឯកសារ ទិន្នន័យ ព័ត៌មាន ភស្តុតាង ជាលទ្ធផល។ (អនឡាញ ឬ ដោយផ្ទាល់)

នៅរាល់ពេលក្រុមការងារថ្នាក់តំបន់ចុះជួយតាមសាលាគោលដៅក្នុងខេត្តណា ត្រូវធានាថា មាន ការចូលរួមពីប្រធាន ឬអនុប្រធានមន្ទីរ ឬមន្ត្រីបង្គោលមន្ទីរអយក.រាជធានី ខេត្ត ការិយាល័យអយក. នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលា លេខាធិការ រដ្ឋបាល ហេរញ្ញិក និងលោកគ្រូអ្នកគ្រូនៃសាលាមធ្យមសិក្សា ដើម្បីចូលរួមអនុវត្តផ្ទាល់ជាមួយគ្នា។ របៀបវារៈ គោលបំណង និងលទ្ធផលរំពឹងទុក ត្រូវកំណត់ច្បាស់លាស់ទៅតាមជំហានៗ និងតម្រូវការជាក់ស្តែងរបស់ សាលារៀននៅក្នុងឯកសារទស្សនទាន ស្របតាមផែនការសកម្មភាព និងសូចនាករសមិទ្ធកម្មគន្លឹះ ក្នុង នោះក្រុមការងារថ្នាក់តំបន់ និងថ្នាក់រាជធានី ខេត្ត ត្រូវធានាថា សាលាមធ្យមសិក្សាយ៉ាងហោចណាស់

ទទួលបានការចុះជួយគាំទ្រ និងការជួយអនុវត្តជាក់ស្តែងចំនួន៣ដងក្នុងមួយឆ្នាំសិក្សា ដោយការចុះជួយគាំទ្រនិងការអនុវត្តជាក់ស្តែងនៅសាលាមធ្យមសិក្សាគោលដៅនិងសាលាមធ្យមសិក្សាបណ្តាញចំណុះ ចូលរួម ដើម្បីពួកគាត់មានឱកាសផ្លាស់ប្តូរយោបល់ ចែករំលែកបទពិសោធ រៀនសូត្រលើឧត្តមានុវត្តន៍ និងអនុវត្តរួមគ្នាលើការបំពេញឯកសារស្តង់ដាសាលារៀនគំរូ និងការកសាងឯកសារគាំទ្រនានាសម្រាប់សូចនាករទាំង៨៣។ បន្ទាប់ពីការចុះជួយតាមខេត្ត និងសាលាគោលដៅ ក្រុមការងារថ្នាក់តំបន់ត្រូវរៀបចំឱ្យមានរបាយការណ៍ ទៅតាមទម្រង់របាយការណ៍ដែលបានផ្តល់ជូន រួមទាំងផែនការដែលត្រូវអនុវត្តបន្តឆ្លើយតបបានតាមតម្រូវការជាក់ស្តែងរបស់សាលាគោលដៅ ជូនទៅលេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំការអនុវត្ត ស្តង់ដាសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈគំរូ។

ក្រុមការងារថ្នាក់តំបន់នីមួយៗត្រូវមានមន្ត្រីបង្គោល១នាក់ ដើម្បីជួយការសម្របសម្រួលជាមួយគ្រប់អ្នកពាក់ព័ន្ធ ការងាររដ្ឋបាល និងភស្តុភារ រួមទាំងការរៀបចំផែនការសកម្មភាព ការជួយរៀបចំកិច្ចប្រជុំទៅតាមផែនការ កាលវិភាគ និងធ្វើកំណត់ហេតុប្រជុំ និងរបាយការណ៍ជាដើម។

### ៦.២ ការជួយគាំទ្រសាលារៀនគោលដៅតាមរយៈការជួបប្រជុំតាមប្រព័ន្ធអនឡាញ

បន្ថែមលើការចុះជួយគាំទ្រ ដោយផ្ទាល់ទៅតាមតំបន់នីមួយៗ យ៉ាងហោចណាស់៣ដង ក្នុងមួយឆ្នាំសិក្សា ក៏ត្រូវមានការជួបប្រជុំតាមប្រព័ន្ធអនឡាញ។ ក្រុមការងារថ្នាក់តំបន់ និងរាជធានីខេត្តនីមួយៗត្រូវរៀបចំឱ្យមានកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាទៀងទាត់ យ៉ាងហោចណាស់១ ទៅ២ ដងក្នុង១ខែជាមួយរបៀបវារៈ និងលទ្ធផលរំពឹងទុកជាក់លាក់ចេញពីកិច្ចប្រជុំនីមួយៗ និងមានធ្វើកំណត់ហេតុច្បាស់លាស់សម្រាប់គាំទ្របន្ត។ កិច្ចប្រជុំតាមអនឡាញផ្តោតជាពិសេសទៅលើការពិនិត្យ វឌ្ឍនភាព និងគាំទ្រជាប់ជាប្រចាំ។ សម្រាប់ពេលវេលាសម្រាប់កិច្ចប្រជុំតាមអនឡាញ អាចបត់បែនបានតាមភាពជាក់ស្តែងសមស្រប ដើម្បីធានាបានការចូលរួម និងប្រសិទ្ធភាព។ អ្នកចូលរួម៖ មន្ត្រីបង្គោលមន្ទីរ អយក. រាជធានី ខេត្ត ការិយាល័យ អយក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលាមធ្យមសិក្សាគោលដៅ ត្រូវចូលរួមចែករំលែក និងអនុវត្តផ្ទាល់ជាមួយគ្នាក្នុងការបំពេញសូចនាករ នៃស្តង់ដាសាលាមធ្យមសិក្សាគំរូ។ កិច្ចប្រជុំនីមួយៗ ត្រូវសង្ខេបឱ្យខ្លីខ្លឹមតាមតែអាចធ្វើទៅបាន ដើម្បីកុំឱ្យរំខានដល់ម៉ោងការងាររបស់អ្នកចូលរួម។ ការអញ្ជើញអ្នកចូលរួមត្រូវធ្វើឡើងយ៉ាងហោចណាស់ ៣ថ្ងៃមុន កាលបរិច្ឆេទនៃការប្រជុំរួមជាមួយនឹងរបៀបវារៈ និងការផ្តល់លីងតំណភ្ជាប់សម្រាប់អ្នកចូលរួម។ ការជួយគាំទ្រសាលារៀនក៏ត្រូវធ្វើផងដែរតាមប្រព័ន្ធតេលេក្រាម ទូរស័ព្ទជាក្រុមឬតាមសាលារៀនអាស្រ័យស្ថានភាព និងសេចក្តីត្រូវការរបស់សាលារៀន ធានាបានប្រសិទ្ធភាព ប្រសិទ្ធផល និងភាពឆ្លើយតប។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

វឌ្ឍនភាព និងទិន្នន័យសាលារៀនរួមទាំងឯកសារគាំទ្រនានារបស់សាលារៀន ត្រូវបានបញ្ចូលជាប់ជាប្រចាំក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលារៀន។

## ៧. គោលការណ៍ណែនាំប្រតិបត្តិក្នុងការគាំទ្រសាលារៀន

យន្តការចុះគាំទ្រ និងវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ ដើម្បីលើកកម្ពស់សមត្ថភាពរបស់សាលារៀនរួមមាននាយក នាយិកាសាលាគ្រូបង្រៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានឱ្យមានភាពម្ចាស់ការ និងផ្តល់ការគាំទ្រដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីឱ្យសាលារៀនមានការប្រែប្រួល និងលទ្ធផលសិក្សាសិស្សមានភាពប្រសើរឡើង និងដើម្បីឱ្យសាលារៀនអនុវត្តស្តង់ដាសាលាគំរូឆ្លើយតបនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការធ្វើហេតុវិនិច្ឆ័យសាលារៀន ឬការធ្វើស្វ័យវាយតម្លៃផ្សេងៗទៀត។

### ៧.១ ហេតុវិនិច្ឆ័យសាលារៀន ឬការធ្វើស្វ័យវាយតម្លៃ

ហេតុវិនិច្ឆ័យសាលារៀន ឬ ការធ្វើស្វ័យវាយតម្លៃរួមមាន៖

- ការវាយតម្លៃដើមគ្រាដោយផ្អែកលើសូចនាករ៨៣ និងតម្រង់ទិស តាមប្រព័ន្ធអនឡាញ
- ការវិភាគតាម SWOT ការស្រាវជ្រាវប្រតិបត្តិការធ្វើហេតុវិនិច្ឆ័យ និងធ្វើស្វ័យឆ្លុះបញ្ចាំង

#### ៧.១.១ ការវាយតម្លៃដើមគ្រាដោយផ្អែកលើសូចនាករ ៨៣

ការវាយតម្លៃនេះ ដំបូងធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ ដើម្បីធ្វើការតម្រង់ទិសលើការបំពេញសូចនាករទាំង៨៣។ បន្ទាប់ពីសាលាបានយល់ច្បាស់ សាលាធ្វើការបំពេញ សូចនាករនោះតាមអនឡាញដោយប្រើប្រាស់ Google Form ក្នុងការវាយតម្លៃ។

ស្តង់ដាសាលាមធ្យមសិក្សាគំរូនឹងត្រូវបានប្រែក្លាយជាឧបករណ៍ សម្រាប់វាយតម្លៃដើមគ្រាសាលាមធ្យមសិក្សាដែលមានភាគីពាក់ព័ន្ធដូចជា ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ព្រមទាំងគ្រប់ភាគីពាក់ព័ន្ធ។

ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិលទ្ធផលអាចទទួលយកបាន គួរអនុវត្តដូចខាងក្រោម៖

គណៈគ្រប់គ្រងសាលាមធ្យមសិក្សា ត្រូវធ្វើស្វ័យវាយតម្លៃជារឿយៗ ក្នុងពេលដំណើរការបំពេញការងារតាមរយៈការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល ឬតាមប្រព័ន្ធផ្សេងទៀតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ដោយមានការជួយសម្របសម្រួលការងារ បច្ចេកទេស

ពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបូកសរុបលទ្ធផល និងវាយតម្លៃសាលាមធ្យមសិក្សា ដើម្បីបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា នៃរដ្ឋបាលរាជធានី ខេត្ត។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវត្រួតពិនិត្យលើការវាយតម្លៃស្តង់ដា សាលាមធ្យមសិក្សាគំរូ ដើម្បីបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)។ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ដែលជាសេនាធិការរបស់ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំពិនិត្យនិងវាយតម្លៃសាលាមធ្យមសិក្សា តាមយន្តការនិងនីតិវិធីជាធរមាន។

ចំពោះបែបបទនិងនីតិវិធី នៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូនឹងមានសេចក្តីអធិប្បាយក្នុងចំណុចខាងក្រោមនៃឯកសារនេះ។ ក្របខណ្ឌពេលវេលា នៃដំណើរការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូប្រចាំឆ្នាំ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាតាមជាក់ស្តែង។

ដើម្បីមានមូលដ្ឋានក្នុងការអនុវត្តស្វ័យវាយតម្លៃសាលាមធ្យមសិក្សា អាចប្រព្រឹត្តទៅបានប្រកបដោយសង្គតិភាព និងលទ្ធផលជឿទុកចិត្តបានគ្រប់មុខសញ្ញាអ្នកពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តតាមគំរូនៃការវាយតម្លៃសាលាមធ្យមសិក្សាដូចខាងក្រោម៖

- **វិធីគណនា**
  - ស្តង់ដាទី៥ មានសូចនាកររងចំនួន ៤
  - ក្នុងចំណោមសូចនាករទាំង៤ អនុវត្តបាន១៦ពិន្ទុ

ដូចនេះ វិធីគណនាជាភាគរយគឺ៖ ចំនួនសូចនាករដែលអនុវត្តបានទទួលបាន១៦ ពិន្ទុ ចែកនឹងចំនួនសូចនាករសរុបដែលមាន២០ ពិន្ទុអតិបរមា ហើយគុណនឹង១០០។ ផ្អែកតាមការវាយតម្លៃខាងលើលទ្ធផលបានបង្ហាញថា សាលាមធ្យមសិក្សានោះអនុវត្តបាន សម្រេច១៦ ពិន្ទុ លើ២០ ពិន្ទុ ក្នុងចំណោមសូចនាករទាំង៤ នៃស្តង់ដាទី៥ ស្មើនឹង៨០% មានន័យថា ទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ។

### ៧.១.២ ការវិភាគបញ្ហាតាម SWOT ការស្រាវជ្រាវប្រតិបត្តិ ការធ្វើហេតុវិនិច្ឆ័យ និងធ្វើការឆ្លុះបញ្ចាំង

#### ក. ការវិភាគ SWOT

ការវិភាគ SWOT ជាវិធីសាស្ត្រមួយអាចយកមកប្រើក្នុងដំណាក់កាលនៃការវិភាគស្ថានភាពដែលជួយរកបញ្ហាជាក់ស្តែង ហើយរៀបចំជាផែនការដោះស្រាយ។ វាជាឧបករណ៍សម្រាប់វិភាគប្រព័ន្ធអ្វីមួយ និងការបំពេញមុខងាររបស់ប្រព័ន្ធនោះក្នុងបរិយាកាសមួយ។ ក្នុងដំណាក់កាលដំបូងនៃការធ្វើផែនការ ឧបករណ៍នេះអាចជួយអ្នកធ្វើផែនការនិងអ្នកគ្រប់គ្រង ដើម្បីកំណត់បញ្ហាសំខាន់ៗដែលបានកើតមាន។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

SWOT តំណាងឱ្យ S (Strengths): ចំណុចខ្លាំង W (Weaknesses): ចំណុចខ្សោយ O (Opportunities): កាលានុវត្តភាព និង T (Threats): ការគំរាមកំហែង។

- ចំណុចខ្លាំង និងចំណុចខ្សោយជាកត្តាខាងក្នុង ចំណែកឯកាលានុវត្តភាព និងឧបសគ្គជាកត្តាខាងក្រៅប្រព័ន្ធ។
- អ្នកវិភាគអាចមើលឃើញស្ថានភាពបច្ចុប្បន្ននិងផែនទីបង្ហាញផ្លូវដែលបង្ហាញអំពីរបៀបពង្រឹងភាពខ្លាំងរបស់ប្រព័ន្ធ និងកាត់បន្ថយ (ឬលុបបំបាត់) ភាពខ្សោយ។
- បន្ទាប់មក អ្នកវិភាគអាចប្រើតារាងនេះដើម្បីទាញយកផលប្រយោជន៍ពីកាលានុវត្តភាព និងចៀសវាង(កាត់បន្ថយ) ការគំរាមកំហែងដោយប្រើព័ត៌មានដែលមានដើម្បីបង្កើតយុទ្ធសាស្ត្រ។

### ❖ តារាងវិភាគ SWOT

| | | |
|---|---|---|
| កត្តាខាងក្នុង (Internal) | ចំណុចខ្លាំង (Strengths) | ចំណុចខ្សោយ (Weaknesses) |
| | | |
| កត្តាខាងក្រៅ (External) | កាលានុវត្តភាព (Opportunities) | ឧបសគ្គ (Threats) |
| | | |

### ❖ វិធីវិភាគ៖

- រៀបចំប្រជុំអ្នកពាក់ព័ន្ធ ដូចជា គណៈកម្មការគ្រប់គ្រងសាលារៀន នាយក ឬនាយិកា នាយករង លោកគ្រូ អ្នកគ្រូ អាណាព្យាបាល អាជ្ញាធរ និងព្រះសង្ឃ
- គូសតារាងវិភាគ SWOT រួចពន្យល់ពី SWOT: ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងឧបសគ្គ
- ចែកក្រដាសស្ទីកគ័រ ៤ សន្លឹក ឱ្យអ្នកចូលរួមបំពេញ តាមការយល់ឃើញក្នុងចំណុចទាំងបួន បន្ទាប់មកយកបិទទៅលើផ្នែកនីមួយៗ

- អ្នកសម្របសម្រួលជួយយកក្រដាសស្អិតគ័រមកអានម្តងមួយៗរហូតចប់ បើសេចក្តីដូចគ្នាមានច្រើនជាងគេ ត្រូវជាចំណុចអាទិភាព
- បន្ទាប់មក អ្នកវិភាគអាចប្រើតារាងនេះ ដើម្បីទាញយកផលប្រយោជន៍ពីកាលានុវត្តភាព និងចៀសវាង(កាត់បន្ថយ)ឧបសគ្គដោយប្រើព័ត៌មានដែលមានដើម្បីបង្កើតយុទ្ធសាស្ត្រ និងផែនការដើម្បីដោះស្រាយ និងបង្កើនវឌ្ឍនភាព។

*ឧបសម្ព័ន្ធទី៤ ៖* *ឯកសារណែនាំប្រតិបត្តិ*

ខ. ការស្រាវជ្រាវប្រតិបត្តិ

ការធ្វើការស្រាវជ្រាវប្រតិបត្តិ ដើម្បីស្វែងរកឱ្យបានស៊ីជម្រៅនូវមូលហេតុជាក់លាក់នៃបញ្ហាដែលកើតមាននៅសាលារៀនក្នុងគោលបំណង ឱ្យមានវឌ្ឍនភាពដោយផ្អែកលើភស្តុតាងនៃការស្រាវជ្រាវ។ ការអនុវត្តស្រាវជ្រាវប្រតិបត្តិរកឱ្យឃើញពីបញ្ហាជាក់ស្តែង និងចំណុចដែលត្រូវកែលម្អដើម្បីរៀបចំផែនការនានារបស់សាលារៀនឈានទៅរកវឌ្ឍនភាពក្នុងសាលាឆ្លើយតបទៅនឹងស្តង់ដាសាលាមធ្យមសិក្សាគំរូ។

ដើម្បីអនុវត្តធ្វើការស្រាវជ្រាវប្រតិបត្តិ ត្រូវឈ្វេងយល់ចំណុចសំខាន់ដូចតទៅ៖

- និយមន័យ តើអ្វីជាការស្រាវជ្រាវប្រតិបត្តិ?
- វិធីសាស្ត្រនៃស្រាវជ្រាវប្រតិបត្តិ

១. កំណត់បញ្ហា

២. ការបង្កើតសំណួរស្រាវជ្រាវ

៣. ការរកដៃគូស្រាវជ្រាវ

៤. ការប្រមូលទិន្នន័យ

៥. ការកត់ត្រាទិន្នន័យ

៦. ការវិភាគទិន្នន័យ

៧. ការឆ្លុះបញ្ចាំងឡើងវិញលើដំណើរការស្រាវជ្រាវ

៨. ការធ្វើបទបង្ហាញចែករំលែក និងការផ្តល់អនុសាសន៍

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

❖ ឥរិយាបថប្រកបដោយសីលធម៌ក្នុងដំណើរការស្រាវជ្រាវ។

ចំណុចសំខាន់ទាំងនេះ នឹងជួយឱ្យអ្នកយល់ដឹងកាន់តែច្បាស់ទៅលើការស្រាវជ្រាវប្រតិបត្តិ។

❖ **ការអនុវត្តធ្វើការស្រាវជ្រាវប្រតិបត្តិ**

ការអនុវត្តធ្វើការស្រាវជ្រាវប្រតិបត្តិ នៅពេលដែលយើងយល់ដឹងពីទ្រឹស្តី យើងអាចអនុវត្តផ្ទាល់តាមចំណុចខាងក្រោម៖

១. ប្រជុំជ្រើសរើសអ្នកពាក់ព័ន្ធដែលចង់ចូលរួមស្រាវជ្រាវ

២. បែងចែកក្រុម កំណត់តួនាទីរបស់សមាជិកក្រុម

៣. ក្រុមកំណត់បញ្ហា

៤. ក្រុមបង្កើតសំណួរស្រាវជ្រាវ និងកម្រងសំណួរសម្ភាសន៍

៥. កំណត់អ្នកចូលរួមសម្ភាសន៍ (អ្នកនៅក្នុងក្រុមដទៃពីរ ឬបីនាក់)

៦. ធ្វើសម្ភាសន៍អ្នកចូលរួមប្រើប្រាស់កម្រងសំណួរដែលបានបង្កើតតាមក្រុមនីមួយៗ

៧. ក្រុមនីមួយៗបញ្ចូលទិន្នន័យនៃការសម្ភាសតាម ***ទម្រង់គំរូ***

៨. វិភាគ និងបកស្រាយទិន្នន័យ

៩. សរសេរការស្រាវជ្រាវប្រតិបត្តិដោយប្រើប្រាស់ទម្រង់គំរូ

១០. ចែករំលែកលទ្ធផល និងកែសម្រួលរបាយការណ៍បើចាំបាច់

១១. យកធ្វើជាអនុសាសន៍ដាក់បញ្ចូលក្នុងផែនការសាលារៀន។

***ឧបសម្ព័ន្ធទី៥៖*** *បច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិ*

### ៧.១.៣ ការរៀបចំព្រឹត្តិបត្រព័ត៌មានសាលារៀន (School's Profile)

ការរៀបចំព្រឹត្តិបត្រព័ត៌មានគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ គណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំបំពេញកម្រងព័ត៌មានផលសម្រេចសាលារៀន ព័ត៌មានធាតុចូលនិងព័ត៌មានដំណើរការសាលារៀនជាព្រឹត្តិបត្រព័ត៌មានគ្រឹះស្ថានមធ្យមសិក្សា ដើម្បីជាព័ត៌មានមូលដ្ឋានជូនថ្នាក់ដឹកនាំ និងអ្នកចុះវាយតម្លៃ។ ការបំពេញព្រឹត្តិបត្រព័ត៌មានគ្រឹះស្ថានមធ្យមសិក្សាសាធារណៈត្រូវរៀបចំឡើងតាមគំរូ Word File (ជូនភ្ជាប់) ដាក់ភ្ជាប់នឹងទម្រង់ Google Form ដើម្បីឱ្យគណៈគ្រប់គ្រងសាលា ទាញយក រួចបំពេញ បន្ទាប់មក Upload តាម Google Form។ ក្រុមការងារគ្រប់គ្រងទិន្នន័យ នាយកដ្ឋានមធ្យមសិក្សា ដឹកនាំក្រុម

ការងារមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ដើម្បីសម្របសម្រួលដឹកនាំបន្តដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាក្នុងបំពេញព្រឹត្តិបត្រព័ត៌មានគ្រឹះស្ថានមធ្យមសិក្សាសាធារណៈនេះ។

ទិន្នន័យដែលគ្រឹះស្ថានសិក្សាបានបំពេញ និង Upload តាមរយៈGoogle Form នេះហើយ ត្រូវចូលមកក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនាយកដ្ឋានមធ្យមសិក្សា ដែលគ្រប់អ្នកពាក់ព័ន្ធអាចចូលទៅមើល និងទាញយកទៅប្រើប្រាស់បាន។

សាលារៀនត្រូវរៀបចំព្រឹត្តិបត្រព័ត៌មានសាលារៀនតាម Google Form ដូចមានក្នុងទម្រង់ភ្ជាប់។

*ឧបសម្ព័ន្ធទី៦៖ ទម្រង់ព្រឹត្តិបត្រព័ត៌មានសាលារៀន )*

## ៧.២ ការធ្វើតេស្តស្តង់ដា

### ៧.២.១ តេស្តប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស

ការធ្វើតេស្តប្រចាំខែ/ត្រីមាស/ឆមាសត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើននៅកម្រិតសាលារៀន។ គណៈគ្រប់គ្រងសាលារៀនធ្វើការជាមួយក្រុមបច្ចេកទេស និងគណៈកម្មការគ្រប់គ្រងសាលារៀនរៀបចំកម្មវិធីតេស្តមួយដែលអាចធានាបាននូវភាពត្រឹមត្រូវ និងមិនលម្អៀងគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់។ ដើម្បីអនុវត្តកិច្ចការតេស្តនេះបានប្រកបដោយគុណភាព និងមានលក្ខណៈស្តង់ដា គណៈគ្រប់គ្រងសាលារៀនត្រូវជ្រើសរើសគ្រូបង្រៀនឱ្យធ្វើជាអនុរក្សតេស្តសម្រាប់គ្រប់គ្រងសកម្មភាព តេស្ត កែសន្លឹកកិច្ចការសិស្ស ស្រង់ឬកពិន្ទុ និងគូសជាប់ធ្លាក់ ដោយប្តូរពួកគាត់ពីថ្នាក់មួយទៅថ្នាក់ មួយទៀត ឬកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយផ្សេងទៀត។ ចំណែកឯបុគ្គលិកផ្សេងទៀតក្នុងសាលារៀន ជាអ្នកជួយគ្រប់គ្រងសណ្តាប់ធ្នាប់ និងវិន័យដើម្បីទប់ស្កាត់ការយកឯកសារ និងឧបករណ៍អេឡិចត្រូនិកចូលក្នុងបន្ទប់តេស្ត។ ដើម្បីបង្ហាញពីតម្លាភាពនៃការធ្វើតេស្ត សាលារៀនត្រូវអញ្ជើញ គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ មាតាបិតាសិស្ស និងតំណាងក្រុមប្រឹក្សាកុមារស្ម័គ្រចិត្ត ចូលរួមសង្កេតដំណើរការតេស្តនេះផងដែរ។

### ៧.២.២ មុនពេលធ្វើតេស្ត

ក. ឯកសាររដ្ឋបាល



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

គណៈគ្រប់គ្រងសាលារៀនត្រូវដឹកនាំប្រជុំជាមួយលោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធដើម្បីបែងចែកតួនាទី ភារកិច្ច និងជួយធ្វើកិច្ចការសំខាន់ៗដើម្បីត្រៀមឱ្យបានរួចរាល់មុនពេលតេស្ត។ កិច្ចការទាំងនេះមានដូចជា៖

- រៀបចំកាលវិភាគតេស្តប្រចាំខែ
- រៀបចំបញ្ជីឈ្មោះសិស្សដែលត្រូវធ្វើតេស្តទៅតាមលំដាប់អក្ខរក្រម និងបិទផ្សាយ
- រៀបចំប្លង់បន្ទប់សម្រាប់ប្រើក្នុងការធ្វើតេស្ត
- រៀបចំបំណែងចែកភារកិច្ចគណៈកម្មការមេប្រយោគ គណៈកម្មការកណ្តាល គណៈកម្មការត្រួតពិនិត្យអគារ និងគណៈកម្មការអនុរក្ស
- រៀបចំគណៈកម្មការកំណែ
- រៀបចំគណៈកម្មការស្រង់ បូកពិន្ទុ និងផ្ទៀងផ្ទាត់
- ត្រួតពិនិត្យវិញ្ញាសាតេស្ត និងត្រៀមថតចម្លងឱ្យបានរួចរាល់តាមចំនួនសិស្សនៅក្នុងបន្ទប់នីមួយៗ។ល។

ក្រោយពីបានត្រៀមកិច្ចការខាងលើរួចរាល់អស់ហើយ គណៈគ្រប់គ្រងសាលារៀនត្រូវដឹកនាំការប្រជុំម្តងទៀតជាមួយលោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីផ្ទៀងផ្ទាត់ភារកិច្ចដែលបានរៀបចំកន្លងមកនិងរួមគ្នាផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីកាលបរិច្ឆេទ បន្ទប់តេស្ត កិច្ចការងារ ទាក់ទងនឹងការធ្វើតេស្តដល់សិស្សដើម្បីបានត្រៀមខ្លួន និងប្រឹងប្រែងរៀនសូត្រ ដល់គ្រូបង្រៀនដើម្បី បានជួយសិស្សឱ្យហ្វឹកហាត់បានកាន់តែស្ទាត់ដល់អ្នកអាណាព្យាបាលសិស្ស និងសហគមន៍ដើម្បីបាន ដឹងឮអំពីព្រឹត្តិការណ៍នៃការធ្វើតេស្តរបស់កូននៅក្នុងសាលារៀន។ ការតេស្តនេះអាច ជាឱកាសជំរុញ ឱ្យអ្នកអាណាព្យាបាលសិស្សបានចូលរួមសង្កេតសកម្មភាពតេស្ត យល់ដឹងអំពីដំណើរការធ្វើតេស្ត ជំរុញកូនចៅរបស់គាត់ឱ្យខិតខំរៀនសូត្របន្ថែមនៅផ្ទះ និងចូលរួមចំណែកអភិវឌ្ឍសាលារៀនដែលជាផ្នែកមួយនៃសហគមន៍របស់គាត់។

### ខ. ការរៀបចំវិញ្ញាសាតេស្ត

ដើម្បីបង្កើតវិញ្ញាសាមួយមានលក្ខណៈស្តង់ដា យើងត្រូវអនុវត្តតាមជំហានសំខាន់ៗចំនួនបួន។ ជំហានទាំងនោះរួមមាន៖

១-ដំបូងគ្រូបង្រៀនត្រូវរៀបចំបំណែងចែកកម្មវិធីសិក្សាប្រចាំខែដោយមានបញ្ចូលលទ្ធផលសិក្សា (ជួនកាល គេសរសេរថា លទ្ធផលសិក្សារំពឹងទុក) ដែលមានសរសេរនៅ ក្នុងសៀវភៅកម្មវិធីសិក្សាលម្អិត។

២-បន្ទាប់មកគ្រូបង្រៀនត្រូវយកបំណែងចែកម៉ោងបង្រៀនទាំងនេះ ទៅប្រើប្រាស់ដើម្បីរៀបចំកិច្ចតែងការបង្រៀន។ ពេលបង្រៀនបានចប់មួយខែ គ្រូបង្រៀនត្រូវបង្កើតតារាងកំណត់គម្រោងលម្អិតវិញ្ញាសាតេស្តប្រចាំខែដោយយោងទៅតាមបំណែងចែកកម្មវិធីសិក្សាប្រចាំខែ។

៣- បន្ទាប់មកទៀត គ្រូបង្រៀនត្រូវកសាងសំណួរតេស្ត ដោយផ្អែកលើតារាងកំណត់គម្រោងលម្អិតវិញ្ញាសាតេស្តប្រចាំខែដែលបានបង្កើតរួចហើយនេះ។

៤- ជាចុងក្រោយ គ្រូបង្រៀនត្រូវផ្គុំសំណួរតេស្តនីមួយៗឱ្យក្លាយជាវិញ្ញាសាតេស្ត ប្រចាំខែ/ត្រីមាស/ឆមាស។

### ៧.២.៣ អំឡុងពេលធ្វើតេស្ត

គណៈគ្រប់គ្រងសាលារៀនត្រូវដឹកនាំការប្រជុំរយៈពេលខ្លីមួយ (ប្រហែល៣០នាទី) មុនដំណើរការធ្វើតេស្តចាប់ផ្តើម ដើម្បីត្រួតពិនិត្យសមាសភាព ស្រង់វត្តមាន និងណែនាំបន្ថែមអំពី ទំនួលខុសត្រូវខ្ពស់តាមតួនាទីរៀងៗខ្លួន ដែលបានកំណត់។

ក្រោយពីប្រជុំ និងទទួលបានការណែនាំពីគណៈគ្រប់គ្រងសាលារៀនរួចហើយ អនុរក្សតេស្តទាំងអស់ត្រូវយកបញ្ជីឈ្មោះសិស្ស ឯកសារពាក់ព័ន្ធ និងសម្ភារៈត្រូវការចាំបាច់នានាពីទីចាត់ការតម្រង់ទៅបន្ទប់តេស្ត ដើម្បីរៀបចំបន្ទប់ ត្រួតពិនិត្យតុកៅអី សរសេរលេខតុ និងត្រៀមក្តារខៀនឱ្យបានរួចស្រេច មុនពេលការធ្វើតេស្តចាប់ផ្តើម។ ចំពោះបុគ្គលិកទទួលខុសត្រូវផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ និងអ្នកត្រួតពិនិត្យដំណើរការតេស្តត្រូវទៅកាន់ទីកន្លែងដែលបានកំណត់ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

ក្នុងពេលដំណើរការធ្វើតេស្ត គណៈគ្រប់គ្រងសាលារៀនត្រូវណែនាំអនុរក្សទាំងអស់ឱ្យផ្តល់សញ្ញាដល់សិស្សដោយសរសេរនៅលើក្តារខៀនអំពីម៉ោងចាប់ផ្តើម រយៈពេល១៥ នាទី និង៥ នាទីមុនប្រមូលវិញ្ញាសាដើម្បីឱ្យសិស្សអាចត្រៀមខ្លួនជាមុននិងពេលដល់ម៉ោងប្រមូល។ អនុរក្សត្រូវអនុវត្តតាមការណែនាំនេះឱ្យបានដូចគ្នាពីបន្ទប់តេស្តមួយទៅបន្ទប់មួយផ្សេងទៀត។

ឆ្លៀតឱកាសនេះដែរ នាយក/នាយិកាសាលាត្រូវព្យាយាមរកពេលវេលា និយាយពន្យល់ណែនាំអ្នកអាណាព្យាបាលសិស្ស និងសហគមន៍ដែលបានចូលរួមសង្កេតការណ៍ អំពីផលប្រយោជន៍ និងសារៈ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

សំខាន់នៃការធ្វើតេស្តរបស់សាលារៀនដើម្បីឱ្យគាត់មានទំនុកចិត្តទៅលើការគ្រប់គ្រងបច្ចេកទេសរបស់សាលារៀន។ ការចូលរួមរបស់អ្នកអាណាព្យាបាលក៏ជាមធ្យោបាយមួយក្នុងការទាក់ទាញការចូលរួមរបស់ពួកគាត់ និងជួយផ្សព្វផ្សាយបន្តអំពីសារៈសំខាន់នៃការធ្វើតេស្តនេះ ដល់អ្នកអាណាព្យាបាលសិស្សដ៏ទៃទៀតក្នុងមូលដ្ឋាន។

### ៧.២.៤ ក្រោយពេលធ្វើតេស្ត

គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធត្រូវត្រួតពិនិត្យនិងរាប់ចំនួនសន្លឹកកិច្ចការរបស់សិស្ស បញ្ជីវត្តមានសិស្សចូលរួមតេស្ត និងឯកសារចាំបាច់មួយចំនួនផ្សេងទៀត ដែលអនុរក្សប្រគល់ឱ្យ។ បន្ទាប់មកគណៈគ្រប់គ្រងសាលារៀនត្រូវចាត់ចែងក្រុមកំណែ និងក្រុមអ្នកត្រួតពិនិត្យកំណែឱ្យបានច្បាស់លាស់ និងម៉ត់ចត់។ ការកែត្រូវផ្អែកលើតារាងអត្រាកំណែ ដែលគ្រូបង្រៀនបានរៀបចំក្នុងអំឡុងពេលបង្កើតសំណួរតេស្តសម្រាប់ការធ្វើតេស្តកន្លងមក។

ក្រោយពីកែកិច្ចការសិស្សរួចស្រេចហើយក្រុមស្រង់ បូកពិន្ទុ ចាប់ផ្តើមស្រង់លទ្ធផលតេស្តរបស់សិស្សម្នាក់ៗតាមបន្ទប់តេស្ត បន្ទាប់មកក្រុមគូសជាប់ធ្លាក់ស្រង់ចំនួនសិស្សសរុបដែលតេស្តជាប់និងតេស្តធ្លាក់តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ ហើយគណៈគ្រប់គ្រងសាលារៀនបិទផ្សាយ លទ្ធផលតេស្ត ប្រចាំខែ និងផ្សព្វផ្សាយដល់មាតាបិតា និងអ្នកអាណាព្យាបាល។

បញ្ជីចំនួនសិស្សសរុបជាប់និងធ្លាក់អាចជួយឱ្យគណៈគ្រប់គ្រងសាលារៀនប្រើសម្រាប់ផ្សព្វផ្សាយដល់សហគមន៍ និងសម្រាប់លើកជារបៀបវារៈប្រជុំពិភាក្សាជាមួយគ្រូបន្ទុកថ្នាក់ដើម្បីដោះស្រាយបញ្ហាក្នុងករណីមានសិស្សធ្លាក់ច្រើន ឬចំនួនសិស្សជាប់មិនមានការកើនឡើង និងមានការធ្លាក់ចុះវិញ។

សាលារៀន និងលោកគ្រូ អ្នកគ្រូត្រូវប្រើប្រាស់លទ្ធផលដែលបានមកពីការធ្វើតេស្តប្រចាំខែឱ្យស្របទៅតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានចែងថា ការធ្វើតេស្តប្រចាំខែជាការវាយតម្លៃបញ្ចប់ការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស និងជាការវាយតម្លៃតាមដំណាក់សម្រាប់អភិវឌ្ឍការបង្រៀននិងរៀនរបស់គ្រូនិងសិស្ស។ ដូចនេះ សាលារៀន និងលោកគ្រូ អ្នកគ្រូគួរតែប្រើប្រាស់លទ្ធផលពីការធ្វើតេស្តនេះក្នុងការបង្កើនគុណភាពការសិក្សារបស់សិស្ស តាមរយៈការវិភាគ ស៊ីជម្រៅដែលនឹងបង្ហាញលម្អិតនៅផ្នែកខាងក្រោម។

### ៧.២.៥ ការវិភាគលទ្ធផលដែលទទួលបានពីការធ្វើតេស្ត

ដូចដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ លទ្ធផលដែលទទួលបានពីការធ្វើតេស្ត ត្រូវតែប្រើប្រាស់ដើម្បីៈ ទី១) កំណត់រកពិន្ទុប្រចាំខែ/ត្រីមាស/ឆមាស (ការធ្វើតេស្តដើម្បីបញ្ចប់ ការបង្រៀន

និងរៀនរបស់គ្រូនិងសិស្ស) ទី២) អភិវឌ្ឍការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស (ការធ្វើតេស្តដើម្បីអភិវឌ្ឍការបង្រៀននិងរៀនរបស់គ្រូ និងសិស្ស)។ ប៉ុន្តែដើម្បីសម្រេចបាន គោលដៅទី២ លទ្ធផលដែលបានមកពីការធ្វើតេស្តនេះ ត្រូវវិភាគឱ្យបានស៊ីជ្រៅបន្ថែមទៀត។ នៅក្នុងការវិភាគតាមសិស្សម្នាក់ៗអាចរកឃើញពិន្ទុ ឬមធ្យមភាគពិន្ទុប្រចាំខែរបស់សិស្សម្នាក់ៗ។

### ៧.២.៦ ការប្រើប្រាស់លទ្ធផលតេស្ត

រាល់ការវាយតម្លៃឬការធ្វើតេស្តទាំងអស់ ប្រសិនបើលទ្ធផលដែលទទួលបានមិនត្រូវបានប្រើប្រាស់ នោះការវាយតម្លៃឬការធ្វើតេស្តនេះគឺគ្មានន័យអ្វីទាំងអស់។ ដូចនេះ រាល់លទ្ធផលទាំងអស់ ដែលបានមកពីការវាយតម្លៃនិងតេស្តផ្សេងៗត្រូវតែយកទៅប្រើប្រាស់ ហើយការប្រើប្រាស់ទៀតសោតត្រូវប្រើប្រាស់ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ទើបការវាយតម្លៃ និងការធ្វើតេស្តរបស់យើងមានប្រយោជន៍។ សម្រាប់ការធ្វើតេស្តប្រចាំខែ/ត្រីមាស/ឆមាស បើតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា លទ្ធផលដែលបានមកពីការវាយតម្លៃនេះត្រូវប្រើប្រាស់ក្នុងគោលបំណងពីរសំខាន់គឺ ១) ដើម្បីកំណត់រកលទ្ធផលបញ្ចប់មេរៀន ជំពូកឬខែនីមួយៗ និង ២) ដើម្បីអភិវឌ្ឍការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស។

*ឧបសម្ព័ន្ធទី៧ ៖ ការធ្វើតេស្តស្តង់ដា*

### ៧.២.៧ តេស្តដើមឆ្នាំ

#### ក- ការរៀបចំតេស្តដើមឆ្នាំ

ដើម្បីឱ្យគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ បានដឹងពីសមត្ថភាពសិស្សម្នាក់ៗ និងងាយស្រួលក្នុងការជួយសិស្សបានទាន់ពេលវេលាចាប់ពីដើមឆ្នាំសិក្សា។

សិស្សថ្នាក់ទី៧ថ្មីត្រូវធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ចំណែកឯថ្នាក់ទី១០ ថ្មី ត្រូវយកមុខវិជ្ជាយ៉ាងហោចណាស់ចំនួន៦ រួមមាន៖ ភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា។ រីឯកម្រិតថ្នាក់ផ្សេងទៀតគួរធ្វើតេស្ត ឬអាចយកលទ្ធផលតេស្តដំណាច់ ឆមាសទី២ ជា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

គោលគ្រប់កម្រិតថ្នាក់ និងគ្រប់មុខវិជ្ជាដើម្បីឱ្យគណៈគ្រប់គ្រងនិងគ្រូបង្រៀនបានដឹងអំពីកម្រិតសមត្ថភាពសិស្សម្នាក់ៗរៀបចំសកម្មភាពជួយអន្តរាគមន៍សិស្សរៀនយឺតបានទាន់ពេល។

យន្តការរៀបចំតេស្តដើមឆ្នាំត្រូវអនុវត្តតាមការរៀបចំតេស្តប្រចាំខែ/ត្រីមាស/ឆមាស។

ខ- ការប្រើប្រាស់តេស្តដើមឆ្នាំ

បន្ទាប់ពីទទួលបានលទ្ធផលពីការធ្វើតេស្តដើមឆ្នាំ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនត្រូវៈ

- សម្របសម្រួល ឱ្យគ្រូមុខវិជ្ជានីមួយៗ រៀបចំផែនការសកម្មភាពប្រចាំខែ ត្រីមាស និងឆ្នាំដើម្បីជួយសិស្សរៀនយឺត ដោយផ្អែកតាមការធ្វើតេស្តស្តង់ដាដើមឆ្នាំជាមូលដ្ឋានតាមកម្រិតសមត្ថភាព (និទ្ទេស A B C D E F) ជាពិសេសគ្រូមុខវិជ្ជាដែលបង្រៀនថ្នាក់សិស្ស រៀនយឺត ធ្លាក់មធ្យមភាគដើមឆ្នាំ ឬធ្លាក់លទ្ធផលតេស្ត។
- រៀបចំបំណែងចែកកម្មវិធីបង្រៀន សម្រាប់ជួយសិស្សរៀនយឺត ផ្អែកតាមសមត្ថភាពសិស្ស
- រៀបចំតារាងតាមដានលទ្ធផលសិក្សារបស់សិស្សរៀនយឺតប្រចាំខែតាមកម្រិតថ្នាក់ផ្អែកលើលទ្ធផលតេស្តស្តង់ដាប្រចាំខែ។
- អញ្ជើញមាតាបិតាឬអ្នកអាណាព្យាបាលមកជួបពិភាក្សារកមធ្យោបាយជួយសិស្សដែលមានកម្រិតសមត្ថភាព (និទ្ទេស D E F) ផ្តោតលើការជួយ សិស្សមករៀនទាន់ពេល ការបង្កើនម៉ោងសិក្សាស្វ័យសិក្សា។
- រៀបចំការបង្រៀនបន្ថែម ដើម្បីគ្រូបង្រៀនតាមមុខវិជ្ជាជួយសិស្សរៀនយឺត អាចទំនាក់ទំនងនិងផ្តល់ព័ត៌មានត្រឡប់ទៅមាតាបិតា ឬអ្នកអាណាព្យាបាលប្រចាំខែ។

៧.២.៨ អំណានស្ទាត់

ក- ការត្រៀមមុនពេលធ្វើតេស្តអំណានស្ទាត់

១- រៀបចំចងក្រង តាក់តែង ឬដកស្រង់អត្ថបទសម្រាប់ធ្វើតេស្តលើការអានស្ទាត់។ លក្ខណៈវិនិច្ឆ័យអត្ថបទត្រូវប្រើប្រាស់ពាក្យផ្សេងៗដូចជា ប្រភេទពាក្យ ព្យញ្ជនៈផ្សំស្រៈ ប្រកបធ្វើជើងព្យាង្គតម្រួត បាលី សំស្ក្រឹត អញ្ញត្រសព្ទ ពាក្យចំណាំ (ពាក្យប្តូរសូរ និងពាក្យមានតួអក្សរមិនអាន)។

២- រៀបចំបញ្ជីឈ្មោះសិស្ស បញ្ជីពិន្ទុប្រចាំខែ តាមថ្នាក់នីមួយៗ។

៣- រៀបចំឧបករណ៍តេស្ត រួមមាន សន្លឹកកិច្ចការសម្រាប់សិស្សអាន ឯកសារកិច្ចការ សិស្ស និងឯកសារណែនាំអនុរក្ស។

៤- រៀបចំទីកន្លែងសម្រាប់ធ្វើតេស្តសិស្សម្នាក់ម្តងៗ។

៥- ត្រៀមនាឡិកាសម្រាប់ផ្ទៀងល្បឿននៃការអានរបស់សិស្សម្នាក់ៗ (ល្បឿនអំណានគិតជាវិនាទី)។

ខ- ដំណើរការធ្វើតេស្ត

១-អនុរក្សបំពេញព័ត៌មានផ្ទាល់ខ្លួនសិស្ស និងកាលបរិច្ឆេទធ្វើតេស្តនៅក្នុង «ឯកសារកិច្ចការសិស្ស» មុនពេលចាប់ផ្តើមធ្វើតេស្ត។

២-អនុរក្សហៅសិស្សមកធ្វើតេស្តសិស្សម្នាក់ម្តងៗ។

៣-អនុរក្សណែនាំសិស្សថាសូមប្អូនអានអត្ថបទនេះឱ្យបានលឿនបំផុតតាមដែលអាចធ្វើបាន។ ប្អូនមានរយៈពេលត្រឹមតែ៦០ វិនាទីប៉ុណ្ណោះ សម្រាប់អានអត្ថបទនេះ។

៤-ពេលសិស្សអាន អនុរក្សត្រូវយកចុងខ្មៅដៃចង្អុលតាមតួអក្សរ នីមួយៗនៅលើឯកសារសន្លឹកកិច្ចការសិស្ស។

៥-អនុរក្សគូសសញ្ញាអក្សរ A (គូសពីក្រោមត្រង់ចំណុចចន្លោះ សិស្សអានដោយ បន្ថែមពាក្យ) នៅលើពាក្យណាដែលសិស្សអានលើស (ថែមពាក្យ)

៦-អនុរក្សគូសសញ្ញា/ពាក្យណាដែលសិស្សអានរំលង (ខ្វះ)

៧-អនុរក្សគូសសញ្ញាធូត លើពាក្យណាដែលសិស្សអានរដិបរដុប(ស្ទួន)

៨-អនុរក្សគូសសញ្ញា X នៅលើពាក្យណាដែលសិស្សអានខុស។ បន្ទាប់មក ឱ្យសិស្សអានពាក្យនោះឡើងវិញភ្លាមៗ ដោយទុករយៈពេលឱ្យអាន៣វិនាទី។ បើសិស្សអានពាក្យនោះឡើងវិញបានត្រឹមត្រូវ អនុរក្សត្រូវគូសវង់ជុំវិញពាក្យ ដែលបានគូសសញ្ញា X នេះហើយចាត់ទុកថាសិស្សអានពាក្យនោះបានត្រឹមត្រូវ។ ប្រសិនបើក្នុងរយៈពេល៣ វិនាទីសិស្សមិនអាចអានពាក្យនោះឡើងវិញបានទេ អនុរក្សត្រូវប្រាប់ពាក្យនោះដល់សិស្សហើយឱ្យសិស្សអានជាបន្តទៀតរហូតចប់។

៩-ពេលសិស្សអានអត្ថបទបាន៦០វិនាទី អនុរក្សត្រូវគូសសញ្ញាវង់ក្រចក ( ) នៅលើពាក្យ ចុងក្រោយបំផុតដែលសិស្សបានអានដល់។

១០-ការបញ្ឈប់ការអាននៅដើមទី៖ ប្រសិនបើសិស្សមិនអាចអានបានមួយល្បះដំបូង អនុរក្សត្រូវប្រាប់សិស្សថា អរគុណហើយបញ្ឈប់ការអានរបស់សិស្ស ដោយគូសធូតល្បះ នោះ ទាំងអស់ រួចគូសសញ្ញាខ្វែង X នៅប្រអប់ខាងក្រោម។

១១-ប្រសិនបើសិស្សអានបាន២០០ ពាក្យ មុនរយៈពេល៦០វិនាទី អនុរក្សត្រូវសរសេរចំនួន វិនាទីដែលនៅសល់នៅផ្នែកខាងក្រោមនៃអត្ថបទ។

គ- ក្រោយពេលធ្វើតេស្ត

១- អនុរក្សប្រមូល«ឯកសារកិច្ចការសិស្ស» រៀបចំដាក់តាមថ្នាក់នីមួយៗ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

២-អនុរក្សធ្វើការកែនិងដាក់ពិន្ទុលើ«ឯកសារកិច្ចការសិស្ស»តាមអត្រាកំណែខាងក្រោម៖

- អត្រាកំណែអត្ថបទតេស្តអំណានស្ទាត់នេះគិតត្រឹម២០០ពាក្យ

$$\text{របៀបគិតពិន្ទុសរុបគឺ ពិន្ទុសរុប} = \frac{\text{ពិន្ទុល្បឿនអំណាន} \times \text{ពិន្ទុភាពអំណាន}}{២}$$

- ១ពាក្យ ស្មើនឹង០,៥ ពិន្ទុ
- ពិន្ទុល្បឿនអំណាន មាន១០០ពិន្ទុ
- ពិន្ទុគុណភាពអំណាន មាន១០០ពិន្ទុ
- ការបញ្ឈប់ការអាន ពិន្ទុស្មើនឹង០,០០ពិន្ទុ

៣- អនុរក្សស្រង់ពិន្ទុដាក់ក្នុងបញ្ជីពិន្ទុប្រចាំខែ។

៤-ធ្វើរបាយការណ៍បង្ហាញពីភាពប្រែប្រួលសមត្ថភាពសិស្សលើល្បឿនអំណាននិងគុណភាពអំណាន។

## ៧.៣ ការរៀបចំផែនការសាលារៀន

ការរៀបចំផែនការសាលារៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅត្រូវស្របតាមគោលការណ៍ណែនាំស្ដីពី មូលនិធិដំណើរការសាលារៀនសាធារណៈ(SOF)(មើលឧបសម្ព័ន្ធ)ក្រសួងតម្រូវឱ្យសាលារៀនទាំងអស់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន(៥ឆ្នាំ)ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន (៣ ឆ្នាំរំកិល) ផែនការថវិកា (១ ឆ្នាំ) និងផែនការប្រតិបត្តិប្រចាំឆ្នាំ ឬផែនការកែលម្អសាលារៀន(១ឆ្នាំ)។ ការរៀបចំផែនការនេះ ត្រូវឆ្លើយតបនឹងស្តង់ដាទាំង៥ នៃស្តង់ដាសាលារៀនគំរូដែលរួមមាន៖

១.លទ្ធផលសិក្សារបស់សិស្ស

២.ការបង្រៀន និងរៀន

៣.ការចូលរួមរបស់សហគមន៍

៤.ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន

៥.គណនេយ្យភាព

### ៧.៣.១ យន្តការនៃការរៀបចំផែនការសាលារៀន

ការរៀបចំផែនការសាលារៀនត្រូវដឹកនាំដោយនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីសមាជិក គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ប្រធានភូមិ ប្រធានក្រុម ក្រុមប្រឹក្សាយុវជននិងកុមារ តំណាងសិស្សានុសិស្ស មាតាបិតាសិស្ស និងតំណាងប្រជាពលរដ្ឋ ដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍ ដើម្បីពិភាក្សារួមគ្នាលើតម្រូវការចាំបាច់របស់សាលារៀននិងសហគមន៍ ជាពិសេស លើបញ្ហាប្រឈមចម្បងៗ និងលទ្ធផលសិក្សារបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ជាពិសេសកុមារ ទាំងអស់បានចូលរៀន សិស្សរៀនចេះ ប្រឡងជាប់ និងបន្តរៀនចប់តាមភូមិសិក្សានីមួយៗ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនត្រូវសម្រេចដោយប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ក្រុងស្រុកខណ្ឌ ចំណែកផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំនិងផែនការប្រតិបត្តិប្រចាំឆ្នាំត្រូវសម្រេចពីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាមរយៈប្រធានការិយាល័យនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

### ៧.៣.២ ទម្រង់ផែនការសាលារៀន

#### ក.ទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន( ៥ ឆ្នាំ )

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន( ៥ ឆ្នាំ ) ត្រូវឆ្លើយតបនឹងស្តង់ដាសាលារៀនគំរូតាមទម្រង់ដូចខាងក្រោម៖

១. សេចក្តីផ្តើម
២. ប្រវត្តិសាលារៀន
៣. ចក្ខុវិស័យ
៤. បេសកកម្ម
៥. វិភាគស្ថានភាព និងបញ្ហាប្រឈម
៦. សូចនាករ និងចំណុចដៅរបស់សាលារៀន
៧. យុទ្ធសាស្ត្រនិងសកម្មភាព
៨. ចំណោលតម្រូវការថវិកា
៩. យន្តការពិនិត្យតាមដាន និងវាយតម្លៃ

តារាងទី១៖ សូចនាករ និងចំណុចដៅរបស់សាលារៀន រយៈពេល៥ឆ្នាំ (២០២៤ ដល់ ២០២៨)

| ល.រ | ស្តង់ដា និងសូចនាករ | ឆ្នាំមូលដ្ឋាន ២០២៣ | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | |
| | ........................................ | | | | | | |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | | | | |
|---|---|---|---|---|---|---|---|
| ស្តង់ដាទី២៖ ការបង្រៀននិងរៀន | | | | | | | |
| | ……………………………… | | | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | | | | |
| | ……………………………… | | | | | | |
| ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | | | | |
| | ……………………………… | | | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាព | | | | | | | |
| | ……………………………… | | | | | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ខ. ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ

ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ( ១ឆ្នាំ )ត្រូវឆ្លើយតបនឹងស្តង់ដាសាលារៀនគំរូ តាមទម្រង់ដូចខាងក្រោម៖

១. សេចក្តីផ្តើម

២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

៣. គោលបំណង

៤. សូចនាករ និងចំណុចដៅរបស់សាលារៀន

៥. សកម្មភាពអនុវត្ត

តារាងទី១៖ សូចនាករ និងចំណុចដៅ

| ល.រ | ស្តង់ដា និងសូចនាករ | ឯកតា | ឆ្នាំគោល | ចំណុចដៅ |
|---|---|---|---|---|
| | | | ២០២២-២០២៣ | ២០២៣-២០២៤ |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | |
| | | | | |
| ស្តង់ដាទី២៖ ការបង្រៀន និងរៀន | | | | |
| | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | |
| | | | | |
| ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | |
| | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាព | | | | |
| | | | | |

តារាងទី២៖ សកម្មភាពអនុវត្ត

| ល.រ | លទ្ធផលរំពឹងទុក | សកម្មភាព | ក្របខណ្ឌពេលវេលា | | | | អ្នកទទួលខុសត្រូវ | ប្រភពធនធាន | | | ថវិកាសរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | រដ្ឋ | សហគមន៍ | ដៃគូ | |
| | | | 1 | 2 | 3 | 4 | | 1 | 2 | 3 | 4=(1+2+3) |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | | | | | |
| | ……………… | | | | | | | | | | |
| ស្តង់ដាទី២៖ ការបង្រៀន និងរៀន | | | | | | | | | | | |
| | ……………… | | | | | | | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | | | | | | | | |
| | ……………… | | | | | | | | | | |
| ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | | | | | | | | |
| | ……………… | | | | | | | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាព | | | | | | | | | | | |
| | ……………… | | | | | | | | | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

គ. សកម្មភាពអនុវត្ត

- ទម្រង់ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសាលារៀន ត្រូវឆ្លើយតបតាមស្តង់ដាសាលារៀនគំរូតាមទម្រង់ដូចខាងក្រោម៖

១.សេចក្តីផ្តើម

២.ចក្ខុវិស័យ

៣.បេសកកម្ម

៤.វឌ្ឍនភាពនៃសូចនាករគន្លឹះ និងបញ្ហាប្រឈម

៥.សូចនាករសមិទ្ធកម្ម និងគោលដៅ។

**តារាងទី១.សូចនាករសមិទ្ធកម្ម និងគោលដៅ**

| ស្តង់ដានិង សូចនាករ | ឆ្នាំគ្រោងថវិកា ២០២៤ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំមុន (២០២២) | ឆ្នាំបច្ចុប្បន្ន (២០២៣) | ឆ្នាំគ្រោងថវិកា | | ឆ្នាំគ្រោងថវិកា (២០២៥) | ឆ្នាំគ្រោងថវិកា (២០២៦) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ(ធៀបនឹងគោលដៅឆ្នាំ២០២៣) | | |
| សូចនាករលទ្ធផលចុងក្រោយ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស** | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ……………… | | | | | | | |
| **ស្តង់ដាទី២៖ការបង្រៀននិងរៀន** | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ……………… | | | | | | | |
| **ស្តង់ដាទី៣៖ការចូលរួមរបស់សហគមន៍** | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ……………… | | | | | | | |
| **ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិការនិងរដ្ឋបាលសាលារៀន** | | | | | | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ……………… | | | | | | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាព** | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| …………… | | | | | | | |

- តម្រូវការចំណាយ

**តារាងទី២៖ការកំណត់តម្រូវការចំណាយ**

| ល.រ | សកម្មភាព | ច្បាប់ហិរញ្ញវត្ថុឆ្នាំ N | | | | គម្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ N+1 | | | | គម្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ N+2 | | | | គម្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ N+3 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | **គាំទ្រដំណើរការសាលារៀន** | ថវិកា | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ | ថវិកា | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ | ថវិកា | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ | ថវិកា | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ |
| ១.១ | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.២ | ការថែទាំ និងជួសជុលផ្សេងៗ | | | | | | | | | | | | | | | | |
| **២** | **កែលម្អគុណភាព បង្រៀន និងរៀន** | | | | | | | | | | | | | | | | |
| ២.១ | ការចូលរួមរៀន ប្រកបដោយសមធម៌ និងបង្ការសិស្សបោះបង់ | | | | | | | | | | | | | | | | |
| ២.៣ | ការកែលម្អបរិស្ថាន និងទីធ្លាកម្សាន្ត | | | | | | | | | | | | | | | | |
| ២.៤ | អប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | | | | | | | | |
| | **សរុបរួម** | | | | | | | | | | | | | | | | |

ឃ. យន្តការនៃការពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀន

ដើម្បីឱ្យការពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀន ប្រកបដោយសក្តិសិទ្ធភាព និងប្រសិទ្ធភាព សាលារៀនត្រូវ៖

- បង្កើតក្រុមការងារពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀន
- ពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន និងទិសដៅបន្តរបស់សាលារៀនដែលកំណត់
- កំណត់អំពីមេរៀនពិសោធន៍ដែលទទួលបានពីការអនុវត្តកន្លងមក
- ពិនិត្យតាមដាន និងវាយតម្លៃគ្រប់កម្មវិធី និងសកម្មភាពទាំងអស់
- កំណត់កាលបរិច្ឆេទ និងការផ្សាយលទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ
- ទទួលមតិយោបល់ពីអ្នកពាក់ព័ន្ធ លើការអនុវត្តផែនការសាលារៀន ដើម្បីកែលម្អផែនការនៅពេលបន្ទាប់។

*ឧបសម្ព័ន្ធទី៨៖ សេចក្តីណែនាំលេខ៦១.អយក.សណន.ការរៀបចំផែនការសាលារៀន*

៧.៤ ការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន

ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សាលារៀន គឺជាផ្នែកមួយដ៏សំខាន់ដែលមានឥទ្ធិពលដល់ការអនុវត្តផែនការសកម្មភាពនានារបស់សាលារៀនដើម្បីជានាន្ទវការផ្តល់សេវាអប់រំដល់សង្គមប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ ដើម្បីសម្រេចបាននូវគោលបំណងនេះ សាលារៀនត្រូវមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយជាក់លាក់សម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនរបស់ខ្លួន។ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សាលារៀនផ្តោតលើការរៀបចំផែនការថវិកា ការវិភាជថវិកា ការអនុវត្តចំណូលចំណាយ និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃ។

៧.៤.១ ការរៀបចំផែនការថវិកាសាលារៀន

ការរៀបចំផែនការថវិកាសាលារៀនគឺជាកិច្ចដំណើរការនៃការកំណត់ពីតម្រូវការថវិកា ដើម្បីអនុវត្តសកម្មភាព ឬគម្រោងមួយ ដោយត្រូវផលិតបានជាលទ្ធផល និងសមិទ្ធផលជាក់ស្តែង។ នៅពេលអនុវត្តមូលនិធិដំណើរការសាលារៀន សាលារៀនសាធារណៈទាំងអស់ត្រូវបង្កើត គណៈកម្មការគ្រប់គ្រងមូលនិធិសាលារៀន (គ.ម.ស.) សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន (៥ឆ្នាំ) ផែនការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

យុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ដើម្បីគ្រប់គ្រងមូលនិធិសាលារៀនឱ្យបានល្អប្រសើរ និងស្របតាមចក្ខុវិស័យ បេសកកម្ម និងតម្រូវការក្នុងមូលដ្ឋានរបស់ខ្លួនឆ្លើយតបនឹងគោលនយោបាយ របស់ក្រសួង។

ដើម្បីឆ្លើយតបទៅនឹងគោលដៅខាងលើការរៀបចំផែនការនិងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (ម.ដ.ស) ត្រូវផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- កំណត់សមាសភាពចូលរួម ឱ្យបានច្បាស់លាស់ និងគ្រប់ភាគីពាក់ព័ន្ធ
- មានគោលនយោបាយ និងផែនការសាលារៀនច្បាស់លាស់ (ដោយមានកំណត់គម្រោងនិងសកម្មភាព ជាអាទិភាព)
- កំណត់សូចនាករសមិទ្ធផលជាប្រយោជន៍ដល់សាលារៀនសាធារណៈ(សូចនាករសមិទ្ធផល និងសូចនាករអនុវត្ត អាចវាស់វែងបាន អាចសម្រេចបានក្នុងរយៈពេលកំណត់)
- ត្រូវកំណត់តម្រូវការថវិកាសរុបប្រចាំឆ្នាំក្នុងរង្វង់ថវិកា ដែលបានបែងចែកតាមឆ្នាំនីមួយៗរបស់សាលារៀន

- ការវិភាជថវិកា

ការវិភាជន៍ថវិកា គឺជាដំណើរការបែងចែកថវិកាទៅតាមសកម្មភាពជាក់លាក់ និងខ្ទង់ថវិកាដោយអនុលោមតាមកាលវិភាគនៃការអនុវត្តផែនការសកម្មភាពនីមួយៗ។ ជាទូទៅ មូលនិធិដំណើរការសាលារៀន សាធារណៈត្រូវបែងចែកផ្អែកតាមឆ្នាំសារពើពន្ធ (ឆ្នាំថវិកា) ដែលមានរយៈពេល១២ ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ។ ថវិកាមូលនិធិដំណើរការសាលារៀនត្រូវបានផ្តល់ជូនសាលារៀន ដែលមានលក្ខណៈសម្បត្តិដូចដែលបានកំណត់ក្នុងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ឆ្នាំ២០១៨ ពោលគឺត្រូវមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន (៥ឆ្នាំ) ផែនការយុទ្ធសាស្ត្រថវិកា (៣ឆ្នាំ) ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

- ការអនុវត្តចំណូល និងចំណាយ

ការអនុវត្តចំណូល និងចំណាយ គឺជានីតិវិធីហិរញ្ញវត្ថុ និងគណនេយ្យសម្រាប់ប្រើប្រាស់ថវិកាឱ្យចំទិសដៅនិងមានប្រសិទ្ធភាព។ មូលនិធិដំណើរការសាលារៀនសាធារណៈ ទទួលបានពីប្រភពខាងក្រោម៖

- **ថវិការដ្ឋ៖** ត្រូវបានផ្តល់ជូនតាមនិយាម ដែលមានចែងក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពី គោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី។ ថវិកានេះ ត្រូវបានផ្ទេរចូលគណនីរបស់សាលារៀនផ្ទាល់តាមរយៈប្រព័ន្ធធនាគារជាប្រាក់រៀល ពីរដងក្នុងមួយឆ្នាំ គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនានៃឆ្នាំនីមួយៗ។

- **ថវិកាដៃគូ៖** ដៃគូអភិវឌ្ឍទាំងអស់ដែលចូលរួមជួយសាលារៀនសាធារណៈតាមរយៈមូលនិធិដំណើរការ សាលារៀនសាធារណៈ ត្រូវរៀបចំថវិកាដោយឡែក ឬយកតាមរូបមន្តថវិការដ្ឋ ដោយមានការឯកភាពពី ក្រសួងអប់រំ យុវជន និងកីឡា ពោលគឺត្រូវបានផ្ទេរចូលគណនីរបស់សាលារៀនផ្ទាល់តាមរយៈ ប្រព័ន្ធធនាគារជាប្រាក់រៀលពីរដងក្នុងមួយឆ្នាំគឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនា នៃឆ្នាំនីមួយៗ។
- **ថវិកាសហគមន៍៖** ដើម្បីចូលរួមលើកកម្ពស់គុណភាពអប់រំក្នុងសហគមន៍របស់ខ្លួនសាលារៀនកៀរគរថវិកាពីសហគមន៍ តាមរយៈការទាក់ទាញសហគមន៍ ឱ្យចូលរួមដំណើរការអភិវឌ្ឍសាលារៀន និងបង្ហាញឱ្យឃើញលទ្ធផលជាក់ស្តែង។
- **ថវិកាផ្សេងៗ៖** ប្រភពផ្សេងៗបានពីការលក់ផលិតផលផ្សេងៗ ផលិតផលស្នាដៃសិស្ស អាជីវកម្មនានារបស់សាលារៀននិងសកម្មភាព ឬព្រឹត្តិការណ៍សាលារៀន។ ថវិកាទាំងនេះត្រូវបញ្ចូលជាមូលនិធិដំណើរការសាលារៀនសាធារណៈដើម្បីបង្ហាញពីតម្លាភាពក្នុងការគ្រប់គ្រង។

គណៈគ្រប់គ្រងសាលារៀន រៀបចំគណនីរបស់សាលារៀននៅធនាគារ ដើម្បីជានាតម្លាភាព គណនេយ្យភាព រវាងសាលារៀន និងអ្នកពាក់ព័ន្ធទាំងអស់។ ដូចនេះ ប្រភពចំណូលទាំងអស់របស់សាលារៀន ត្រូវបានផ្ទេរចូលក្នុងគណនីរបស់សាលារៀនផ្ទាល់ ដោយមានរបាយការណ៍ច្បាស់លាស់។

- នីតិវិធីក្នុងការគ្រប់គ្រងការអនុវត្តចំណូល និងចំណាយ៖

**ការទទួលមូលនិធិ៖** រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ

**ការផ្ទេរថវិកា៖**

- រៀបចំបង្កាន់ដៃទទួលប្រាក់ និងផ្ទេរចូលក្នុងគណនីសាលារៀននៅធនាគារ
- ប្រកាសឥណទានធនាគារ បន្ទាប់ពីថវិកាចំណូលចូលក្នុងគណនី
- កត់ត្រារាល់ទិន្នន័យចូលក្នុងបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ និងចូលបញ្ជីបេឡាសាលារៀន

- ការដកសាច់ប្រាក់សម្រាប់ការចំណាយ៖

- រៀបចំបណ្ណបើក/ដកសាច់ប្រាក់ ឬមូលប្បទានបត្រ ឬបណ្ណប្រកាសពន្ធ (ធនាគារ) សម្រាប់ចំណាយតាមសកម្មភាពជាក់ស្តែង (តាមផែនការ)
- រៀបចំឯកសារសម្រាប់ទូទាត់ និងកត់ត្រាចំណូលបញ្ជីបេឡាសាលារៀនក្នុងបណ្ណចំណាយ។

សម្រាប់គោលការណ៍អនុវត្តការចំណាយថវិកាមូលនិធិសាលារៀនត្រូវបានកំណត់ការចំណាយទៅតាមមុខសញ្ញា និងតម្រូវការជាក់ស្តែងរបស់សាលារៀន(ផ្តោតលើកិច្ចគាំទ្រដំណើរការនិងការកែលម្អគុណភាពអប់រំ ផ្អែកតាមផែនការ) ដោយអនុលោមតាមប្រកាសអន្តរក្រសួង ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកា ក្រសួងអប់រំ យុវជន និងកីឡា។ នាយកសាលា ត្រូវរៀបចំសំណើសុំ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ចំណាយថវិកា និងបណ្ណចំណាយដោយមានភ្ជាប់ឯកសារគាំទ្រដោយមានចំណារឯកភាពពីគណៈកម្មការមូលនិធិសាលារៀន។ អ្នកស្នើសុំ ឬអ្នកអនុវត្ត សកម្មភាព ត្រូវរក្សាទុកឯកសារពាក់ព័ន្ធ ដើម្បីជាភស្តុតាងសម្រាប់ការទូទាត់ ( ឧ. បណ្ណចំណាយ សំណើសុំ ចំណាយ មូលប្បទានបត្រ វិក្កយបត្រ របាយការណ៍លទ្ធផល កំណត់ហេតុប្រគល់-ទទួល ទម្រង់សាកសួរតម្លៃចំនួន៣ សន្លឹកពីអ្នកផ្គត់ផ្គង់ តារាងវាយតម្លៃ-ល-)។

## ៧.៥ ផែនការរៀនសូត្រសិស្ស និងផែនការបង្រៀនរបស់គ្រូ

ដើម្បីឱ្យផែនការរៀនសូត្រសិស្ស និងផែនការបង្រៀនរបស់គ្រូបង្រៀនមានសក្តិសិទ្ធិភាព និងប្រសិទ្ធភាព អ្នកពាក់ព័ន្ធត្រូវ៖

១.គណៈគ្រប់គ្រងសាលារៀន ដឹកនាំនិងគ្រប់គ្រងការធ្វើតេស្តដើមឆ្នាំតាមការណែនាំ ដោយមានការចូលរួមពីអ្នកអាណាព្យាបាលសិស្ស និងគណៈកម្មការ គ្រប់គ្រងសាលារៀន ដើម្បីធានាបានគុណភាពលទ្ធផលតេស្ត ដោយមានការដឹងឮពីអាណាព្យាបាលសិស្សដោយផ្ទាល់។

២.គណៈគ្រប់គ្រងសាលារៀនផ្សព្វផ្សាយលទ្ធផលតេស្តនៅកម្រិតថ្នាក់ សម្រាប់មុខវិជ្ជានីមួយៗ នៅក្នុងសហគមន៍ ជាពិសេសនៅទីប្រជុំជន ដូចជា នៅវត្ត នៅសាលាឃុំ នៅផ្ទះមេភូមិ នៅផ្ទះគ្រូបង្រៀន នៅផ្ទះក្រុមប្រឹក្សាកុមារ/យុវជនសាលារៀន។ល។

៣.គណៈគ្រប់គ្រងសាលារៀន ធ្វើកិច្ចការជាមួយប្រធានក្រុមបច្ចេកទេស ក្នុងការរៀបចំថ្នាក់រៀនតាមកម្រិតសមត្ថភាពសិស្ស ABCDEF។

៤.គ្រូបន្ទុកថ្នាក់ដឹកនាំសិស្ស និងអ្នកអាណាព្យាបាលសិស្សផ្ទាល់ យកលទ្ធផលតេស្តដើមឆ្នាំមកពិគ្រោះដើម្បីឱ្យសិស្សបានកំណត់លទ្ធផលសិក្សាដំណាច់ឆ្នាំ តាមត្រីមាស និងប្រចាំខែ និងមានការដឹងឮ និងចូលរួមសម្រេចជាមួយកូន និងគ្រូបន្ទុកថ្នាក់។

៥.គ្រូបន្ទុកថ្នាក់ដឹកនាំការប្រជុំជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ដើម្បីបង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន សម្រាប់ជួយតាមដានការសិក្សារបស់កូនចៅ ការបង្រៀនរបស់គ្រូបង្រៀន និងជាពិសេសសម្រាប់ជួយដល់សិស្សមកពីគ្រួសារជួបការលំបាក និងការរៀបចំបរិស្ថានថ្នាក់រៀន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ទម្រង់ផែនការរបស់សិស្ស**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាល័យ**.......................................................

ផែនការសិក្សារបស់សិស្ស

ឆ្នាំសិក្សា២០២....-២០២....

| | | | | |
|---|---|---|---|---|
| ឈ្មោះសិស្ស | ៖ .............. | ភេទ | ៖ ........ | ថ្នាក់ទី៖ ៧.... |
| ស្ថានភាពគ្រួសារ | ៖ នៅជាមួយយាយតា ឪពុកម្ដាយចំណាកស្រុកធ្វើពលករនៅទីក្រុង (សិស្សជួបការលំបាក) | | | |
| សាលារៀន | ៖ ..................... | ខេត្ត | ៖ ..................... | |
| ឈ្មោះមាតាបិតា | ៖ ..................... | លេខទូរស័ព្ទ | ៖ ...................... | |
| ឈ្មោះគ្រូបន្ទុកថ្នាក់ | ៖ ..................... | លេខទូរស័ព្ទ | ៖ ..................... | |

| | | | | | |
|---|---|---|---|---|---|
| ***កម្រិតពិន្ទុ៖*** *Fក្រោម 50ពិន្ទុ* | *Eពី51-60ពិន្ទុ* | *D ពី61-70ពិន្ទុ* | *Cពី71-79ពិន្ទុ* | *Bពី80-89ពិន្ទុ* | *Aពី90-100ពិន្ទុ* |
| ***កម្រិតពិន្ទុ៖*** *Fក្រោម 25ពិន្ទុ* | *Eពី 25-29ពិន្ទុ* | *D ពី30-34ពិន្ទុ* | *Cពី35-39ពិន្ទុ* | *Bពី40-44ពិន្ទុ* | *Aពី45-50ពិន្ទុ* |

រូបថតសិស្ស

# មុខវិជ្ជាគោល ភាសាខ្មែរ និងគណិតវិទ្យា

| កម្រិតថ្នាក់ | មុខវិជ្ជាភាសាខ្មែរ កម្រិតលទ្ធផលសិក្សានៅដើមឆ្នាំ | | | | | | កម្រិតពិន្ទុតាមត្រីមាស | | | | កម្រិតពិន្ទុនៅចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|
| | ១. ស្គាល់សូរ | ២. ស្គាល់តួអក្សរ | ៣. អានស្ទាត់ | ៤. វាក្យសព្ទ | ៥. អានយល់ន័យ | **កម្រិតពិន្ទុនៅដើមឆ្នាំ** | ត្រីមាស ទី១ | ត្រីមាស ទី២ | ត្រីមាស ទី៣ | ត្រីមាស ទី៤ | |
| ទី៧ | | | | | | F | F | D | C | B | B |
| ទី៦ | | | | F | E | | E | D | C | C | B |
| ទី៥ | | | E | | | | E | D | C | C | B |
| ទី៤ | | C | | | | | C | C | B | B | A |
| ទី៣ | F | | | | | | E | D | C | B | A |

| កម្រិតថ្នាក់ | មុខវិជ្ជាគណិតវិទ្យា កម្រិតលទ្ធផលសិក្សានៅដើមឆ្នាំ | | | | | | កម្រិតពិន្ទុតាមត្រីមាស | | | | កម្រិតពិន្ទុនៅចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|
| | A | B | C | D | E | F | ត្រីមាស ទី១ | ត្រីមាស ទី២ | ត្រីមាស ទី៣ | ត្រីមាស ទី៤ | |
| ទី៧ | | | | | | | | | | | |
| ទី៦ | | | | | | | | | | | |
| ទី៥ | | | | | | | | | | | |
| ទី៤ | | | | | | | | | | | |
| ទី៣ | | | | | | | | | | | |

# មុខវិជ្ជានាំមុខ១០ (គ្រប់ថ្នាក់ពីថ្នាក់ទី៧ ដល់ទី១២)

| មុខវិជ្ជា | កម្រិតពិន្ទុនៅដើមឆ្នាំ | លទ្ធផលពិន្ទុសម្រេចបានតាមខែ ផ្អែកលើផែនការរៀនសូត្រប្រចាំខែ | | | | | | | | | | | | | | | | | | | | កម្រិតពិន្ទុនៅចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខែ១ | ជាក់ស្តែង | ខែ២ | ជាក់ស្តែង | ខែ៣ | ជាក់ស្តែង | ខែ៤ | ជាក់ស្តែង | ខែ៥ | ជាក់ស្តែង | ខែ៦ | ជាក់ស្តែង | ខែ៧ | ជាក់ស្តែង | ខែ៨ | ជាក់ស្តែង | ខែ៩ | ជាក់ស្តែង | ខែ១០ | ជាក់ស្តែង | |
| ១.ខ្មែរ | F | F | F | E | E | E | | E | | D | | D | | D | | D | | C | | C | | B |
| ២.គណិត | F | F | F | F | E | E | | E | | E | | E | | D | | D | | C | | C | | B |
| ៣.អង់គ្លេស | F | F | F | F | F | F | | E | | E | | E | | E | | D | | D | | D | | C |
| ៤.រូបវិទ្យា | F | E | E | E | F | E | | E | | E | | E | | D | | D | | D | | C | | C |
| ៥.គីមីវិទ្យា | F | F | F | F | F | E | | E | | E | | E | | D | | D | | D | | C | | C |
| ៦.ជីវវិទ្យា | F | E | E | E | D | E | | E | | E | | E | | D | | D | | D | | C | | C |
| ៧.ផែនដីវិទ្យា | F | F | F | F | D | E | | E | | E | | E | | D | | D | | D | | C | | C |
| ៨.ពលរដ្ឋវិជ្ជា | F | F | F | F | D | E | | E | | E | | D | | D | | D | | C | | C | | C |
| ៩.ប្រវត្តិវិទ្យា | F | F | F | E | E | E | | E | | D | | D | | D | | C | | C | | B | | B |
| ១០.ភូមិវិទ្យា | F | E | E | E | D | E | | E | | D | | D | | D | | D | | C | | C | | B |

ថ្ងៃ............. ខែ....... ឆ្នាំ............... ព.ស ២៥៦....

........... ថ្ងៃទី...... ខែ ...... ឆ្នាំ២០២.........

បានឃើញ និងឯកភាព
គ្រូទទួលបន្ទុកថ្នាក់

ហត្ថលេខាឬ
ស្នាមមេដៃមាតាបិតា
ឬអ្នកអាណាព្យាបាលសិស្ស

ហត្ថលេខា / ឈ្មោះសិស្ស

## ៧.៦ ក្របខណ្ឌការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែម

### ១- កម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែម

#### ក. មុខវិជ្ជាជំនាញស្នែម

ការកំណត់មុខជំនាញសម្រាប់បណ្តុះបណ្តាល សាលារៀនត្រូវសហការជាមួយភាគីពាក់ព័ន្ធ ត្រូវសិក្សាជំនាញស្របទៅតាមតម្រូវការអ្នកសិក្សា និងទីផ្សារការងារ តាមធនធានដែលមាននៅក្នុងសហគមន៍។ មុខវិជ្ជាជំនាញស្នែមរួមមាន៖ ផ្នែកកុំព្យូទ័រ ផ្នែកអគ្គិសនី ផ្នែកមេកានិច ផ្នែកអេឡិចត្រូនិច ផ្នែកបសុវប្បកម្ម ផ្នែកក្បេត្រសាស្រ្ត ផ្នែកកែច្នៃអាហារ ផ្នែកអប់រំបំណិនជីវិត ផ្នែកសំណង់ ផ្នែកសិប្បកម្ម ឬជំនាញថ្មីផ្សេងទៀតដែលមិនមាននៅក្នុងឧបសម្ព័ន្ធ។

#### ខ. រយៈពេលសិក្សា

ពេលវេលា និងម៉ោងសិក្សាសម្រាប់មុខជំនាញនីមួយៗ ត្រូវរៀបចំដោយមានការឯកភាពគ្នារវាងសាលារៀន និងអ្នកផ្តល់សេវាបណ្តុះបណ្តាល។ សាលារៀន និងអ្នកផ្តល់សេវាបណ្តុះបណ្តាលអាចរៀបចំម៉ោងសិក្សាបន្ថែមច្រើនជាងម៉ោងសិក្សាតាមការណែនាំ ដែលមានចែកក្នុងកម្មវិធីសិក្សានេះ ដោយយោងទៅតាមតម្រូវការជាក់ស្តែងរបស់អ្នកសិក្សានិងស្ថានភាពនៃអ្នកផ្តល់សេវាបណ្តុះបណ្តាលដើម្បីឈានសម្រេចគោលដៅបណ្តុះបណ្តាលជំនាញ។

**គ. ក្របខ័ណ្ឌពេលវេលានិងកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែមមាន៖**

- ជំនាញសិក្សារយៈពេល ៣ខែ ចាប់ពី ៤៥ ▼ ៥០ ម៉ោង ស្មើ ២ក្រេឌីត
- ជំនាញសិក្សារយៈពេល ៦ខែ ចាប់ពី ៩០ ▼ ១០០ ម៉ោង ស្មើ ៤ក្រេឌីត
- ជំនាញសិក្សារយៈពេល ៩ខែ ចាប់ពី ១៣៥ ▼ ១៥០ ម៉ោង ស្មើ ៦ក្រេឌីត
- ជំនាញសិក្សារយៈពេល ១២ខែ ចាប់ពី ១៨០ ▼ ២០០ ម៉ោង ស្មើ ៨ក្រេឌីត

**កម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែមនេះ បែងចែកជាពីរផ្នែកគឺ ផ្នែកទ្រឹស្តីនិងផ្នែកប្រតិបត្តិ៖**

- ផ្នែកទ្រឹស្តី រយៈពេលសិក្សាមួយក្រេឌីតស្មើ១៥ម៉ោង
- ផ្នែកប្រតិបត្តិ រយៈពេលសិក្សាមួយក្រេឌីតស្មើ៣០ម៉ោង

**សម្គាល់៖**

- អ្នកសិក្សារៀនក្នុង១សប្តាហ៍៤ម៉ោង ក្នុង១ថ្ងៃ ១ឬ២ម៉ោង អាចបត់បែនតាមស្ថានភាពជាក់ស្តែង

- កាលវិភាគសិក្សាត្រូវមានការឯកភាពគ្នារវាងគណៈកម្មការ គ្រូបណ្តុះបណ្តាល និងសិស្ស ដែលទទួលការបណ្តុះបណ្តាល

២- វិធីសាស្ត្របណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម

ការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែម ត្រូវផ្តោតលើការអនុវត្តជាក់ស្តែងច្រើនជាងបទបង្ហាញក្នុងថ្នាក់ (ទ្រឹស្តីយ៉ាងច្រើន៣០% និងប្រតិបត្តិយ៉ាងតិច៧០%) រហូតដល់មានសមត្ថភាពឆ្លើយតបទៅនឹងលក្ខខណ្ឌបានកំណត់ក្នុងកម្មវិធី ដើម្បីធានាឱ្យសិស្សទទួលបាននូវសមត្ថភាពជំនាញជាក់លាក់សម្រាប់លើកកម្ពស់ជីវភាពរស់នៅ និងជំរុញទឹកចិត្តបន្តការសិក្សាជំនាញបន្ថែមផ្នែកស្នែមនៅឧត្តមសិក្សា។ ការសិក្សាទ្រឹស្តីផ្សារភ្ជាប់ទៅនឹងអនុវត្តជាក់ស្តែងក្នុងបន្ទប់ពិសោធន៍ បន្ទប់ប្រតិបត្តិ រោងជាង កសិដ្ឋាន ការដ្ឋាន ឬកន្លែងប្រកបអាជីវកម្មផ្ទាល់របស់គ្រូបណ្តុះបណ្តាល ដោយផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងការប្រតិបត្តិ ឬជីវភាពរស់នៅប្រចាំថ្ងៃ។ ការបណ្តុះបណ្តាលអាចប្រើប្រាស់វិធីសាស្ត្រចម្រុះ ដើម្បីជំរុញឱ្យ ការសិក្សាតាមបែបសកម្ម និងមានភាពជាក់ស្តែង។ ការបណ្តុះបណ្តាលនេះ ផ្តល់ឱ្យអ្នកសិក្សាធ្វើការងារជាបុគ្គល ឬជាក្រុម ដើម្បីពិភាក្សា វិភាគ និងរិះរកបច្ចេកទេសថ្មីៗសម្រាប់ជំនាញបន្ថែមផ្នែកស្នែម ដែលជាតម្រូវការ ការងារនៅក្នុងសហគមន៍ផ្ទាល់។ ការទស្សនាវីដេអូ និងការធ្វើទស្សនកិច្ចសិក្សាគួរត្រូវបានជំរុញអនុវត្តដើម្បីបង្កើតគំនិតគ្រប់គ្រងអាជីវកម្ម និងទទួលបាននូវបទពិសោធ។

ការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែមផ្តោតលើគោលការណ៍នៃការបណ្តុះបណ្តាលដូចខាងក្រោម៖

- **គោលការណ៍ទី១**

ការបណ្តុះបណ្តាល គឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យពួកគេទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្រចម្រុះស្របតាមស្ថានភាពអ្នកសិក្សា។

- **គោលការណ៍ទី២**

ការបណ្តុះបណ្តាល គឺជាសកម្មភាពជួយ និងលើកទឹកចិត្តអ្នកសិក្សាឱ្យចេះរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីឈ្វេងយល់ ធ្វើវិចារ សហការ អង្កេត និងការអនុវត្តចំណេះដឹងសម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ ។

- **គោលការណ៍ទី៣**

ការបណ្តុះបណ្តាលត្រូវបន្តពង្រឹង និងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រលាញ់ និងផ្តល់តម្លៃដល់ការសិក្សាជំនាញបន្ថែមផ្នែកស្ទែម និងត្រូវផ្តោតសំខាន់លើការប្រតិបត្តិជាក់ស្តែងតាមជំនាញនីមួយៗ។

- **គោលការណ៍ទី៤**

ការបណ្តុះបណ្តាលត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារៈឧបទេស រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្បូរបែប។

*ឧបសម្ព័ន្ធទី៩៖ ការអប់រំស្ទែម*

៣- ការអប់រំស្ទែម អាចបញ្ចូលជាមួយក្របខណ្ឌការអនុវត្ត

ក. ទិដ្ឋភាពទូទៅនៃការអប់រំ

ការអប់រំសាកលមានការវិវត្តន៍ជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនខាងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងតម្រូវការសង្គមជាពិសេសបដិវត្តកម្ម៤.០ និងបំណិនសតវត្សរ៍ទី២១។ នៅក្នុងយុគសម័យនៃបដិវត្តឧស្សាហកម្ម៤.០ និន្នាការនៃការអប់រំរបស់សកលលោកគឺផ្តោតសំខាន់ទៅលើការអប់រំជំនាញនវានុវត្តន៍ និងបច្ចេកវិទ្យា ដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព ពោលគឺការបណ្តុះបណ្តាលសិស្សានុសិស្ស ឱ្យក្លាយជាពលរដ្ឋផលិត។

ដើម្បីសម្រេចបាននូវគោលដៅជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញលើការអនុវត្តការរៀន និងបង្រៀនស្ទែម ដើម្បីជួយឱ្យអ្នកសិក្សាមានបំណិនផ្នែកនវានុវត្តក្នុងគោលដៅអភិវឌ្ឍសមត្ថភាពអ្នកសិក្សាឱ្យក្លាយជាអ្នកផលិតប្រកបដោយឧត្តមានុវត្តន៍។

ការសិក្សាស្ទែមនៅក្នុងថ្នាក់រៀនជាលំនាំនៃការរៀននិងបង្រៀនរបស់គ្រូបង្រៀននិងសិស្សានុសិស្ស ដើម្បីផ្តល់ឱ្យសិស្សនូវបំណិនច្នៃប្រតិដ្ឋ និងនវានុវត្តន៍។ ការច្នៃប្រតិដ្ឋ និងការរិះរកនូវយុទ្ធវិធីបង្រៀនគឺជាភារកិច្ចអាជីពដែលគ្រូបង្រៀនត្រូវអនុវត្តជាប្រចាំថ្ងៃដើម្បីលើកកម្ពស់ភាពឆ្លើយតប និងសក្តិសិទ្ធិភាព។ បើគ្រូបង្រៀនចេះធ្វើពិសោធន៍ នោះពិតជាការប្រសើរ ប៉ុន្តែភាពប្រសើរជាងនេះទៀតនោះ គឺការរិះរកវិធីសាស្ត្រដើម្បីដឹកនាំសិស្សឱ្យចេះរៀបចំដំណើរការពិសោធនោះបានដោយខ្លួនឯងប្រកបដោយសិល្បៈ។

ចំណុចចាប់ផ្តើមដំបូងសម្រាប់គ្រូបង្រៀនគឺវិធីសាស្ត្របង្រៀន។ មានវិធីសាស្ត្របង្រៀនជាច្រើនដែលគ្រូបង្រៀនអាចយកទៅប្រើប្រាស់បាន រួមមានវិធីសាស្ត្របង្រៀនតាមបែបស្ទែម ( STEM Classroom

Activities) វិធីសាស្ត្របង្រៀនតាមបែបវិធីវិទ្យាសាស្ត្រ វិធីសាស្ត្របង្រៀនបែបរិះរក (Inquiry-Based Learning) វិធីសាស្ត្របង្រៀនតាមបែបដោះស្រាយបញ្ហា (Problem-Based Learning) វិធីសាស្ត្របង្រៀនបែបគម្រោង (Project-Based Learning) ជាដើម។ តាមរយៈវិធីសាស្ត្របង្រៀនខាងលើនេះ គ្រូបង្រៀនមានសមត្ថភាពគ្រប់គ្រាន់ និងសម្បូរបែបសម្រាប់ដឹកនាំថ្នាក់រៀនពិសោធន៍ ឬថ្នាក់រៀនស្ទែម។ កិច្ចការបន្ទាប់របស់គ្រូបង្រៀនគឺការផលិត និងការច្នៃប្រតិដ្ឋ បង្កើតនូវឧបករណ៍ងាយៗសម្រាប់គាំទ្រដល់ថ្នាក់រៀនរបស់ខ្លួន។ ការប្រើប្រាស់សម្ភារៈពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍គឺជាផ្នែកមួយដែលគាំទ្រដល់ការអប់រំស្ទែម។ សកម្មភាពថ្នាក់រៀនស្ទែម គឺជារបត់ថ្មីមួយទៀតសម្រាប់លោកគ្រូអ្នកគ្រូមុខវិជ្ជាវិទ្យាសាស្ត្រដែលតម្រូវឱ្យលោកគ្រូអ្នកគ្រូប្រើយន្តការអន្តរកម្មមុខវិជ្ជា (Inter-disciplines) រវាងមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ដែលមានសារៈសំខាន់ជួយសិស្សទៅរកការដោះស្រាយបញ្ហាប្រកបដោយវិទ្យាសាស្ត្រ ការសហការក្រុម និងភាពទទួលខុសត្រូវ។ ការអនុវត្តពិសោធន៍ជាក់ស្តែង មានសារៈសំខាន់ចំពោះការសិក្សាហ្វឹកហាត់របស់សិស្ស។ សិស្សានុសិស្សទទួលបាននូវការអភិវឌ្ឍជំនាញដោះស្រាយបញ្ហា ដើម្បីឆ្លើយតបទៅនិងបាតុភូតធម្មជាតិទាំងនៅក្នុងថ្នាក់រៀននិងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ការអភិវឌ្ឍសមត្ថភាពផ្នែកស្រាវជ្រាវលើបច្ចេកវិទ្យា និងនវានុវត្តន៍ ជាយន្តការដ៏សំខាន់នៅក្នុងយុគសម័យបច្ចេកវិទ្យានៃពិភពលោកដែលកំពុងមានការវិវត្តយ៉ាងឆាប់រហ័ស ទៅលើបញ្ញាសិប្បនិម្មិត (Artificial Intelligence) រួមទាំងបច្ចេកវិទ្យាថ្មីៗដែលកំពុងបម្រើឱ្យសេចក្តីត្រូវការរបស់មនុស្សលោក។ សមិទ្ធផលបច្ចេកវិទ្យាថ្មីៗ ដែលជាតម្រូវការចាំបាច់លើគ្រប់វិស័យរួមមានដូចជា វិស័យសេដ្ឋកិច្ច យោធា ឧស្សាហកម្ម សុខាភិបាល វេជ្ជសាស្ត្រ កសិកម្ម ឧស្សាហកម្មអាហារ សង្គមកិច្ច សាសនា សិល្បៈ និងវប្បធម៌ជាដើមគឺសុទ្ធសឹងពឹងផ្អែកទៅលើការអប់រំ និងការបណ្តុះបណ្តាល។

ការអនុវត្តធ្វើពិសោធន៍ និងដឹកនាំសិស្សធ្វើពិសោធជាប្រចាំគឺជាទម្លាប់ដែលឆ្ពោះទៅរកការផ្លាស់ប្តូរនូវសកម្មភាពរៀន និងបង្រៀនបែបសកម្ម ដោយផ្តល់ឱ្យសិស្សានុសិស្សនូវការគិតស៊ីជម្រៅតាមបែបវិទ្យាសាស្ត្រទៅលើបាតុភូតធម្មជាតិដែលកើតឡើងនៅជុំវិញខ្លួនពួកគេ។ ទម្លាប់នេះបន្តិចម្តងៗនឹងនាំឱ្យសិស្សានុសិស្ស មានបំណិនវិទ្យាសាស្ត្រគឺការគិតបែបតក្កវិជ្ជា ការសង្កេតច្បាស់លាស់និងការដោះស្រាយវិភាគបញ្ហា ឬបាតុភូតប្រកបដោយភាពទន់ភ្លន់ និងប្រាកដនិយម។

ការឈ្វេងយល់នូវរបៀបនៃការគិតទៅលើវត្ថុបំណងមេរៀន ការបង្កើតនូវសំណួរគន្លឹះ ការច្នៃប្រឌិតវិធីសាស្ត្របង្រៀនស្ទែម ការសរសេរសន្លឹកកិច្ចការសម្រាប់សិស្ស របាយការណ៍ស្ទែម និងយន្តការវាយតម្លៃ គឺជាអ្វីដែលគ្រូបង្រៀនអាជីពត្រូវមាន និងប្រតិបត្តិជាប្រចាំថ្ងៃ។ ភាពខ្វះចន្លោះនៃយុទ្ធវិធី និងវិធីសាស្ត្រ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ធ្វើពិសោធន៍ ឬស្ទែមដែលមាននៅក្នុងសៀវភៅសិក្សាគោល ឬឯកសារគាំទ្រការរៀន និងបង្រៀនពិសោធន៍ និងស្ទែមផ្សេងៗទៀត ជាមូលហេតុមួយ ក្នុងចំណោមឧបសគ្គផ្សេងៗទៀតដែលរារាំងដល់ការអភិវឌ្ឍបំណិនវិទ្យាសាស្ត្រនៅតាមវិទ្យាល័យនានា ក្នុងពេលកន្លងមក។ ហេតុដូច្នេះ ការផលិតឯកសារសៀវភៅណែនាំ អ៊ែប និងវីដេអូពិសោធន៍ និងស្ទែមបន្ថែមទៀត គឺជាការចាំបាច់ ដើម្បីជួយដល់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សនៅក្នុងដំណើរការរៀន និងការបង្រៀន ស្ទែមឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់។

ខ. តើការអប់រំស្ទែមជាអ្វី?

ការអប់រំ STEM (Science Technology Engineering and Mathematics) គឺជាដំណើរការនៃការរៀន និងបង្រៀនដោយផ្តោតទៅលើការបញ្ចូលគ្នានៃមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ កម្មវិធីនេះផ្តោតទៅលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាដែលរួមមាន៖ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា និងបរិស្ថានវិទ្យា។ ដោយឡែកសម្រាប់មុខវិជ្ជាបច្ចេកវិទ្យា និងវិស្វកម្ម ពុំត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិបានទូលំទូលាយនៅឡើយ។ ប៉ុន្តែការអនុវត្តនូវមុខវិជ្ជាវិស្វកម្ម និងបច្ចេកវិទ្យានេះ អាចរំលេចចេញនៅក្នុងការអនុវត្តពិសោធទៅតាមបាតុភូតជាក់ស្តែង។

ក្នុងក្របខណ្ឌនៃការរៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ក៏ទាមទារឱ្យមានការបញ្ចូលនូវកម្មវិធីអប់រំ STEM ផងដែរ ដោយផ្តោតលើបាតុភូតធម្មជាតិ(Real World Phenomena) និងការពិសោធជាក់ស្តែង(Scientific Experiment)។ បន្ថែមលើនេះទៀត វិស័យបច្ចេកវិទ្យា ដូចជាការប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍ឌីជីថលផ្សេងៗក៏ជាផ្នែកមួយនៃកម្មវិធីអប់រំ STEM ផងដែរ ព្រោះវាបានរំលេចនូវភាពជាប់ទាក់ទងគ្នានៃផលិតផលរបស់វិស័យបច្ចេកវិទ្យា។ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលការអប់រំ STEM ក៏រាប់បញ្ចូលទាំងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាផងដែរ។ ការអប់រំស្ទែមក៏បានជំរុញនូវការឈ្វេងយល់ឱ្យបានស៊ីជម្រៅពីរបៀបដែលវត្ថុ ឬអង្គធាតុមួយដំណើរការដោយប្រើបច្ចេកវិទ្យា និងវិស្វកម្មនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ បំណិនវិស្វកម្មត្រូវបានរំលេចឡើងនៅក្នុងដំណើរការដោះស្រាយបញ្ហារបស់សិស្ស ដើម្បីបង្កើតផលិតផលប្រកបដោយនវានុវត្តន៍។

គ. សារៈសំខាន់នៃការអប់រំស្ទែម

លក្ខណៈសំខាន់របស់ STEM គឺការសង្កេតលើបាតុភូតធម្មជាតិ ដែលសិស្សានុសិស្សបានជួបប្រទះក្នុងសកម្មភាពនៃជីវិតរស់នៅប្រចាំថ្ងៃ ដោយមានការពន្យល់ ឬបកស្រាយតាមបែបវិទ្យាសាស្ត្រ ដើម្បីឆ្ពោះទៅរកការបង្កើតនូវផលិតផលថ្មី។ លក្ខណៈពិសេសមួយទៀតរបស់ស្ទែមគឺសិស្សសិក្សា ឬពន្យល់

បាតុភូតធម្មជាតិដោយប្រើប្រាស់អន្តរមុខវិជ្ជាដើម្បីដោះស្រាយបញ្ហា។ ដូច្នេះ វាធ្វើឱ្យមានភាពងាយស្រួលក្នុងការផ្សារភ្ជាប់ចំណេះដឹងនិងបទពិសោធពីមុនទៅនឹងបាតុភូតនៅក្នុងបញ្ញត្តិគោល(Core Idea) ដែលធ្វើឱ្យការសិក្សាវិទ្យាសាស្ត្រកាន់តែងាយយល់ ហើយការរៀនសូត្រនៅក្នុងថ្នាក់រៀនក៏បានផ្សារភ្ជាប់ទៅនឹងទេពកោសល្យពីធម្មជាតិរបស់សិស្ស។ ម៉្យាងទៀត ការណែនាំអំពីការងារពិសោធន៍អាចផ្តល់ឱកាសឱ្យសិស្ស និងជំរុញសិស្សឱ្យមានចំណាប់អារម្មណ៍លើមុខវិជ្ជាវិទ្យាសាស្ត្រ និងអន្តរមុខវិជ្ជានៅក្នុងដំណើរការមេរៀនក្នុងថ្នាក់ផ្ទាល់។ សកម្មភាព STEM ជំរុញសិស្សានុសិស្សក្នុងការសង្កេតដោយអនុញ្ញាតឱ្យពួកគេទទួលបានការយល់ដឹងកាន់តែប្រសើរអំពីបញ្ញត្តិគោល(Core Idea)។ លំនាំនៃការបង្រៀន និងរៀនវិមាត្របី(បញ្ញត្តិគោល អន្តរមុខវិជ្ជានិងការអនុវត្ត)នៃការអប់រំស្ទែម នាំឱ្យមានភាពប្រសើរឡើងនូវគុណភាពវាយតម្លៃលើការអនុវត្ត និងលទ្ធផលតេស្តរបស់សិស្សសម្រាប់ក្របខណ្ឌសាលារៀន។

ចំណុចគោលសំខាន់ធំៗទាំងបីខាងលើនេះ អាចបង្កើតបានជាលក្ខណៈស្តង់ដាចំនួន១៥ចំណុចនៃគោលវិធីអប់រំ STEM ដែលតែងតែជួបប្រទះនៅពេលសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបវិមាត្របី។ លក្ខណៈស្តង់ដាទាំងនេះ គួរតែយកទៅប្រើក្នុងកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិរបស់ក្រសួងអប់រំ យុវជន និងកីឡា។ តាមរយៈវិធីនេះ ការអនុវត្តវិធីអប់រំស្ទែម(STEM) មិនត្រឹមតែជំរុញឱ្យសិស្សានុសិស្សកាន់តែចង់រៀនប៉ុណ្ណោះទេ តែក៏ជួយឱ្យពួកគេមានលទ្ធភាពអភិវឌ្ឍគំនិតច្នៃប្រឌិដ្ឋ និងបង្កើតថ្មីដោយខ្លួនឯង ព្រមទាំងបង្កើនការរិះគិតបានកាន់តែស៊ីជម្រៅ។ ជាទូទៅ ការរៀនតែទ្រឹស្តីមួយមុខ(វិមាត្រមួយ) សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ គឺធ្វើឱ្យសិស្សខ្វះខាតនូវការរិះគិត និងគំនិតបង្កើតថ្មី បើធៀបទៅនឹងការរៀនតាមកម្មវិធីអប់រំស្ទែម(STEM)។ ការអនុវត្តកម្មវិធីអប់រំស្ទែម(STEM) បានផ្តល់ឱកាសឱ្យសិស្សានុសិស្សបានចូលរួមច្រើនយ៉ាង ដែលអាចទាក់ទាញចំណាប់អារម្មណ៍ពួកគាត់។ សារៈសំខាន់មួយទៀតនោះគឺប្រសិនបើ សិស្សានុសិស្សរីករាយក្នុងការអនុវត្តពិសោធន៍លើមុខវិជ្ជាវិទ្យាសាស្ត្រ ពួកគេក៏មានមូលដ្ឋានកាន់តែរឹងមាំក្នុងការជ្រើសរើសមុខវិជ្ជា ឬមុខជំនាញច្បាស់លាស់ ដើម្បីបន្តការសិក្សានៅកម្រិតសាលាបច្ចេកទេស និងឧត្តមសិក្សាផងដែរ។ ម៉្យាងវិញទៀត ការសិក្សាសង្កេតទៅលើបាតុភូតជាក់ស្តែងដែលមានការសហការ និងការពិភាក្សាគ្នាទាមទារឱ្យសិស្សានុសិស្សចេះរៀនធ្វើការងារជាក្រុមប្រកបដោយប្រសិទ្ធភាពដែលផ្តល់អត្ថប្រយោជន៍ ជាពិសេសសម្រាប់សិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដើម្បីទទួលបាននូវឱកាសរៀនសូត្រពីគ្នាទៅវិញទៅមក ឬពីគ្រូបង្រៀនផ្ទាល់។ ជារួប ការអនុវត្តលើមុខវិជ្ជាវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាដោយប្រើនូវវិធីសាស្ត្របែបពហុគំនិត និងមានភាពអន្តរកម្មឥតឈប់ឈរជំរុញឱ្យមាននិរន្តរភាពនៃទំនាក់ទំនងរវាងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និងការអភិវឌ្ឍលើជំនាញកម្រិតខ្ពស់ឆ្លើយតបទៅនឹងការត្រៀមខ្លួនសម្រាប់ទីផ្សារការងារនៅក្នុងតំបន់និងសកលលោករបស់យុវជន



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជំនាន់ក្រោយ។ បំណិន និងជំនាញការងារបន្ថែមក៏ទាមទារឱ្យមានការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបវិមាត្របី ដើម្បីឱ្យសិស្សទទួលបានជោគជ័យក្នុងការប្រកួតប្រជែងរកការងារ និងឱកាសស្វែងរកអាហារូបករណ៍ទាំងក្នុងតំបន់ និងសកលលោក។ ប្រទេសកម្ពុជាបាននឹងកំពុងផ្តល់ឱកាសអភិវឌ្ឍដល់សិស្សស្មើៗគ្នាលើកម្មវិធីប្រកួតប្រជែងសមត្ថភាពសិស្សកម្រិតអន្តរជាតិលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រដែលហៅកាត់ថា PISA (Program for International Student Assessment) ដែលជាកម្មវិធីលំដាប់អន្តរជាតិមួយត្រូវបានរៀបចំឡើងរៀងរាល់បីឆ្នាំម្តង ដោយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (Organization for Economic Co-operation & Development - OECD)។

ការរៀន និងបង្រៀនបែបវិធីអប់រំស្ទែម (STEM)មានសក្តានុពលយ៉ាងខ្លាំងក្នុងការជួយឱ្យសម្រេចបានផែនការអភិវឌ្ឍប្រកបដោយចីរភាព (Sustainable Development Goals – SDG 4) និងផែនទីចង្អុលផ្លូវលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់កម្ពុជានៅឆ្នាំ២០៣០ (Cambodia's Science, Technology & Innovation Roadmap 2030) ដោយជួយធ្វើឱ្យកើនឡើងនូវយន្តការសេដ្ឋកិច្ចសហគមន៍ និងសេដ្ឋកិច្ចសង្គមជាតិ តាមរយៈភាពសកម្មនៃការសិក្សារបស់សិស្សានុសិស្សនៅកម្រិតមធ្យមសិក្សា។ ការអប់រំស្ទែម (STEM) ធានាថាសិស្សនៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិទទួលបាននូវចំណេះដឹងវិទ្យាសាស្ត្រ វិស្វកម្ម និងជំនាញបច្ចេកទេស រួមទាំងជំនាញរិះគិតស៊ីជម្រៅ ដើម្បីធ្វើការដោះស្រាយបញ្ហាប្រឈមក្នុងសហគមន៍និងពិភពលោកដែលរួមចំណែកគាំពារដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

ឃ. តើស្ទែមត្រូវបានប្រើក្នុងវិស័យអ្វីខ្លះ?

ជាទូទៅ ស្ទែមត្រូវបានញែកចេញជាបីវិស័យធំៗ ដែលក្នុងនោះរួមមាន៖ ស្ទែមក្នុងវិស័យអប់រំ (STEM Education) ស្ទែមក្នុងវិស័យអនុវត្ត (STEM Applied) និងស្ទែមក្នុងវិស័យឌីជីថល ឬស្រាវជ្រាវ (STEM Digital)។

វិស័យនីមួយៗខាងលើនេះ មានទិសដៅ និងផ្តល់សារៈសំខាន់ទៅលើវត្ថុបំណងខុសៗគ្នា។

-ស្ទែមក្នុងវិស័យអប់រំ (STEM Education)

ស្ទែមក្នុងវិស័យអប់រំជាប្រភេទនៃការអប់រំបែបបរិយាបន្ន ដោយមានការផ្តោតលើទំនាក់ទំនងរវាងសម្បទាទាំងបួន (វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា) និងចំណេះដឹងទ្រឹស្តីនៃ STEM ក្នុងថ្នាក់រៀន ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃក្នុងសហគមន៍ ពិភពធម្មជាតិ ឬបាតុភូតធម្មជាតិ។ ឧទាហរណ៍៖

-ការប្រើប្រាស់ចំណេះដឹងនៃការរីកមាឌរបស់អង្គធាតុរាវ ទៅនឹងបញ្ញត្តិនៃការបង្កើតទែម៉ូម៉ែត្រ

អាល់កុល ឬទែម៉ូម៉ែត្របារត

-ការប្រើប្រាស់ទ្រឹស្តីបាតុភូតអូស្មូសក្នុងមុខវិជ្ជាជីវវិទ្យាសម្រាប់បង្កើតឧបករណ៍លាងឈាម

-ការប្រើប្រាស់ទ្រឹស្តីបំប្លែងថាមពលពន្លឺទៅជាថាមពលអគ្គិសនី ដោយប្រើប្រព័ន្ធផ្ទាំងសូឡា

-ការប្រើប្រាស់ទ្រឹស្តីតារាសាស្ត្រនៃមុខវិជ្ជាផែនដីវិទ្យាសម្រាប់វិស័យអវកាស

-ការប្រើប្រាស់ទ្រឹស្តីពីតាគ័រនៃមុខវិជ្ជាគណិតវិទ្យាសម្រាប់គណនាចម្ងាយខ្លីបំផុតនៃផ្លូវជាដើម។

ការអប់រំ STEM ជំរុញឱ្យមានការបង្កើតគំនិត និងចំណេះដឹងថ្មី(Update, Upgrade and Innovate) តាមរយៈការបណ្តុះបណ្តាលនូវបំណិនរាងកាយ និងបំណិនបញ្ញាចាប់តាំងពីថ្នាក់មត្តេយ្យសិក្សាដែលមានសារៈសំខាន់ក្នុងដំណាក់កាលដំបូងនៃការអប់រំនៅក្នុងបរិបទសកលភាវូបនីយកម្ម។

-ស្ទែមក្នុងវិស័យអនុវត្ត (STEM Applied)

ស្ទែមក្នុងវិស័យអនុវត្ត ផ្តោតទៅលើការអនុវត្តសមត្ថភាពជំនាញ និងទេពកោសល្យរបស់ពលរដ្ឋនៅក្នុងចង្វាក់ផលិតកម្មការងារ (STEM Workforce) ដើម្បីលើកកម្ពស់សេដ្ឋកិច្ចនៅក្នុងសហគមន៍ និងសេដ្ឋកិច្ចសកល។ យន្តការរបស់ស្ទែមក្នុងវិស័យអនុវត្ត គឺជំរុញឱ្យមានការប្រើប្រាស់ចំណេះដឹងមូលដ្ឋានដើម្បីបណ្តុះបំណិនគិតបែបស៊ីជម្រៅ (Critical Thinking) បំណិនដោះស្រាយបញ្ហា (Problem Solving) និងបំណិនទំនាក់ទំនង (Communication) ទៅអនុវត្តប្រកបដោយភាពច្នៃប្រឌិត។ ឧទាហរណ៍៖

-ការបង្កើតទែម៉ូម៉ែត្រអាល់កុល ឬទែម៉ូម៉ែត្របារត

-ការបង្កើតឧបករណ៍លាងសម្អាតឈាម

-ការទាញយកថាមពលចេញពីពន្លឺព្រះអាទិត្យ

-ការបង្កើតឧបករណ៍មេកានិកផ្សេងៗ និង

-ការគណនាការប្រាក់។

ផ្តើមចេញពីការសិក្សាទ្រឹស្តីអប់រំស្ទែមនៅក្នុងថ្នាក់រៀន សិស្សរៀបចំបង្កើតបន្ទះប្រព័ន្ធសូឡាព្រះអាទិត្យ (Solar Panel)ដើម្បីបំប្លែងថាមពលពន្លឺទៅជាថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងសាលារៀនជំនួសឱ្យការប្រើប្រាស់ថាមពលអគ្គិសនីដើរដោយប្រេងឥន្ធនៈ។ ស្ទែមក្នុងវិស័យអនុវត្តក៏ជាវិសាលភាពបន្តពីស្ទែម ក្នុងវិស័យអប់រំ ដោយដើរតួជាការអនុវត្តគម្រោងស្ទែម (STEM Projects) ហើយទាមទារឱ្យមានការផ្តួចផ្តើម ដោយយកចិត្តទុកដាក់ទៅលើការប្រាស្រ័យទាក់ទង ការសហការពីអ្នកជំនាញ និងធនធានសំខាន់ៗ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- ស្ទែមក្នុងវិស័យឌីជីថល (STEM Digital)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ស្ទែមក្នុងវិស័យឌីជីថល (STEM Digital) ផ្តោតសំខាន់ទៅលើការអនុវត្តចំណេះដឹងឌីជីថល (Digital Literacy) ដើម្បីពង្រឹងសមត្ថភាព ឬជំនាញដោះស្រាយបញ្ហា រួមទាំងការទាញយកជាតុសំខាន់ៗនៃប្រព័ន្ធបច្ចេកវិទ្យាមកប្រើប្រាស់ និងរុករកនូវរបកគំហើញថ្មីៗ។ វាជំរុញឱ្យយើងទាំងអស់គ្នាមានជំនាញប៉ាន់ស្មាន វាយតម្លៃប្រព័ន្ធដំណើរការអភិវឌ្ឍប្រព័ន្ធឌីជីថលទំនើបៗទៅលើប្រសិទ្ធភាពដោះស្រាយបញ្ហាសង្គម បញ្ហាការអប់រំ និងបញ្ហាសេដ្ឋកិច្ចជាដើម។ ឧទាហរណ៍ ប្រព័ន្ធគ្រប់គ្រងសាលា(LMS) ដើម្បីគ្រប់គ្រងរាល់វត្តមានគ្រូ និងសិស្ស រួមទាំងប្រព័ន្ធបូកស្រង់ពិន្ទុស្វ័យប្រវត្តិរៀងរាល់ខែផងដែរ។ ឧទាហរណ៍មួយទៀត គឺការរុករករបស់អ្នកវិទ្យាសាស្ត្រផ្នែកអវកាសក្នុងពេលបច្ចុប្បន្នទៅលើលក្ខខណ្ឌដែលទ្រទ្រង់ជីវិតនៅលើភពផ្សេងៗក្រៅពីភពផែនដីរបស់អង្គការណាសា និងការបង្កើតឡើងនូវភពថ្មីបែបឌីជីថល (Metaverse planet) មួយទៀតរបស់ក្រុមហ៊ុនមេតា (Meta)។ ស្ទែមក្នុងវិស័យឌីជីថលជាកម្រិតខ្ពស់មួយដើរស្របនឹងនិន្នាការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីសម្របទៅនឹងបរិបទសហគមន៍ចម្រុះ Blended Community (Real World and Social Media)។

វិស័យទាំងបីខាងលើនេះ សុទ្ធសឹងជាវិស័យដែលប្រទេសកម្ពុជាកំពុងត្រូវការចាំបាច់ក្នុងការប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសជឿនលឿននៅឆ្នាំ២០៥០ ពោលគឺជាប្រទេសអ្នកផលិត (Producer)។

ដូច្នេះ ខ្លឹមសារឯកសារស្ទែមក្នុងវិស័យអប់រំ(STEM Education) ដើរតួរជាឯកសារគោល និងជាឯកសារតម្រង់ទិសជំនួយដល់ការយល់របស់លោកគ្រូអ្នកគ្រូឱ្យកាន់តែច្បាស់ សម្រាប់ការអនុវត្តទៅលើវិធីសាស្ត្របង្រៀន និងរៀនតាមលំនាំស្ទែមក្នុងវិស័យអប់រំ (STEM Education) ។

- ការបង្រៀនដោយផ្តោតទៅលើវិមាត្របីនៃការអប់រំស្ទែម(Three dimensions)

ស្ទែមទាមទារចាំបាច់នូវគោលគំនិតវិមាត្របី ដែលជាគោលគំនិតសំខាន់សម្រាប់ការសិក្សាក្នុងនោះរួមមាន បញ្ញត្តិគោល ( Core Idea) ការអនុវត្ត(Practices) និងអន្តរមុខវិជ្ជា (Crosscutting) ។

-បញ្ញត្តិគោល (Core Idea) ផ្តោតសំខាន់ទៅលើមេរៀននៅក្នុងសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលរួមមាន៖ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី និងបរិស្ថានវិទ្យា និងគណិតវិទ្យាពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ មុខវិជ្ជាគោលត្រូវបានកំណត់ឡើងច្បាស់លាស់សម្រាប់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូដំណើរការរៀន និងបង្រៀន។

-អន្តរមុខវិជ្ជា(Crosscutting) ជាមេរៀនដែលកើតឡើងផ្អែកលើបាតុភូតធម្មជាតិ នៅក្នុងអំឡុងពេលធ្វើពិសោធន៍លើទ្រឹស្តីគោលមួយជាក់លាក់ ដោយបង្ហាញពីរបៀបដោះស្រាយបញ្ហារបស់សិស្សតាមរយៈមុខវិជ្ជាវិទ្យាសាស្ត្រផ្សេងៗទៀត រួមទាំង បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ អន្តរមុខវិជ្ជាអាចលេចឡើងនៅអំឡុងពេលសិស្សធ្វើពិសោធន៍ផ្ទាល់តាមរយៈបាតុភូតជាក់ស្តែងបែបសត្យានុម័ត ហើយក៏មិនអាចកំណត់បានដោយកត្តាបរានុម័តទេថាបាតុភូតនោះមានទំនាក់ទំនងរវាងប៉ុន្មានមុខវិជ្ជានោះ។




រូប១ វិមាត្របីរបស់ស្ទែម

-ការអនុវត្ត (Practices) សកម្មភាពនៃការសង្កេតបាតុភូតធម្មជាតិ ដោយឈរលើគោលវិធីសាស្ត្រការសិក្សាតាមបែបរិះរក(Inquiry-Based Learning)។ ការធ្វើសង្កេត សិស្សជាអ្នកធ្វើសកម្មភាពក្នុងការសិក្សាដោយភ្ជាប់ទំនាក់ទំនងនៃការអនុវត្ត ដើម្បីយល់ឱ្យបានស៊ីជម្រៅលើទ្រឹស្តីគោលដែលមាននៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា។ ការអនុវត្តសកម្មភាពចាំបាច់នៃការអប់រំស្ទែម (STEM) គឺដើម្បីសម្រេចគោលដៅក្នុងការដោះស្រាយបញ្ហាបាតុភូតដែលបានលេចឡើង។

ង. ស្តង់ដាទាំង១៥ របស់ស្ទែម

មុខវិជ្ជាវិទ្យាសាស្ត្រ និងវិស្វកម្មនៅក្នុងសាលារៀនទាមទារឱ្យសិស្សអនុវត្តសកម្មភាពបែបស្ទែម ដែលមានស្តង់ដាដូចខាងក្រោម៖

១ .សួរសំណួរ និងកំណត់អំពីបញ្ហាដែលលេចឡើងតាមរយៈបាតុភូត

២ .អភិវឌ្ឍ និងប្រើគំរូម៉ូដែល

៣ .រៀបចំផែនការ និងធ្វើការសង្កេត

៤ .វិភាគ និងបកស្រាយទិន្នន័យ

៥ .ប្រើគណិតវិទ្យា និងការគណនា តាមបែបតក្កវិទ្យា ភាពសមហេតុផល និងការគិតត្រិះរិះ

៦ .ធ្វើការអធិប្បាយពន្យល់ និងកំណត់សេចក្តីសន្និដ្ឋាន ឬផ្តល់នូវដំណោះស្រាយសមស្រប

៧ .ចូលរួមពិភាក្សាដោយប្រើភស្តុតាង និងហេតុផលវិទ្យាសាស្ត្រ

៨ .ប្រមូល វាយតម្លៃ និងការដោះដូរទិន្នន័យគ្នាទៅវិញទៅមក។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដូចគ្នាទៅនឹងការអនុវត្តនៅតាមសាលា ការអនុវត្តសកម្មភាពស្ទែម (STEM) តែងតែមានទំនាក់ទំនងរវាងគ្រប់មុខវិជ្ជាវិទ្យាសាស្ត្រ វិស្វកម្ម និងបច្ចេកវិទ្យា នៅពេលដែលសិស្សធ្វើការសង្កេតទៅលើចំណុចដូចខាងក្រោម៖

៩. លំនាំនៃបាតុភូតធម្មជាតិ

១០. មូលហេតុ និងលទ្ធផល

១១.បរិមាណសមាមាត្រនិងមាត្រដ្ឋាន(ការវាស់វែងនិងការកត់ត្រាទិន្នន័យ)

១២. ប្រព័ន្ធ និងគំរូប្រព័ន្ធ

១៣. រូបធាតុ និងថាមពល៖ លំហូរ ការរក្សាទុក និងវដ្តនៃការកកើតឡើងវិញ

១៤. ទម្រង់ និងមុខងារនៃបាតុភូត (តើវាជាអ្វី? ហើយវាអាចធ្វើអ្វីបាន?)

១៥. ស្ថិរភាព និងការប្រែប្រួលនៃបាតុភូត។ (តើវាមានស្ថិរភាពដែរឬទេ? តើវាមានការប្រែប្រួលដែរឬទេ? និងតើវាប្រែប្រួលបាននៅពេលណា?)

ច .សេចក្តីសន្និដ្ឋាន

ការអប់រំក្នុងយុគសម័យថ្មីសតវត្សរ៍ទី២១នេះ បានជំរុញឱ្យពិភពលោកមានការវិវត្តយ៉ាងលឿនលើវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យាដែលជាវិស័យដ៏សំខាន់មួយជួយឱ្យសេដ្ឋកិច្ចពិភពលោកលូតលាស់យ៉ាងឆាប់រហ័ស ជាពិសេសបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ការផ្លាស់ប្តូរវិធីសាស្ត្រនៃការសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ គឺជាគន្លឹះសំខាន់ដែលនាំសិស្សឆ្ពោះទៅរកទេពកោសល្យក្នុងការច្នៃប្រឌិតដើម្បីក្លាយខ្លួនទៅជាពលរដ្ឋប្រកបដោយផលិតភាព។ លំនាំនៃការរៀន និងបង្រៀនបែបបុរាណត្រូវបានជំនួសដោយសកម្មភាពនៃការរៀន និងបង្រៀនបែបសកម្ម ដែលទាមទារឱ្យសិស្សមានបំណិនក្នុងការគិតបែបចម្រុះមុខវិជ្ជាក្នុងពេលតែមួយ។ មួយផ្នែកទៀតនៃវិធីសាស្ត្រការសិក្សាថ្មី គឺសិក្សាចេញពីទ្រឹស្តីទៅជាលទ្ធផលមួយច្បាស់លាស់ បម្រើឱ្យសេចក្តីត្រូវការប្រចាំថ្ងៃរបស់សហគមន៍។ តាមរយៈរបៀបរៀននិងបង្រៀនថ្មីនេះ បេសកកម្មនៃការអប់រំជាសកល គឺបណ្តុះពលរដ្ឋឱ្យមានបំណិនវិជ្ជាជីវៈប្រកបដោយលក្ខណវិទ្យាសាស្ត្រ និងនវានុវត្តន៍ទៅលើបច្ចេកវិទ្យាថ្មីៗ។ ដើម្បីសម្រេចបាននូវបេសកកម្មអប់រំបែបថ្មីនេះ ស្ទែមបានក្លាយទៅជាយន្តការដ៏សំខាន់នៃការអប់រំ ធ្វើឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្ររៀន និងបង្រៀនរបស់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលារៀននាពេលបច្ចុប្បន្ន។

រួមសេចក្តីមក ការអប់រំស្ទែម គឺជាការសិក្សាតាមបែបអន្តរមុខវិជ្ជាដែលមានលក្ខណៈជាវិធីអង្កេតរិះរក ស្ថាបនានិយម លើកកម្ពស់ដល់ការគិត ការត្រិះរិះពិចារណា រួមផ្សំជាមួយនឹងការអនុវត្តជាក់ស្តែងជាច្រើន ដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រើប្រាស់ក្នុងសង្គមជាក់ស្តែង និងមានគោលបំណង៖ (១) លើក

ទឹកចិត្តសិស្សឱ្យបន្តការសិក្សាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅថ្នាក់ឧត្តមសិក្សា (២)បំប៉នសិស្សឱ្យអាចប្រកួតប្រជែងស្វែងរកការងារ និងអាហារូបករណ៍សម្រាប់បន្តការសិក្សាលើឆាកអន្តរជាតិ និង(៣) លើកទឹកចិត្តយុវជនឱ្យត្រៀមខ្លួន និងរួមចំណែកក្នុងការអភិវឌ្ឍសង្គមឌីជីថល។

*ឧបសម្ព័ន្ធទី៩៖ ការអប់រំស្ទែម*

### ៧.៧ វិធីសាស្ត្របង្រៀនតាមបែបបញ្ញត្តិ

#### ក.លំនាំដើម

ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ និងការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សិស្សនឹងក្លាយជាពលរដ្ឋពេញលេញឬពលរដ្ឋពូកែ។ ពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ ពោរពេញដោយវិជ្ជា និងចរណៈ (Khmer Buddhism Institute , 1931)។ សិស្សពោរពេញដោយវិជ្ជា និងចរណៈនឹងបម្រើការងារ ក្នុងគ្រប់វិស័យឧស្សាហកម្មដោយមោទនភាព មានគណនេយ្យភាព ទទួលខុសត្រូវខ្ពស់ និងចូលរួមលើកតម្កើងគុណតម្លៃសង្គម។ ពលរដ្ឋពោរពេញដោយវិជ្ជា និងចរណៈ នឹងដឹកនាំកម្ពុជាទៅដល់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០ និងចំណូលខ្ពស់ ត្រឹមឆ្នាំ២០៥០។

#### ខ.កម្មវិធីសិក្សាតាមសិក្សាបញ្ញត្តិ

ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ ត្រូវផ្ដោតការយកចិត្តទុកដាក់លើវិមាត្រ៣៖ ១.បញ្ញត្តិ ២. អង្គហេតុ ៣.បំណិននិងដំណើរការ។ ទម្លាប់រៀបចំកម្មវិធីសិក្សាបែបប្រពៃណី






youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ផ្តោតការយកចិត្តទុកដាក់លើវិមាត្រ២៖ ១.អង្គហេតុ (មាតិកា) ២.បំណិន និងដំណើរការ។

*រូបភាព០១. កម្មវិធីសិក្សាបែបប្រពៃណី*

*រូបភាព០២. កម្មវិធីសិក្សាតាមសិក្សាបញ្ញត្តិ*




បញ្ញត្តិជាគ្រឿងសង្ហារិមនៃចិត្ត។ ចិត្តដែលមានបំពាក់គ្រឿងសង្ហារិមល្អៗ ជាប្រភពផ្តល់បីតិ ជោគជ័យ និងភាពជាពលរដ្ឋពូកែ (Parker, 2012 )។ បញ្ញត្តិជាជាតុសម្រាប់ដឹកនាំចិត្តនាំផ្លូវគិតរបស់សិស្សនិងភ្ជាប់ជាមួយតម្រូវការនៃការរៀនបន្ត រស់នៅ និងធ្វើការ។ បញ្ញត្តិអាចបង្កប់ក្នុងគំនិតទូទៅគោលគំនិតឬគំនិតធំរបស់អ្នកនិពន្ធ។ បញ្ញត្តិអាចបង្ហាញក្នុងគំនិតទូទៅ គំនិតធំ ឬគោលគំនិតរបស់អ្នកនិពន្ធ។ ការស្គាល់ និងយល់បញ្ញត្តិ ជាការចាប់ផ្តើមស្វែងពុទ្ធិគ្រប់កម្រិត និងផ្តើមការស្រាវជ្រាវពីកម្រិតតូច ដល់កម្រិតធំ។ ដូច្នេះ អ្នកគ្រូ លោកគ្រូត្រូវកំណត់រកបញ្ញត្តិចេញពីមេរៀន ឯកសារអំណាន ឬកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជាតាមកម្រិតថ្នាក់ដែលអ្នកគ្រូ លោកគ្រូត្រូវបង្រៀន។

គ.បញ្ញត្តិ និងចិត្តសិស្ស

របកគំហើញនៃការស្រាវជ្រាវរបស់ Ignatavicius (2017), Giddens & Brady (2007), Kluwer (2017) អំពីសិស្សរៀនពេទ្យពន្យល់ថា ការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ និងកម្មវិធីសិក្សាបញ្ញត្តិ សិស្សអាចភ្ជាប់បញ្ញត្តិរៀនពីសាលាជាមួយនឹងការងារជាក់ស្តែងក្នុងវិស័យពេទ្យ។ Kluwer (2017), Erickson L. H (2008), Erickson, Lanning, & French (2017), Erickson & Lanning (2014), និងStern, Lauriault, & Ferraro (2018) បញ្ជាក់បន្ថែមថា ការដឹកនាំសិស្សឱ្យរៀនតាមកម្មវិធីសិក្សាបញ្ញត្តិ សិស្សពេញចិត្តចូលរួមក្នុងដំណើរការរៀន ដោយសារៈ

១.សិស្សបន្ថយការរៀនបែបចូលត្រចៀកស្តាំ ចេញត្រចៀកឆ្វេង

២.សិស្សប្រើព័ត៌មានសម្បូរបែបពីច្រើនប្រភព និងគួរឱ្យទុកចិត្ត

៤.សិស្សបានអភិវឌ្ឍបំណិនច្រើនយ៉ាង គិតកម្រិតខ្ពស់ ស្រាយបញ្ហា

៥.សិស្សអភិវឌ្ឍសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ ដោយប្រើបញ្ញត្តិ

៦.សិស្សមានសេរីភាព និងឯករាជ្យក្នុងដំណើរការរៀន

៧.សិស្សអភិវឌ្ឍសមត្ថភាពច្នៃប្រឌិត

៨.សិស្សក្លាយជាបុគ្គលពូកែឆ្ងល់ និងសួរសំណួរ

៩.សិស្សក្លាយជាបុគ្គលមានជម្រើសនៃការស្រាយបញ្ហា។

### ឃ. វិជ្ជានុក្រម BLOOM

ចេតនានៃមាតាបិតា និងអាណាព្យាបាលមួយចំនួន បញ្ជូនកូនចូលសាលា សំដៅឱ្យកូនក្លាយជាពលរដ្ឋពូកែ ពោរពេញដោយវិជ្ជា និងចរណៈ។ ចេតនាមាតាបិតា និងអាណាព្យាបាលខ្លះទៀត ចង់ឱ្យកូនមានបំណិនសតវត្សរ៍ទី២១។ ចេតនានៃបុគ្គលមួយចំនួនចង់រៀនមានចំណេះដឹងបច្ចេកទេស និងរៀនឱ្យដល់កម្រិតបញ្ញា។ ចេតនានៃប្រព័ន្ធអប់រំរបស់កម្ពុជា ចង់ឱ្យសិស្សទទួលបាន និងប្រើវិជ្ជាសម្បទា បំណិនសម្បទានិងចរិយាសម្បទាក្នុងការងារ។ ចម្ងល់មួយយ៉ាងសាមញ្ញចោទជាសំណួរថា មានមធ្យោបាយ និងវិធីអ្វីដែលល្អបំពេញចេតនានេះ?

ការជានាសម្រេចចេតនានេះ គឺមានមធ្យោបាយ និងវិធីច្រើន។ សៀវភៅនេះជ្រើសយកគោលវិធីសិក្សាបញ្ញត្តិសម្រាប់សរសេរកម្មវិធីសិក្សា និងវិធីសាស្ត្រសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សា សម្រាប់ដឹកនាំការរៀនមកបរិយាយ។

បុគ្គលគ្រប់រូបប្រហែលជាចង់បានបំណិនគិតកម្រិតខ្ពស់រហូត ***បង្កើតថ្មី*** សម្រាប់ប្រើការក្នុងការងារ រស់នៅ និងធ្វើការ។ Benjamin BLOOM (1956) បង្កើតតារាងមួយហៅថា វិជ្ជានុក្រមប្លូម




t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

(BLOOM)។ Anderson, Krathwohl, & Airasian (2001) កែសម្រួលតារាងវិជ្ជានុក្រមនេះ ឱ្យមាន៦ កម្រិត នៃសមត្ថភាពគិតដូចតារាងវិជ្ជានុក្រមដើម BLOOM (1956)គឺ***បង្កើតថ្មី*** (រូបភាព០៣)។

*រូបភាព០៣. វិជ្ជានុក្រម Bloom និងរចនាសម្ព័ន្ធនៃពុទ្ធិ*

ង. រចនាសម្ព័ន្ធនៃពុទ្ធិ

គ្រូបង្រៀនកម្ពុជាគ្រប់រូបពិតជាធ្លាប់ឮ សរសេរ អាន និងប្រើពាក្យ **ពុទ្ធិ ព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញា** ញឹកញាប់ណាស់។ គ្រូបង្រៀនពិតជាមានចេតនាបង្រៀនសិស្ស និងរៀនដោយខ្លួនឯងឱ្យអភិវឌ្ឍពុទ្ធិដល់កម្រិតបញ្ញា។

១. ព័ត៌មាន

ជាតុផ្សំដំបូង មូលដ្ឋាន ឬផ្ទៃខាងលើនៃជាតុនានាដែលអ្នកសិក្សាត្រូវទទួលបានដំបូង យកមកចាំទុកនិងសម្គាល់ទុក។ ជាទូទៅ អ្នកសិក្សាចាំទុក ឬសម្គាល់ទុកនូវរូបវត្ថុ ឬនាមវត្ថុមួយចំនួននៃអង្គហេតុ ឬព្រឹត្តិការណ៍ ក្នុងវិញ្ញាណ តាមរយៈភ្នែក ត្រចៀក អណ្ដាត ច្រមុះ ឬរាងកាយ។ ការចាំទុក ឬសម្គាល់ទុកជាចំណុចចាប់ផ្ដើមនៃការរៀនដំបូងបំផុត។

២. ចំណេះដឹង

មានព័ត៌មាន មិនទាន់មានចំណេះដឹងទេ។ ការមានចំណេះដឹង គឺបានស្វែងភាពពិត ត្រឹមត្រូវ ឬច្បាស់លាស់នៃព័ត៌មានពីច្រើនប្រភពដែលគួរឱ្យទុកចិត្ត និងប្រើការបាន។ ការមានចំណេះដឹង គឺប្រមូលបានកញ្ចប់នៃជាតុផ្សំជាច្រើនបង្កប់ក្នុងកញ្ចប់ព័ត៌មានមូលដ្ឋានពីច្រើនប្រភព។ ការមានចំណេះដឹង គឺស្គាល់មុខងារ តួនាទី និងរចនាសម្ព័ន្ធនៃជាតុផ្សំនីមួយៗក្នុងកញ្ចប់ព័ត៌មាន ស្របតាមលក្ខខណ្ឌ កាល និងបរិបទ។ ការមានចំណេះដឹង គឺកើតឡើងដោយប្រើចិត្តយកទៅគិត ឆ្ងល់ បង្កើតសំណួរ សួរ និងរកការពន្យល់ពីច្រើនប្រភព។ ដើម្បីបានជាចំណេះដឹង សិស្សត្រូវឆ្លើយសំណួរមួយ។ តើព័ត៌មាននោះពិតត្រឹមត្រូវ និងប្រើការបានកម្រិតណា? មានចំណេះដឹង គឺបំបែកជាតុនានា និងបរិមាណនៃជាតុបង្កប់ក្នុងព័ត៌មាន ឬក្នុងសញ្ញាណទទួលបានក្នុងជំហានដំបូង។

៣. វិជ្ជា

មានវិជ្ជាគឺមានចំណេះដឹង ប៉ុន្តែត្រូវភ្ជាប់ដោយភស្តុតាងវិទ្យាសាស្ត្រ។ មានវិជ្ជា គឺយល់ពីជាតុលម្អិត និងមុខងារនៃជាតុនីមួយៗបង្កប់ក្នុងចំណេះដឹង។ មានវិជ្ជាត្រូវមានភស្តុតាងវិទ្យាសាស្ត្របញ្ជាក់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃជាតុផ្សំនៃចំណេះដឹង។ ការមានវិជ្ជា មនុស្សអាចយកទៅប្រតិបត្តិបាន ស្របតាមកាល បរិបទ និងលក្ខខណ្ឌ។ ការមានវិជ្ជា គឺមានភាពច្បាស់លាស់ ពិត និងត្រឹមត្រូវអំពីរបៀបយកជាតុលម្អិតក្នុងចំណេះដឹងទៅអនុវត្ត និងចែករំលែកជាប្រយោជន៍មនុស្ស។ មានវិជ្ជា

គឺយល់ច្បាស់ និងយល់ត្រូវ អំពីលក្ខណៈវិនិច្ឆ័យ បច្ចេកទេស ទ្រឹស្តី វិធីសាស្ត្រ វិធី យុទ្ធវិធី មុខងារ គោលការណ៍ ក្បួន រចនាសម្ព័ន្ធ។ល។ដែលពាក់ព័ន្ធនឹងធាតុលម្អិតរបស់ចំណេះដឹង សម្រាប់យកទៅប្រតិបត្តិប្រចាំជីវិត និងចែករំលែកជាប្រយោជន៍មនុស្ស។

៤. បញ្ញា

ការមានចំណេះដឹង ឬវិជ្ជាច្រើនឬជម្រៅប៉ុនណា ដោយបានអានច្រើនប៉ុនណា ឬរៀនចប់អស់ថ្នាក់រៀន ក៏ពុំទាន់មានបញ្ញាដែរ។ បញ្ញាកើតចេញពីការប្រតិបត្តិ។ ប្រតិបត្តិសំដៅបញ្ជាក់ភាពពិតត្រឹមត្រូវ និងច្បាស់លាស់នៃចំណេះដឹង និងវិជ្ជា ជាប្រយោជន៍នៃមនុស្ស។ មានបញ្ញាគឺប្រមូលបានទិន្នន័យប្រកបដោយគុណភាព គ្រប់គ្រាន់ ទុកចិត្ត ត្រឹមត្រូវ និងច្បាស់លាស់ពីការប្រតិបត្តិ ឬពិសោធន៍ ដោយផ្ទាល់ខ្លួន។ មានបញ្ញាគឺបានប្រើទិន្នន័យប្រកបដោយគុណភាពទៅបង្កើតទ្រឹស្តី គោលការណ៍ វិធីសាស្ត្រ លក្ខខណ្ឌថ្មី ស្របតាមកាល និងបរិបទ។




*រូបភាព០៤. ធាតុគោលនៃសិក្សាបញ្ញត្តិ*

ច. ដំណើរការរៀនតាមសិក្សាបញ្ញត្តិ

ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ សំដៅបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប។ ដំណើរការរៀន និងដឹកនាំការរៀនតាមកម្មវិធីសិក្សាតាមខ្លឹមសារមេរៀន សំដៅឱ្យសិស្សទន្ទេញរត់មាត់ ចាំខ្លឹមសារមេរៀន។ ខ្លឹមសារមេរៀនមាន អង្គហេតុ ឧទាហរណ៍



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ព្រឹត្តិការណ៍ តួលេខ រូបមន្ត គំនិតទូទៅ ទ្រឹស្តី ព័ត៌មាន និងទិន្នន័យ (Erickson & Lanning, 2014; Stern, Lauriault, & Ferraro, 2018; Erickson, Lanning, & French, 2017)។ ការរៀនទន្ទេញចាំរត់មាត់ គឺសម្រាប់ឆ្លើយសំណួរកម្រិតទាប បំពេញតម្រូវការប្រឡងតែប៉ុណ្ណោះ។ សិស្សមានសមត្ថភាពប្រើបំណិនតាមកិរិយាសព្ទសកម្ម កំណត់ក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM, ១៩៥៧) (Stern, Lauriault, & Ferraro, 2018; Kluwer, 2017; Erickson & Lanning, 2014)។

ដំណើរការរៀន និងការដឹកនាំការរៀនតាមកម្មវិធីសិក្សាតាមសិក្សាបញ្ញត្តិ និងប្រើវិធីសាស្ត្របង្រៀនតាមសិក្សាបញ្ញត្តិ សំដៅឱ្យសិស្ស ១. ស្គាល់ ២. យល់ និង៣. ធ្វើ (Erickson, Lanning, & French, 2017)។

*រូបភាព០៥. ដំណើរការរៀនតាមសិក្សាបញ្ញត្តិ*

- **សិស្សស្គាល់**សំដៅឱ្យសិស្សភ្ជាប់ជាមួយបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត គំនិតធំ ទ្រឹស្តី ឬគោលការណ៍រៀនពីសាលាជាមួយបទពិសោធ ឬការធ្លាប់ស្គាល់
- **សិស្សស្គាល់** សំដៅឱ្យសិស្សប្រើបទពិសោធ និងចំណេះដឹងមានស្រាប់




- **សិស្សយល់** សំដៅឱ្យសិស្សពង្រីកសេចក្តីយល់ស៊ីជម្រៅលើគំនិតទូទៅ គោលគំនិត ឬគំនិតធំ ទ្រឹស្តី ឬគោលការណ៍ និងបញ្ញត្តិ។




- **សិស្សយល់** សំដៅដល់ការបំបែក និងញែកធាតុ ឬផ្គុំធាតុនៃបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត គំនិតធំ គោលការណ៍ ឬទ្រឹស្តី។

*រូបភាព៥. បញ្ញត្តិមេរោគ និងអនាម័យ*

- **សិស្សធ្វើឬប្រតិបត្តិ** សំដៅឱ្យសិស្សភ្ជាប់បញ្ញត្តិរៀនពីសៀវភៅ ពីគ្រូបង្រៀន និងមិត្តភក្តិក្នុងសាលារៀន ជាមួយនឹងតម្រូវការប្រចាំថ្ងៃ ធ្វើការ និងរៀនបន្ត ក្នុងគ្រប់បរិបទ លក្ខខណ្ឌនិងកាល។ ឧទាហរណ៍ *ចូរកូនលាងដៃនឹងសាប៊ូ!* ប្រសិនបើការបង្រៀនផ្តោតការយកចិត្តទុកដាក់តែលើការលាងដៃ សិស្សបានត្រឹមដឹងអំពីលាងដៃ។ ក្នុងបរិបទនៃកូវីដ-១៩ ការបង្រៀនតាមសិក្សាបញ្ញត្តិ គឺលើសពីលាងដៃនឹងសាប៊ូ។ ការរៀនគឺផ្តោតការយកចិត្តទុកដាក់លើការយល់បញ្ញត្តិ និងបំណិនស្រាយបញ្ហា។ បញ្ញត្តិដែលត្រូវរៀន គឺមេរោគ និងអនាម័យ។ *មេរោគ និងអនាម័យ* អាចភ្ជាប់រៀនជាមួយមុខវិជ្ជាផ្សេងដូចជា ជីវវិទ្យា គេហវិទ្យា សីលធម៌។ល។ បញ្ញត្តិ*មេរោគ និងអនាម័យ* មានលក្ខណៈសកល មនុស្សយល់ដូចៗគ្នា។ បញ្ញត្តិ*មេរោគ និងអនាម័យ* យកមកប្រើគ្រប់កាល។ ទោះអត់កូវីដ ១៩ ឬមានកូវីដ ១៩ ក៏ត្រូវតែលាងដៃនឹងសាប៊ូ។

ឆ.បញ្ញត្តិជាអ្វី?

សិស្សរៀនមេរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិមានសមត្ថភាពប្រែក្លាយព័ត៌មានឱ្យទៅជាចំណេះដឹងទៅជាវិជ្ជា និងបន្ថែមជម្រៅរហូតដល់បញ្ញា។ សិស្សមានសមត្ថភាពគិត និងប្រើព័ត៌មានជាប្រយោជន៍គ្រប់កាល និងបរិបទ។ សិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ ដូចជាវិភាគ វាយតម្លៃ និងច្នៃប្រឌិដ្ឋ ដោយផ្តើមចេញពីទិន្នន័យគ្រប់ជ្រុងជ្រោយ និងព័ត៌មានពិតប្រាកដ និងច្បាស់លាស់។ ពាក្យនិយមប្រើក្នុងការ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

សរសេរកម្មវិធីសិក្សា តាមគោលវិធីសិក្សាបញ្ញត្តិ មាន ៖ **ការយល់ទូទៅ គំនិតទូទៅ គោលគំនិត គំនិតធំ បញ្ញត្តិ ប្រធានបទ និងអង្គហេតុ។**

*រូបភាព០៦. ពាក្យបច្ចេកទេសក្នុងសិក្សាបញ្ញត្តិ*




បញ្ញត្តិមានបង្កប់ក្នុងប្រយោគនៃការនិយាយ ឬសរសេរ អាចជាពាក្យមួយ ឬការផ្សំផ្គុំពាក្យពីរ ឬឃ្លាខ្លីមួយ។ បញ្ញត្តិអាចរំលេចចេញក្នុងប្រយោគ នៃគោលគំនិត គំនិតទូទៅ ឬគំនិតធំ។ បញ្ញត្តិអាចយកទៅប្រើការបាន និងភ្ជាប់បាននឹងតម្រូវការគ្រប់កាល និងបរិបទ។ ពាក្យ ឬឃ្លាខ្លីមួយអាចចាត់ទុកជាបញ្ញត្តិ ត្រូវគោរពលក្ខខណ្ឌ៖ ១.លក្ខណៈសកល ២.អរូបី ៣.តំណភ្ជាប់ ៤.គ្រប់កាល។

ការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ និងតាមកម្មវិធីសិក្សាបញ្ញត្តិ ជាការតម្រៀបអង្គហេតុ ឬព័ត៌មានឱ្យមានរចនាសម្ព័ន្ធ។ ព័ត៌មាន ឬអង្គហេតុមានរចនាសម្ព័ន្ធ ជាគ្រឹះនៃដំណើរការរៀន ដើម្បីអភិវឌ្ឍបំណិនគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ ស្វែងសេចក្តីពន្យល់ និងបញ្ជាក់សេចក្តីពិត ត្រឹមត្រូវ និងច្បាស់លាស់ ដូចរបៀបនៃការគិតរបស់ អ្នកវិទ្យាសាស្ត្រ។ ឧទាហរណ៍ អ៊ីសាក់ ញូតុន (Isaac Newton, ឆ្នាំ១៦៤៣–១៧២៧) ស្វែងការពន្យល់អំពីមូលហេតុនៃការធ្លាក់ផ្លែប៉ោម។ លោកពន្យល់ទ្រឹស្តីទម្លាក់សេរី និងបង្កើតបានរូបមន្តកម្លាំងទំនាញមួយឱ្យអ្នកវិទ្យាសាស្ត្ររៀនជាហូរហែ។ ចម្ងល់របស់ អ៊ីសាក់ ញូតុន ចាប់ផ្តើមពីការគិត សង្កេត ឆ្ងល់ បង្កើតសំណួរ ចោទសំណួរ និងស្វែងការពន្យល់។

*រូបភាព០៩. ភាពខុសគ្នារវាងបញ្ញត្តិ និងប្រធានបទ និងអង្គហេតុ*




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ជ. ការវាយតម្លៃការរៀនតាមសិក្សាបញ្ញត្តិ

រូបភាពពន្យល់ថា ក្របខ័ណ្ឌពង្រីកពុទ្ធិរបស់ WEBB (1997) មាន៤កម្រិត៖ ១.រំឭកនិងពង្រីកការចងចាំ ២.បំណិននិងបញ្ញត្តិ ៣.គិតបែបយុទ្ធសាស្ត្ររយៈពេលខ្លី ៤.ពង្រីកវិសាលភាពនៃគំនិត។ ជាទូទៅ ប្រព័ន្ធអប់រំជាច្រើនកន្លែងប្រើក្របខ័ណ្ឌពង្រីកពុទ្ធិរបស់ WEBB (1997) សម្រាប់តាក់តែងលំនាំនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ គ្រូបង្រៀនគួរប្រតិបត្តិទម្លាប់តាក់តែងលំនាំវាយតម្លៃលទ្ធផលសិក្សាតាមកម្រិតនីមួយៗ។

ការវាយតម្លៃលទ្ធផលសិក្សារំពឹងទុក (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាកំណត់ក្នុងកម្មវិធីសិក្សា) ជាដំណើរការនិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតនៃការទទួលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្ស។ ការវាយតម្លៃសំដៅរកព័ត៌មានទិន្នន័យ ឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្តអំពីដំណើរការរៀន និងការដឹកនាំការរៀន។ ការវាយតម្លៃសំដៅរកវិធី និងផ្តល់ធាតុចូល ដើម្បីជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ។ ការវាយតម្លៃសំដៅដល់ការពិនិត្យឡើងវិញលើទម្រង់ ទម្លាប់ និងវិធាននៃការគ្រប់គ្រងថ្នាក់រៀន និងប្រព័ន្ធអប់រំ។

ការវាយតម្លៃជួយគ្រូបង្រៀន ៖

- ឱ្យស្គាល់បរិបទសិស្សច្បាស់
- ឱ្យប្រើព័ត៌មានអំពីការចងចាំ ការយល់ និងឥរិយាបថរបស់សិស្ស



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ឱ្យរកព័ត៌មានពីលទ្ធផលសិក្សា តាមប្រភេទសិស្ស
- ឱ្យស្គាល់ច្បាស់អំពីឥរិយាបថ ទម្លាប់ និងវិធីរៀនរបស់សិស្ស
- ឱ្យកែលម្អឥរិយាបថ ទម្លាប់ និងវិធីរៀនក្នុង និងក្រៅថ្នាក់
- ឱ្យធ្វើផែនការរយៈពេលខ្លី ក្នុងការកែលម្អឥរិយាបថ ទម្លាប់ និងវិធីរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ
- ឱ្យកែលម្អទម្លាប់ និងវិធីបង្រៀន ក្នុងថ្នាក់ និងក្រៅថ្នាក់។

*រូបភាព១០. គោលការណ៍វាយតម្លៃការសិក្សា*




*ប្រភព ៖ សម្រួលពី* WEBB (1997)

ឈ. លំនាំនៃការតាក់តែងផែនការដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ

**១. គោលបំណង**

**១.១ មេរៀនទី២**

**១.២ បញ្ញត្តិ**

វីរភាព សង្គ្រាម ជម្លោះ នយោបាយ អំណាច ជនជាន តំបន់ ទីកន្លែង ភាពជាពលរដ្ឋ អធិបតេយ្យភាព ការចូលរួម

**១.៣ លទ្ធផលសិក្សា**

សូមអានសេចក្ដីពន្យល់

**១.៤ បំណិនដើម្បីជោគជ័យ**

- បង្កើតសំណួរ
- កែលម្អសំណួរ
- សួរសំណួរ
- កត់ត្រាចម្លើយ
- វាយតម្លៃលទ្ធផល

**២. ដំណើរការរៀន និងដឹកនាំការរៀន**

**២.១ សំណួរគន្លឹះ**

សំណួរ០១.
សំណួរ០២.
សំណួរ០៣.

សូមអានសេចក្ដីពន្យល់

**២.២ យុទ្ធវិធី**

យុទ្ធវិធី០១៖
យុទ្ធវិធី០២៖
យុទ្ធវិធី០៣៖

សូមអានសេចក្ដីពន្យល់

**៣. វាយតម្លៃការសិក្សា**

**៣.១ វាយតម្លៃដើម្បីការរៀនបន្ត**

វាយតម្លៃ០១.
វាយតម្លៃ០២.
វាយតម្លៃ០៣.

សូមអានសេចក្ដីពន្យល់

**៣.២ ផែនការជួយសិស្សរៀនយឺត**

ផែនការ០១.
ផែនការ០២.
ផែនការ០៣.

សូមអានសេចក្ដីពន្យល់

*ឧបសម្ព័ន្ធទី១០៖ សិក្សាបញ្ញត្តិដើម្បីអភិវឌ្ឍគុណសម្បទាសតវត្សទី២១*

## ៧.៨ ការសិក្សាបែបគម្រោង ផែនការបង្រៀនសម្រាប់អ្នកសម្របសម្រួល

សៀវភៅណែនាំនេះ ផ្តល់នូវការសង្ខេបបច្ចេកទេសសំខាន់ៗដែលអ្នកអប់រំអាចយកទៅប្រើដើម្បីអនុវត្តការសិក្សាបែបគម្រោងនៅក្នុងសាលារបស់ពួកគេ។ ការសិក្សាបែបគម្រោង គឺជាវិធីមួយមានតាំងពីច្រើនទសវត្សមកហើយ ក្នុងការជួយពង្រឹងចំណេះដឹងសិស្សពីគោលការណ៍ផ្សេងៗពួកគេបានរៀនក្នុង មុខវិជ្ជាផ្សេងៗគ្នា (សូមមើលប្រអប់ទី១ សម្រាប់និយមន័យ)។

- វិធីនេះមានលក្ខណៈសំខាន់ៗមួយចំនួនដូចខាងក្រោម៖
- សិស្សធ្វើការសហការអង្កេតជាក្រុម
- ប្រើប្រាស់ការសិក្សាបែបអនុវត្តជាក់ស្តែង
- ត្រូវការបំណែនដោះស្រាយប លើកកម្ពស់កសិក្សាស្រាវ
- មានភាពបត់បែន និងចម្រុះមុខវិជ្ជា
- បង្កើតផលិតផលថ្មីៗ

ដោយសារប្រព័ន្ធអប់រំកម្ពុជាចង់ឱ្យមានភាព ប្រសើរឡើងនូវវិធីបង្រៀនក្នុងសតវត្សថ្មីផ្តោតលើការរៀនបែបអនុវត្តជាក់ស្តែង នោះការសិក្សាបែបគម្រោង កាន់តែមានភាពសំខាន់ និងចាំបាច់។ នេះគឺដោយសារតែវាជួយជំរុញដល់ការបង្កើតការសិក្សាបែបគម្រោងផ្សេងៗ លើកកម្ពស់ការសិក្សារបស់សិស្សឱ្យលើសពីសៀវភៅសិក្សា។ ក្នុងករណីនេះ យើងអាចនិយាយបាន ថា សិស្សប្រើគោលការណ៍ដែលបានរៀនដើម្បី បង្កើត ចំណេះដឹងថ្មី។ ដូចនេះ ការសិក្សាបែបគម្រោងជាគំរូ ទស្សនវិជ្ជាអប់រំគេស្គាល់ថាជា ការសិក្សាបែបស្ថាបនា និយម ដោយសិស្សធ្វើសកម្មភាពសិក្សាច្រើន លើសពីការទន្ទេញចាំទ្រឹស្តី ឬគោលការណ៍ ប៉ុន្តែបង្កើតចំណេះ ដឹងថ្មីៗក្នុងទម្រង់ជាគម្រោងសិក្សា។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយបញ្ចូលផែនការបង្រៀនសម្រាប់អ្នកសម្របសម្រួលដែលក្រសួងប្រគល់ការកិច្ចក្នុងការផ្សព្វផ្សាយពីការប្រើប្រាស់ការសិក្សាបែបគម្រោងនេះទៅកាន់សាលាផ្សេងៗ ព្រមទាំង សំណុំឯកសារមេរៀន និងសម្ភារៈ ដែលអ្នកសម្របសម្រួលអាចចែករំលែកជាមួយសិក្ខាកាមចូលរួមសិក្ខាសាលា។

*ឧបសម្ព័ន្ធទី១១៖ ការសិក្សាបែបគម្រោងផែនការបង្រៀនសម្រាប់អ្នកសម្របសម្រួល*

## ៧.៩ ការលើកកម្ពស់ស្តង់ដាសាលារៀនគំរូដោយវិធីបង្រៀនតាមបែបថ្នាក់រៀនត្រឡប់ និងវិធីសាស្ត្របង្រៀនតាមទ្រឹស្តីអប់រំស្ថាបនានិយម

### ក. ការណែនាំអំពីវេទិកា "Duraseksa - ទូរសិក្សា"

ភ្លាមៗបន្ទាប់ពីការប្រកាសផ្អាកដំណើរការគ្រឹះស្ថានសិក្សាទូទាំងប្រទេស ដើម្បីទប់ស្កាត់ការផ្ទុះរាលដាលនៃជំងឺកូវីដ-១៩ កាលពីដើមឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមបង្កើត **មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថលនិងការអប់រំពីចម្ងាយ** ជាដំណោះស្រាយផ្នែកប្រតិបត្តិចំពោះបញ្ហាដែលបានកើតឡើងនាពេលកន្លងមក នៅលើដំណើរបរិវត្តកម្មនៃការអប់រំឌីជីថល ក៏ដូចជា វាយតម្លៃ និងថ្លឹងថ្លែងលើភាពសមស្របនៃបច្ចេកវិទ្យាអប់រំ ដែលសក្តិសមនិងអាចទទួលយកបាន សម្រាប់ការប្រើប្រាស់ក្នុងបរិបទកម្ពុជា។ មជ្ឈមណ្ឌលបានប្រមូលផ្តុំនិងផលិតជាបន្តបន្ទាប់នូវមាតិកាឌីជីថលដែលមាន**ភាពពេញលេញ** (គ្រប់មេរៀន មុខវិជ្ជា និងកម្រិតថ្នាក់) **ពហុប្រភេទ** (វីដេអូ ឯកសារអំណាន សន្លឹកកិច្ចការ សៀវភៅសិក្សាគោល ធនាគារសំណួរ សៀវភៅអន្តរកម្ម) **សម្បូរបែប** (ការសិក្សាតាមបែបបញ្ញត្តិសង្ខេប ការសិក្សាតាមថ្នាក់រៀន ការសិក្សាដោយសំណួរ-ចម្លើយ) ប្រើប្រាស់**វេទិកាឌីជីថលចម្រុះ** (ជា Website: www.duraseksa.com និង IOS, Android App "ទូរសិក្សា - Duraseksa") ហើយមាន**លក្ខណៈចម្រុះ**(កុមារតូច បឋមសិក្សា មធ្យមសិក្សា អប់រំបច្ចេកទេស អប់រំក្រៅប្រព័ន្ធ អប់រំពិសេស អភិវឌ្ឍយុវជន ...)។




*រូបភាពគេហទំព័រវេបសាយ www.duraseksa.com លើផ្ទាំងកុំព្យូទ័រ*



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

គ្រូត្រូវណែនាំដល់សិស្សដែលមានកុំព្យូទ័រឱ្យចូលប្រើប្រាស់វេបសាយនេះ www.duraseksa.com ដើម្បីទទួលបានមាតិកាអប់រំ ដោយឥតគិតថ្លៃ មានសុវត្ថិភាពខ្ពស់ និងមានល្បឿនលឿន។ សម្រាប់សិស្សានុសិស្សដែលមានទូរស័ព្ទ Smartphone គ្រូត្រូវណែនាំពួកគេឱ្យ Download កម្មវិធី **Duraseksa-ទូរសិក្សា** ដែលមានសម្រាប់ប្រព័ន្ធ IOS និង Android។




***រូបភាពការចូល Download កម្មវិធី Duraseksa - ទូរសិក្សា App នៅក្នុង App Store រូបសញ្ញា Duraseksa - ទូរសិក្សា App នៅលើផ្ទាំង Screen ទូរសព្ទដៃ និងផ្ទាំងខាងមុខ របស់ទំព័រដំបូងនៃ Duraseksa - ទូរសិក្សា App***

បន្ទាប់ពី Download កម្មវិធី **Duraseksa-ទូរសិក្សា** រួចហើយសិស្សអាចចុះឈ្មោះ (Subscribe) ប្រើប្រាស់កម្មវិធីនេះតាម២របៀបដែលរបៀបទី១ គឺសិស្សអាចតភ្ជាប់ទៅកាន់ហ្វេសប៊ុកឬអ៊ីមែល ឬរបៀបទី២ គឺសិស្សត្រូវធ្វើការបំពេញព័ត៌មានមួយចំនួន។

ខ. ការអនុវត្តវិធីសាស្ត្រថ្នាក់រៀនត្រឡប់ (Flipped Classroom)

❖ ការរៀនតាមបែបស៊ីជម្រៅ (Enrichment Learning)

សិស្សត្រូវការធនធានសិក្សា ដែលមាន**ភាពពេញលេញ ពហុប្រភេទ សម្បូរបែប** និងមាន**លក្ខណៈចម្រុះ** ដើម្បីគាំទ្រដល់ដំណើរការរៀនដោយខ្លួនឯង ជាមួយមិត្តភក្តិ និងការរៀនក្នុងថ្នាក់។ ជាងនេះទៅទៀត សិស្សានុសិស្សត្រូវការវិធីសាស្ត្ររៀនផ្សេងៗគ្នា និងបរិស្ថាននៃការរៀនខុសៗគ្នា ដើម្បីកសាងសម្បទាអប់រំ ដែលផ្តោតលើចំណេះដឹង បំណិនអនុវត្តនិងចរិយាធម៌។ សិស្សានុសិស្ស

ដែលអនុវត្តការរៀនតាមបែបស៊ីជម្រៅ តែងប្រើប្រាស់ ធនធានសិក្សាច្រើនប្រភេទ លើសពីសៀវភៅសិក្សាគោលដែលផ្ដល់ដោយគ្រូ។ លើសពីនេះទៀត សិស្សដែលរៀនតាមបែបស៊ីជម្រៅ តែងតែចែករំលែកគ្នាទៅវិញទៅមកនូវធនធានសិក្សាដែលពួកគេអាចរកបាន ទៅកាន់ដៃគូសិក្សារបស់ខ្លួន។ ការរៀនតាមបែបស៊ីជម្រៅ (Enrichment Learning) ជាការរៀនដែល សិស្សដឹកនាំខ្លួនឯងឱ្យទទួលបានបទពិសោធលើសពីការរៀនក្នុងថ្នាក់ និងដោយប្រើធនធានសិក្សាតែមួយបែប តែជាការស្វែងរកឱកាសរៀនស្វែងយល់ និងទទួលការហ្វឹកហាត់យ៉ាងស៊ីជម្រៅ ទៅក្នុងមេរៀន បណ្ដុំមេរៀន មុខវិជ្ជា និងកម្រងមុខវិជ្ជា (Integrated Subjects)។ ការរៀនតាមបែបស៊ីជម្រៅ អាចមានកម្រិតផ្សេងៗគ្នា ទៅតាមស្ថានភាពនៃការរស់នៅ និងសាលារៀន រួមមានការបង្កើតកម្មវិធីសិក្សាក្រៅម៉ោងសិក្សា ការផ្ដល់វគ្គសិក្សាបំប៉នសមត្ថភាព ការចូលរួមសិក្ខាសាលាជំនាញ និងការចូលហ្វឹកហាត់ការងារ។

វិធីសាស្ត្ររៀនតាមបែបស៊ីជម្រៅដែលមានភាពងាយស្រួលបំផុតនិងដែលស្របជាមួយបរិបទនៃការអប់រំឌីជីថល គឺការរៀនដោយប្រើប្រាស់មាតិកាឌីជីថលបន្ថែម និងផ្សារភ្ជាប់ជាមួយការអនុវត្តវិធីសាស្ត្រថ្នាក់រៀនត្រឡប់ (Flipped Classroom)។ សិស្សអាចប្រើប្រាស់មាតិកាឌីជីថលដែល បានផលិតរួចដោយមជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថលនិងពីចម្ងាយ និងគួបផ្សំជាមួយការផ្លាស់ប្ដូរវិធីសាស្ត្របង្រៀនរបស់គ្រូនៅក្នុងថ្នាក់ ដោយការអនុវត្តវិធីសាស្ត្រថ្នាក់រៀនត្រឡប់។ មាតិកាឌីជីថលទាំងនេះផ្ដល់ឱកាសឱ្យសិស្សរៀនសូត្របន្ថែមជាមួយ ១. ការស្វែងយល់និងចងចាំបញ្ញត្តិនៃមេរៀន ២. ការធ្វើតេស្តសាកល្បងខ្លួនឯងមុនពេលចូលរៀន ៣. ការដោះស្រាយលំហាត់ពីកម្រិតងាយទៅលំបាក ៤. ការសិក្សាបន្ថែមក្នុងករណីដែលរៀនក្នុងថ្នាក់ពុំបានគ្រប់គ្រាន់ ៥. ការបំប៉នជំនួយស្មារតីដោយការសង្ខេបមេរៀន ឬរូបមន្ត និង ៦. ការត្រៀមខ្លួនសម្រាប់ការប្រឡងប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ ឬប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។

- ការប្រើប្រាស់មាតិកាលើ វេទិកា "Duraseksa - ទូរសិក្សា" សម្រាប់អនុវត្តវិធីសាស្ត្រថ្នាក់រៀនត្រឡប់

គ្រូអាចប្រើប្រាស់មាតិកាឌីជីថល ដែលមានផ្ទុកនៅក្នុងកម្មវិធីទូរសព្ទដៃ **Duraseksa-ទូរសិក្សា** ឬលើវេបសាយ www.duraseksa.com សម្រាប់ជាជំនួយដល់ការបង្រៀននៅក្នុងថ្នាក់រៀនទូទៅ ដើម្បីឱ្យសិស្សទទួលបានធនធានសិក្សាកាន់តែប្រសើរ ឬអាចសាកល្បងប្រើប្រាស់មាតិកាឌីជីថលទាំងនេះដើម្បីអនុវត្ត**វិធីសាស្ត្រថ្នាក់រៀនត្រឡប់**។ ជាគោលការណ៍សាមញ្ញក្នុងការអនុវត្តវិធីសាស្ត្រថ្នាក់រៀនត្រឡប់ គឺសិស្សត្រូវទទួលការណែនាំពីគ្រូ ឱ្យទស្សនាវីដេអូនិងមើលមេរៀននៅមុនពេលចូលរៀនក្នុងថ្នាក់ហើយគ្រូអាចបង្រៀនកាន់តែស៊ីជម្រៅលើមេរៀននីមួយៗនៅក្នុងថ្នាក់ និងកាន់តែមានលក្ខណៈ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បុគ្គលសម្រាប់សិស្ស បន្ទាប់មកសិស្សត្រូវអនុវត្តលំហាត់ ឬកិច្ចការផ្ទះបន្ថែម ជាលក្ខណៈសហការជាមួយមិត្តភក្តិ ឬដោយខ្លួនឯង។ សិស្សដែលមានលទ្ធភាពក៏អាចចំណាយពេលបន្ថែមជាមួយការងារនៅ**ក្លឹបសិក្សា** ចំណែកសិស្សដែលមានតម្រូវការរៀនបន្ថែមក៏អាចចូលរៀននៅ**ក្លឹបពន្លឿនការសិក្សា** ឬ**ក្លឹបមិត្តជួយមិត្ត** ដែលជាការសិក្សាដោយកិច្ចសហការ។

គោលការណ៍រួមនៃការប្រើប្រាស់វិធីបង្រៀន តាមបែបថ្នាក់រៀនត្រឡប់គឺ**ការណែនាំឱ្យសិស្សរៀនមុនចូលរៀនក្នុងថ្នាក់ ការបង្រៀនក្នុងថ្នាក់និងឆ្លើយតបចំពោះសំណួរឬចម្ងល់ជាបុគ្គលរបស់សិស្ស និងការជំរុញសិស្សឱ្យហ្វឹកហាត់អនុវត្តលំហាត់ កិច្ចការផ្ទះ ឬគម្រោងស្រាវជ្រាវបន្ទាប់ពីម៉ោងរៀនក្នុងថ្នា**ក់។ រូបភាពខាងក្រោមនេះ ជាវិបុលនៃការប្រើប្រាស់មាតិកាឌីជីថល ដែលមានក្នុងកម្មវិធីទូរសព្ទដៃ Duraseksa-**ទូរសិក្សា**ដែលគ្រូបង្រៀនអាចណែនាំសិស្សឱ្យប្រើប្រាស់នៅក្នុងវិធីសាស្ត្រថ្នាក់រៀនត្រឡប់។



*រូបភាពប្រភេទផ្សេងៗគ្នានៃមាតិកាឌីជីថលគាំទ្រដំណើរការថ្នាក់រៀនត្រឡប់*

ជាការអនុវត្តជាក់ស្តែង នៅ៥នាទីចុងក្រោយនៃម៉ោងសិក្សានីមួយៗ គ្រូត្រូវណែនាំសិស្សឱ្យសិស្សរៀនដោយខ្លួនឯង នៅផ្ទះឬនៅក្រៅម៉ោងរៀន ដោយប្រើប្រាស់**មាតិកាឌីជីថលដើម្បីត្រៀមខ្លួនមុនពេលចូលរៀនក្នុងថ្នាក់៖**

១. **វីដេអូសង្ខេបមេរៀន** ដែលវីដេអូនីមួយៗមានរយៈពេល ១០-១៥នាទី បកស្រាយខ្លឹមសារនៃមេរៀនដោយសង្ខេប

២. **សន្លឹកកិច្ចការសម្រាប់លើកកម្ពស់ការចងចាំ** ដែលមានប្រហែល ២-៣ទំព័រសម្រាប់មេរៀននីមួយៗ ហើយសិស្សអាចឆ្លើយសំណួរងាយៗសម្រាប់លើកកម្ពស់ការចងចាំមេរៀន

៣. **សន្លឹកកិច្ចការសម្រាប់ស្វែងយល់បញ្ញត្តិនៃមេរៀន** ពេលសិស្សបានមើល**វីដេអូមេរៀនសង្ខេប** និងអនុវត្តកិច្ចការលើ**សន្លឹកកិច្ចការសម្រាប់ លើកកម្ពស់ការចងចាំ** រួចរាល់ហើយ សិស្សអាចបន្តអាន **សន្លឹកកិច្ចការសម្រាប់ស្វែងយល់បញ្ញត្តិនៃមេរៀន** ដើម្បីត្រៀមខ្លួនចូលរៀនក្នុងថ្នាក់ឱ្យបានប្រសើរ។

ជាដំបូង សិស្សត្រូវចុចលើពាក្យ **"មេរៀនសង្ខេប"** ដើម្បីចូលទៅកាន់បណ្ណុំ**មាតិកាឌីជីថលដើម្បីត្រៀមខ្លួនមុនពេលចូលរៀនក្នុងថ្នាក់** រួចជ្រើសរើស**កម្រិតថ្នាក់** និងជាបន្តមកគឺជ្រើសរើស**មុខវិជ្ជា**សម្រាប់រៀន។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជាបន្តមក សិស្សត្រូវជ្រើសរើស**មេរៀន**ដែលត្រូវរៀនក្នុងថ្នាក់នៅ ថ្ងៃខាងមុខ ហើយបន្ទាប់មកត្រូវចុចលើពាក្យ "**ចូលរៀន**"។ បន្ទាប់ពីសិស្ស ទស្សនាវីដេអូរួចហើយ សិស្សអាចចុចលើពាក្យ "**ឯកសារ**" ដើម្បីស្វែងរក**សន្លឹកកិច្ចការសម្រាប់លើកកម្ពស់ការចងចាំនិងសន្លឹកកិច្ចការសម្រាប់ស្វែងយល់បញ្ញត្តិនៃមេរៀន**។



នៅអំឡុងម៉ោងសិក្សាក្នុងថ្នាក់ គ្រូបង្រៀនអាចសាកល្បងអនុវត្ត**វិធីសាស្ត្របង្រៀនតាមទ្រឹស្តីអប់រំបែបស្ថាបនានិយម**។ សម្រាប់សិស្សានុសិស្សដែលរៀនយឺត ពុំសូវយល់មេរៀន ឬមិនបានមករៀន គ្រូបង្រៀនអាចណែនាំសិស្សឱ្យទស្សនា **វីដេអូបង្រៀនទូទៅ** ដែលជាវីដេអូផលិតតាមមេរៀននីមួយៗជាលក្ខណៈនៃការបង្រៀនក្នុងថ្នាក់ដោយពិស្តារ ពន្យល់លម្អិត និងមានរយៈពេលពេញមួយម៉ោង។



ជាដំបូង សិស្សត្រូវចុចលើពាក្យ "**មេរៀនក្រសួងអប់រំ**" ដើម្បីចូលទៅកាន់បណ្ដុំ**មាតិកាឌីជីថលវីដេអូបង្រៀនទូទៅ** រួចជ្រើសរើស**កម្រិតថ្នាក់** និងជាបន្តមកគឺជ្រើសរើស**មុខវិជ្ជា**សម្រាប់រៀន។



ជាបន្តមក សិស្សត្រូវជ្រើសរើស**មេរៀន**ដែលត្រូវរៀនបំប៉នបន្ថែម ជាពិសេសចំពោះមេរៀនណាដែលសិស្សពុំសូវយល់ច្បាស់ ឬពុំបានរៀន ក្នុងថ្នាក់។ បន្ទាប់ពីសិស្សទស្សនាវីដេអូរួចហើយ សិស្សអាចចុចលើពាក្យ "ឯកសារ" ដើម្បីអានបន្ថែម នូវមេរៀនដែលមាននៅក្នុងសៀវភៅសិក្សាគោល។

នៅចុងបំផុតនៃម៉ោងសិក្សា បន្ទាប់ពីគ្រូណែនាំឱ្យសិស្សចេះប្រើប្រាស់**មាតិកាឌីជីថលដើម្បីត្រៀមខ្លួនមុនពេលចូលរៀនក្នុងថ្នាក់ នៅម៉ោងបន្ទាប់ទៀត** រួចរាល់ហើយ ជាទីបញ្ចប់គ្រូត្រូវណែនាំសិស្សឱ្យប្រើប្រាស់**មាតិកាឌីជីថលដើម្បីសិក្សាស៊ីជម្រៅលើមេរៀន បន្ទាប់ពីចប់ម៉ោងសិក្សាក្នុងថ្នាក់** ដោយកិច្ចសហការរវាងមិត្តភក្តិក្នុងថ្នាក់ ឬការរៀនជាក្លឹបសិក្សា រួមមាន ៖

១. **វីដេអូសំណួរចម្លើយ** ដែលជាវីដេអូបំផុសការយល់ដឹងរបស់សិស្សលើមេរៀននីមួយៗ ដោយការដាក់ជាសំណួរគន្លឹះ ឬលំហាត់សំខាន់ៗ និងមានការបកស្រាយលើកំណែ

២. **សៀវភៅលំហាត់អនុវត្តនិងកិច្ចការផ្ទះ៖** ជាការចងក្រងសំណួរ និងលំហាត់ទៅកម្រិតនៃភាពលំបាកសម្រាប់មេរៀននីមួយៗ ហើយដែលសៀវភៅនេះមានលំហទំនេរសម្រាប់សិស្សសរសេរចម្លើយ ហើយសិស្ស អាចយកសៀវភៅនេះមកសួរគ្រូបន្ថែមនៅម៉ោងសិក្សាក្រោយ ប្រសិនបើពួកគេពុំសូវយល់ច្បាស់លើលំហាត់ណាមួយ

៣. **សៀវភៅជំនួយស្មារតីរូបមន្តគន្លឹះ និងសង្ខេបមេរៀន** (កំពុងស្ថិតក្នុងដំណាក់កាលរៀបចំបន្ថែម) ជាសៀវភៅដែលចងក្រងរូបមន្តគន្លឹះ ការពន្យល់ខ្លីៗ ការបង្ហាញទ្រឹស្តីបទ ដែលសិស្សអាចទន្ទេញនិងចងចាំសម្រាប់មេរៀននីមួយៗ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៤. **ប្រព័ន្ធធ្វើតេស្តសមត្ថភាពសិស្ស** ជាប្រព័ន្ធមានភាពអន្តរកម្ម ដែលសិស្សអាចឆ្លើយសំណួរ ហើយវាយតម្លៃសមត្ថភាពដោយខ្លួនឯង ដែលសំណួរនីមួយៗត្រូវបានរៀបចំជាលំដាប់ៗ ទៅតាមកម្រិតនៃភាពលំបាក

ជាដំបូង សិស្សត្រូវចុចលើពាក្យ "**សំណួរ-ចម្លើយ**" ដើម្បីចូលទៅ កាន់បណ្តុំ**មាតិកាឌីជីថលដើម្បីសិក្សាស៊ីជម្រៅលើមេរៀន បន្ទាប់ពីចប់ម៉ោងសិក្សាក្នុងថ្នាក់** រួចជ្រើសរើស**កម្រិតថ្នាក់** និងជាបន្តមកគឺជ្រើសរើស**មុខវិជ្ជា**សម្រាប់រៀន។



រៀនតាមការពន្យល់របស់គ្រូក្នុងថ្នាក់រួចមក ដោយការទស្សនាវីដេអូស្តីសំណួរ-ចម្លើយទាក់ទងនឹងមេរៀននោះ ដោយចុចលើពាក្យថា "**ចូលរៀន**"។ បន្ទាប់ពីសិស្សទស្សនាវីដេអូរួចហើយ សិស្សអាចចុចលើពាក្យ "**ឯកសារ**" ដើម្បីទទួលបានកម្រងលំហាត់អនុវត្ត និងសំណួរទាក់ទងនឹងមេរៀននោះ ដើម្បីបន្តអនុវត្តជាលក្ខណៈសហការជាមួយមិត្តភក្តិ។



## ៧.១០ ការណែនាំសិស្សឱ្យចេះបង្កើតកាលវិភាគរៀន ជាលក្ខណៈបុគ្គល

ដោយសារការអនុវត្តវិធីសាស្ត្រថ្នាក់រៀនត្រឡប់ ត្រូវទាមទារឱ្យសិស្ស ផ្លាស់ប្តូរវិធីសាស្ត្ររៀន ជាពិសេសពីការពឹងផ្អែកទាំងស្រុងចំពោះការបង្រៀនរបស់គ្រូក្នុងថ្នាក់រៀន មកជាការរៀនដោយខ្លួនឯង និងជាលក្ខណៈសហការនៅមុន និងក្រោយពេលរៀនក្នុងថ្នាក់រៀន ដូច្នេះគ្រូត្រូវណែនាំសិស្សឱ្យចេះបង្កើតកាលវិភាគសិក្សាជាលក្ខណៈបុគ្គល។

**កាលវិភាគតាមថ្នាក់រៀនធម្មតា (ថ្នាក់ទី១២)**

| ម៉ោងសិក្សា | ចន្ទ | អង្គារ | ពុធ | ព្រហ. | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ៧:០០-៨:០០ | គណិត | គណិត | គណិត | ភូមិ | ប្រវត្តិ | ប្រវត្តិ | |
| ៨:០០-៩:០០ | គណិត | គណិត | ខ្មែរ | អង់គ្លេស | ជីវៈ | ភូមិ | |
| ៩:០០-១០:០០ | គីមី | ខ្មែរ | ពលរដ្ឋ | ជីវ | រូប | ពលរដ្ឋ | |
| ១០:០០-១១:០០ | ខ្មែរ | កីឡា | គីមី | រូប | រូប | ផែនដី | |
| | សម្រាក | | | | | | |
| ១៣:០០-១៤:០០ | | | | | | | |
| ១៤:០០-១៥:០០ | | | | | | | |
| ១៥:០០-១៦:០០ | | | | | | | |
| ១៦:០០-១៧:០០ | | | | | | | |

ជាទូទៅ សិស្សានុសិស្សទទួលបានការបង្រៀនក្នុងថ្នាក់ត្រឹមតែ៤ម៉ោងក្នុងមួយថ្ងៃ (២៤ម៉ោងសិក្សាក្នុង១សប្តាហ៍) គឺពុំបានដល់៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចដែលបានកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សាឡើយ គឺដូចគំរូកាលវិភាគខាងក្រោមនេះនៃសិស្សថ្នាក់ទី១២ ជាឧទាហរណ៍។ សិស្សានុសិស្សពុំបានឬមានលទ្ធភាពទាបក្នុងការចូលរួមប្រឡូកនៅក្នុងសកម្មភាពក្លឹបសិក្សាក្លឹបបំប៉នសម្រាប់សិស្សរៀនយឺត និងក្លឹបសម្រាប់សិស្សពូកែ។ ខាងក្រោមនេះ ជាការកែលម្អកាលវិភាគរៀនជាលក្ខណៈបុគ្គល ដោយមានមូលដ្ឋានលើកាលវិភាគខាងលើ ដែលអាចបង្កើនម៉ោងសិក្សាជាលក្ខណៈស្វ័យសិក្សា២ម៉ោង និងជាលក្ខណៈសហការ១ម៉ោង បន្ថែមទៀតក្នុង១ថ្ងៃ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## កាលវិភាគតាមថ្នាក់រៀនត្រឡប់ (ថ្នាក់ទី១២)

| ម៉ោងសិក្សា | ចន្ទ | អង្គារ | ពុធ | ព្រហ. | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ៧:០០-៨:០០ | គណិត | គណិត | គណិត | ភូមិ | ប្រវត្តិ | ប្រវត្តិ | អង់គ្លេស កុំព្យូទ័រ កីឡា |
| ៨:០០-៩:០០ | គណិត | គណិត | ខ្មែរ | អង់គ្លេស | ជីវៈ | ភូមិ | |
| ៩:០០-១០:០០ | គីមី | ខ្មែរ | ពលរដ្ឋ | ជីវៈ | រូប | ពលរដ្ឋ | |
| ១០:០០-១១:០០ | ខ្មែរ | កីឡា | គីមី | រូប | រូប | ផែនដី | |
| | សម្រាក | | | | | | |
| ១៣:០០- ១៤:០០ | M, C, K | M, K | M, K, I, C | G, B, P | H, B, P | H, G, I, E | |
| ១៤:០០-១៥:០០ | | | | | | ក្លឹប សិក្សា | |
| ១៥:០០-១៦:០០ | M | M, K | G, B, P | H, B, P | H, G | | M |
| ១៦:០០-១៧:០០ | K | I, C | | | I, E | | C, K |

១. ពណ៌ប្រផេះ (អង់គ្លេស ឬកុំព្យូទ័រ) ជាជម្រើសរបស់សិស្សក្នុងការបំប៉នចំណេះដឹងផ្នែកភាសាបរទេស ឬកុំព្យូទ័រ ឬអាចប្រើសម្រាប់ការកំសាន្តកីឡាមិត្តភាព

២. ពណ៌ខៀវ គឺជាម៉ោងសិក្សាជាក្រុម ឬជាបុគ្គលរបស់សិស្ស ដោយផ្តោតលើមាតិកាឌីជីថលសម្រាប់រៀនបន្ទាប់ពីម៉ោងរៀនក្នុងថ្នាក់រួមមាន វីដេអូសំណួរចម្លើយ សៀវភៅលំហាត់អនុវត្ត (កិច្ចការផ្ទះ) និងដោយមានជំនួយពីសៀវភៅជំនួយស្មារតី

៣. ពណ៌បៃតង គឺជាម៉ោងសិក្សាស្វ័យសិក្សានៅតាមផ្ទះ ឬកន្លែងសមរម្យណាមួយ ដោយផ្តោតលើមាតិកាឌីជីថលសម្រាប់រៀននៅមុន ម៉ោងរៀនក្នុងថ្នាក់ រួមមានវីដេអូសង្ខេបសន្លឹកកិច្ចការលើកកម្ពស់ការចងចាំ និងសន្លឹកកិច្ចការសិក្សាបញ្ញត្តិ

៤. ពណ៌លឿង គឺជាម៉ោងសម្រាប់ក្លឹបសិក្សាមុខវិជ្ជាដែលសិស្សដែលមានចំណូលចិត្តដូចគ្នាអាចរួមគ្នារៀនបង្កើតគម្រោង ក៏ដូចជាសម្រាប់សិស្សដែលរៀនយឺតលើមុខវិជ្ជាណាមួយអាចស្នើសុំការជួយគាំទ្របន្ថែមពីសិស្សពូកែក្នុងថ្នាក់ ឬក្នុងសាលា

៥. M: គណិតវិទ្យា, C: គីមីវិទ្យា, K: ភាសាខ្មែរ, I: សីលធម៌និងពលរដ្ឋ E: បរិស្ថាននិងផែនដី, G: ភូមិវិទ្យា, B: ជីវវិទ្យា, P: រូបវិទ្យា, H: ប្រវត្តិវិទ្យា

ឧទាហរណ៍៖ នៅថ្ងៃសុក្ររៀងរាល់សប្តាហ៍ សិស្សត្រូវរៀនមុខវិជ្ជាប្រវត្តិវិទ្យា ជីវវិទ្យា និងរូបវិទ្យា នៅក្នុងថ្នាក់រៀន។ ដូច្នេះ ដើម្បីលើកកម្ពស់ការរៀនតាមបែបថ្នាក់រៀនត្រឡប់ គឺសិស្សត្រូវរៀនមុខវិជ្ជាទាំង៣នេះ ដោយខ្លួនឯងនៅផ្ទះ (ពណ៌បៃតង) ដោយប្រើប្រាស់**មាតិកាឌីជីថលដើម្បីត្រៀមខ្លួនមុនពេលចូលរៀនក្នុងថ្នាក់**។ នៅក្នុងថ្នាក់រៀន គ្រូត្រូវអនុញ្ញាតឱ្យសិស្សសួរសំណួរដែលពួកគេពុំសូវយល់ច្បាស់។ សម្រាប់សិស្សដែលរៀនយឺត ឬពុំសូវយល់ច្បាស់ ឬខកខានពុំបានរៀននៅម៉ោងណាមួយ ពួកគេអាចប្រមូលផ្តុំគ្នាដើម្បីរៀន ជាក្លឹបសិក្សា **នៅរសៀលថ្ងៃសៅរ៍** (ពណ៌លឿង)។ ក្លឹបសិក្សានៅរសៀលថ្ងៃសៅរ៍នេះ ក៏អាចប្រើប្រាស់សម្រាប់សិស្សដែលមានចំណាប់អារម្មណ៍ លើការសិក្សាតាមការបង្កើតគម្រោង ឬក្លឹបសិក្សាមុខវិជ្ជា។ នៅពេលរសៀលបន្ទាប់ពីការរៀនក្នុងថ្នាក់ សិស្សអាចរៀនជាក្រុមដោយប្រើប្រាស់**មាតិកាឌីជីថលដើម្បីសិក្សាស៊ីជម្រៅលើមេរៀន បន្ទាប់ពីចប់ម៉ោងសិក្សាក្នុងថ្នាក់** លើមុខវិជ្ជាដែលទើបនឹងរៀនចប់ក្នុងថ្នាក់ (ពណ៌ផ្ទៃមេឃ)។

*ឧបសម្ព័ន្ធទី ១២ ៖ វិធីសាស្ត្រស្តាបនានិយមនិងថ្នាក់រៀនត្រឡប់*

៧.១១ សកម្មភាពបន្ថែមក្រៅម៉ោងសិក្សា

ក. និយមន័យ

សកម្មភាពបន្ថែមក្រៅម៉ោងសិក្សា សំដៅដល់ការរៀបចំកម្មវិធីអប់រំបន្ថែមតាមវិធីសាស្ត្រផ្សេងៗក្រៅពីសេវាបង្រៀននិងរៀនក្នុងថ្នាក់ប្រចាំសប្តាហ៍។

ខ. ទម្រង់នៃការរៀបចំសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា

សកម្មភាពបន្ថែមក្រៅម៉ោងសិក្សា អាចជាការសកម្មភាពក្លឹបសិក្សា ការងារគម្រោង ការអប់រំសហគ្រិនភាព កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបន្ថែម (តាមរយៈកិច្ចសហការជាមួយអ្នកផ្តល់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងមូលដ្ឋាន) ការរៀបចំវេទិកាជជែកពិភាក្សាអំពីអាជីព វេទិកាជជែក



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដេញដោល ដំណើរទស្សនកិច្ចសិក្សាអំពីការងារ ការសង្កេតការងារ ការរៀបចំពិព័រណ៍ស្នាដៃសិស្ស ការរៀបចំពិព័រណ៍ការងារខ្នាតតូច ការបំផុសស្មារតីចូលរួមរៀបចំព្រឹត្តិការណ៍ទិវាជាតិ (ទិវាគ្រូបង្រៀន ទិវាអក្ខរកម្ម ទិវាវប្បធម៌ ទិវាបរិស្ថាន ទិវាមច្ឆជាតិ រុក្ខទិវា...) ការចូលរួមសកម្មភាពស្ម័គ្រចិត្តការងារសង្គម (យុវជនកាកបាទក្រហម យុវជនកាយរឹទ្ធ ស្ម័គ្រចិត្តសហគមន៍)។ល។ ដែលសាលារៀនមានលទ្ធភាពជ្រើសរើសអនុវត្តនៅក្នុងផែនការប្រចាំឆ្នាំរបស់ខ្លួន។

គ. ការរៀបចំសេវាសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា

គណៈគ្រប់គ្រងសាលារៀន ត្រូវដាក់ចេញនូវសេវាសកម្មភាពបន្ថែមក្រៅសិក្សាតាមលទ្ធភាពដែលអាច រៀបចំបាន ដោយធ្វើយ៉ាងណាត្រូវបង្កលក្ខណៈឱ្យសិស្សម្នាក់ៗត្រូវតែទទួលបានឱកាសចូលរួមក្នុងសកម្មភាពបន្ថែមក្រៅម៉ោងសិក្សាណាមួយជាកាតព្វកិច្ច ក្នុងមួយឆ្នាំសិក្សា។

ដើម្បីឱ្យការងារនេះអាចដំណើរការទៅបាន គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវពិនិត្យជ្រើសរើសរកលោកគ្រូអ្នកគ្រូដែលមានសេវាម៉ោងបង្រៀនមិនទាន់គ្រប់តាមនិយាម (ករណី សាលារៀនលើសគ្រូ) ឬលោកគ្រូអ្នកគ្រូដែលមានឧបនិស្ស័យស្រឡាញ់ពេញចិត្តការអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា ស្របទៅនឹងកម្មវិធីអប់រំបន្ថែមដែលសាលារៀនគ្រោងនឹងអនុវត្តឱ្យជួយសម្របសម្រួលដឹកនាំកម្មវិធីទាំងនោះ ដោយមានលិខិតចាត់តាំង(លិខិតបង្គាប់ការ) ត្រឹមត្រូវ។ ជាមួយគ្នានេះ សាលារៀន ត្រូវប្រើប្រាស់យន្តការក្រុមប្រឹក្សាកុមារ និងយុវជនប្រចាំសាលារៀន ឱ្យជួយសម្របសម្រួលកិច្ចការងារតាមជាក់ស្ដែង។ សាលារៀនក៏អាចប្រើប្រាស់យន្តការសហគមន៍ ដើម្បីផ្ដល់ជាអ្នកជំនាញក្នុងការជួយដឹកនាំ បង្ហាត់បង្ហាញជាក់ស្ដែងពីសកម្មភាពក្រៅម៉ោង ដែលទាក់ទងនឹងកម្មវិធីបំណិនជីវិត និងកម្មវិធីក្រៅម៉ោងផ្សេងទៀត ទៅតាមលទ្ធផាពជាក់ស្ដែង។

សកម្មភាពបន្ថែមក្រៅម៉ោងសិក្សានីមួយៗ ត្រូវកំណត់ឱ្យមាន៖ ឈ្មោះក្រុម (ប្រធានបទសិក្សា) គោលបំណង និងបេសកកម្ម សមាសភាពចូលរួម រចនាសម្ព័ន្ធក្រុម (ប្រធាន អនុប្រធាន លេខាធិការ និងសមាជិក ត្រូវជ្រើសរើសតាមការស្ម័គ្រចិត្ត ឬការបោះឆ្នោត) ផែនការសកម្មភាពការងារ តម្រូវការសម្ភារៈ ធនធានគាំទ្រ។

ឃ. ក្របខណ្ឌពេលវេលា

សាលារៀន អាចពិនិត្យលទ្ធភាពក្នុងការរៀបចំសេវាសកម្មភាពបន្ថែមក្រៅម៉ោងសិក្សាក្នុងរូបភាពបត់បែនទន់ភ្លន់ និងមានការឯកភាពផ្ទៃក្នុងទៅលើការដាក់ចេញនូវក្របខណ្ឌពេលវេលា អាចជាទម្រង់សកម្មភាពប្រចាំថ្ងៃ ប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ឬប្រចាំឆ្នាំជាដើម អាស្រ័យលើចរិតលក្ខណៈនៃសកម្មភាពនីមួយៗ។ ក្នុងន័យនេះ សកម្មភាពមួយចំនួន គួរត្រូវបានរៀបចំឡើងជា

ប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ ដើម្បីជំរុញប្រសិទ្ធភាពនៃការចូលរួមរបស់សិស្សនៅម៉ោងទំនេរពីសេវារៀនក្នុងថ្នាក់។ ឧទាហរណ៍៖ សិស្សដែលមានសេវារៀនក្នុងថ្នាក់នៅពេលព្រឹក ពួកគេអាចចូលរួមសកម្មភាពបន្ថែមក្រៅម៉ោងសិក្សានៅពេលរសៀល ឬចូលរួមសកម្មភាពបន្ថែមក្រៅម៉ោងសិក្សានេះនៅពេលព្រឹកសម្រាប់សិស្សមានសេវារៀនក្នុងថ្នាក់ពេលរសៀល។ សាលារៀនក៏អាចពិនិត្យលទ្ធភាពបំផុសចលនាចូលរួមក្នុងទិវាជាតិផ្សេងៗដោយផ្អែកលើប្រក្រតិទិនប្រចាំឆ្នាំផ្លូវការ។

ង. ធនធានគាំទ្រ

ដើម្បីជំរុញប្រសិទ្ធភាព និងផ្តល់ការគាំទ្រដល់ដំណើរការអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សាបានពេញលេញ គណៈគ្រប់គ្រងសាលារៀន ត្រូវពិនិត្យលទ្ធភាពក្នុងការវិភាជន៍កញ្ចប់ថវិកាដំណើរការសាលារៀនសាធារណៈប្រចាំឆ្នាំ ឬធ្វើការកៀរគរប្រភពធនធាននិងថវិកា តាមរយៈការចូលរួមពីថវិកាមូលនិធិសហគមន៍ ថវិកាជាអំណោយទាន ថវិកាចូលរួមរបស់សិស្សផ្ទាល់ខ្លួន ថវិកាចូលរួមរបស់មាតាបិតាឬអ្នកអាណាព្យាបាលសិស្សឬថវិកាដែលទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

ថវិកាទាំងនេះ នឹងត្រូវប្រើប្រាស់ក្នុងគោលបំណងផ្តល់ការលើកទឹកចិត្តបន្ថែមដល់លោកគ្រូអ្នកគ្រូដែលចូលរួមចំណែកក្នុងការដឹកនាំសកម្មភាពសិស្ស និងផ្គត់ផ្គង់សម្ភារៈគាំទ្រនានា បម្រើឱ្យការអនុវត្តសេវាសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា។ ការចាត់ចែងធនធានទាំងឡាយ ត្រូវធានានូវសុខដុមនីយកម្មផ្ទៃក្នុង។

ច. យន្តការដំណើរការសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា

- មុនពេលដំណើរការ
  - គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ និងបុគ្គលិកអប់រំក្នុង សាលារៀន ត្រូវប្រជុំពិភាក្សាកំណត់ជ្រើសរើសយកទម្រង់សកម្មភាពបន្ថែមក្រៅម៉ោងសិក្សា និងយន្តការលម្អិតនៃកិច្ចដំណើរការសកម្មភាពទាំងនោះ មកអនុវត្តតាមស្ថានភាពជាក់ស្តែង។
  - គណៈគ្រប់គ្រងសាលារៀន ត្រូវផ្សព្វផ្សាយដល់សហគមន៍ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស និងសិស្សានុសិស្សក្នុងសាលារៀន ឱ្យបានដឹងឮ និងយល់ច្បាស់អំពីតម្រូវការចាំបាច់នៃការអនុវត្តសកម្មភាព បន្ថែមក្រៅម៉ោងសិក្សារបស់សិស្ស។
  - គណៈគ្រប់គ្រងសាលារៀនត្រូវសម្របសម្រួលរៀបចំសមាសភាពគ្រូតាមមុខវិជ្ជា ឬបុគ្គលិកទីចាត់ការ ឱ្យទទួលបន្ទុកដឹកនាំសម្របសម្រួល សកម្មភាពបន្ថែមក្រៅម៉ោងសិក្សាតាមស្ថានភាពជាក់ស្តែង។
  - ការរៀបចំសមាសភាពសិស្សចូលរួមតាមសកម្មភាពនីមួយៗ ត្រូវមានភាពចម្រុះ បរិយាបន្នដើម្បីធានាបាននូវបរិយាកាសសិក្សាបែបសហការ និងជួយគ្នាទៅវិញទៅមក។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- គណៈគ្រប់គ្រងសាលារៀន ត្រូវសម្របសម្រួលផ្គត់ផ្គង់សម្ភារៈផ្សេងៗគាំទ្រដល់ដំណើរការសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា តាមស្ថានភាពតម្រូវការ និងធនធានជាក់ស្តែង។
- គណៈគ្រប់គ្រងសាលារៀន ត្រូវចាត់ចែងទីកន្លែងអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា និងកាលវិភាគប្រើប្រាស់តាមស្ថានភាពជាក់ស្តែង។ សាលារៀនអាចប្រើប្រាស់បន្ទប់បំណិនជីវិតពហុបំណង បន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ បន្ទប់រៀនណាមួយដែលទំនេរ ជាកន្លែងអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា។

- អំឡុងពេលដំណើរការ

- លោកគ្រូអ្នកគ្រូដឹកនាំ និងសមាជិកក្រុមអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សានីមួយៗ ត្រូវពិភាក្សាកំណត់របៀបវារៈការងារតាមក្រុមរបស់ខ្លួន តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ និងកំណត់គោល ការណ៍ចាំបាច់ដូចមានបញ្ជាក់ក្នុងកថាខណ្ឌទី៣ នៃចំណុច ១.៣ ខាងលើ។
- លោកគ្រូអ្នកគ្រូដឹកនាំក្រុមត្រូវផ្តល់ការគាំទ្រផ្នែកស្មារតីនិងបច្ចេកទេសនិងសម្របសម្រួលបែងចែកការទទួលខុសត្រូវរបស់សមាជិកក្រុម ជំរុញឱ្យសមាជិកក្រុមគ្រប់រូបមានភាពសកម្មព្រមទាំងពិនិត្យតាមដានវឌ្ឍនភាពការងាររួម និងវាយតម្លៃឆ្លុះបញ្ចាំងជាប្រចាំ។
- ការអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា អាចនឹងត្រូវធ្វើឡើងនៅទីកន្លែងដែលគណៈគ្រប់គ្រងសាលារៀន និងសមាជិកក្រុមបានកំណត់ និងឯកភាពគ្នា ឬអាចរៀបចំឡើងក្នុងទម្រង់អនឡាញ។
- ក្នុងករណីចាំបាច់ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូទទួលបន្ទុកដឹកនាំក្រុមត្រូវសម្របសម្រួលអញ្ជើញវាគ្មិនក្នុងវិស័យនានាមកចែករំលែក និងផ្តល់ជាទស្សនាទានតម្រង់ទិសដល់សិស្ស ឬអាចរៀបចំជាដំណើរទស្សនកិច្ចសិក្សារបស់សិស្សទៅកាន់ស្ថាប័នគោលដៅពាក់ព័ន្ធ ដើម្បីផ្តល់នូវរូបភាពការងារជាក់ស្តែងដល់សិស្ស។
- ការអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា សិស្សត្រូវតែបង្កើតបានជាសមិទ្ធផលស្នាដៃដែលអាចវាស់វែងបាន ទោះបីក្នុងទម្រង់ជាឯកសារស្រាវជ្រាវ ឯកសារករណីសិក្សា របាយការណ៍អនុវត្តសកម្មភាព ស្នាដៃ ជាសមិទ្ធផលជាក់ស្តែង ឬវីដេអូនៃការរៀបចំសកម្មភាព ព្រឹត្តិការណ៍ ទិវាជាតិនានា។

- ក្រោយពេលដំណើរការ

- គណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធផល ស្នាដៃសិស្សដែលទទួលបាន តាមរយៈការអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សារបស់សិស្ស។

សមាសភាពគណៈកម្មការវាយតម្លៃនេះត្រូវដឹកនាំដោយនាយកឬនាយករង អមដោយសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន ប្រធានក្រុមតាមមុខវិជ្ជាពាក់ព័ន្ធ លោកគ្រូអ្នកគ្រូដឹកនាំក្រុម។

- គណៈកម្មការវាយតម្លៃត្រូវពិនិត្យលើស្នាដៃដាក់ស្ដែងឬស្ដាប់បទបង្ហាញតាមក្រុមនីមួយៗ ដើម្បីវាយតម្លៃដាក់ពិន្ទុកំណត់ជ័យលាភីស្នាដៃឆ្នើមតាមចំណាត់ថ្នាក់។
- គណៈកម្មការវាយតម្លៃត្រូវរៀបចំឧបករណ៍វាយតម្លៃឱ្យសមស្របទៅនឹងទម្រង់សកម្មភាពបន្ថែមក្រៅម៉ោងសិក្សារបស់សិស្ស ដោយធានាបាននូវយុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន។
- គណៈគ្រប់គ្រងសាលារៀនត្រូវពិនិត្យលទ្ធភាពរៀបចំជាប្រាក់រង្វាន់ឬសម្ភារៈរង្វាន់អមដោយបណ្ណសរសើរ១ច្បាប់ ទុកផ្ដល់ជូនក្រុមដែលទទួលបានជ័យលាភីស្នាដៃឆ្នើម និងលោកគ្រូអ្នកគ្រូដឹកនាំក្រុម។
- គណៈគ្រប់គ្រងសាលារៀន ត្រូវបង្កើតក្រុមការងាររៀបចំព្រឹត្តិការណ៍ពិព័រណ៍ស្នាដៃសិស្សដែលមានសមាសភាពចម្រុះពីសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន។

• ការពិនិត្យតាមដាន និងវាយតម្លៃ

ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការអនុវត្តសកម្មភាពបន្ថែមក្រៅម៉ោងសិក្សារបស់សិស្ស គណៈគ្រប់គ្រងសាលារៀន ត្រូវបញ្ចូលការងារនេះទៅក្នុងរបៀបវារៈកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់សាលារៀន ដើម្បីពិនិត្យវឌ្ឍនភាព បញ្ហាប្រឈម និងដាក់ចេញនូវវិធានការណ៍ដោះស្រាយបានទាន់ពេលវេលា ដើម្បីពង្រឹងគុណភាព នៃការផ្ដល់សេវាអប់រំកម្រិតសាលារៀន។

*ឧបសម្ព័ន្ធទី១៣៖ ឯកសារណែនាំប្រតិបត្តិស្ដីពី មគ្គុទ្ទេសក៍អាជីព និងការផ្ដល់ប្រឹក្សាសម្រាប់ គណៈគ្រប់គ្រងសាលារៀននិងគ្រូប្រឹក្សាតាមសាលារៀន*



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៧.១២ ផែនការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន កិច្ចព្រមព្រៀងការងារ និងគន្លងអាជីពគ្រូបង្រៀន

នៅដើមឆ្នាំសិក្សា(មុនបវេសនកាល) គណៈគ្រប់គ្រងសាលារៀន សហការជាមួយភាគីពាក់ព័ន្ធ រៀបចំផែនការគ្រប់គ្រងបុគ្គលិកដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា School-Management App/ Software៖

| សកម្មភាពគោល | សកម្មភាពរង | ក្របខណ្ឌពេលវេលា |
|---|---|---|
| - គ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក | - កត់ត្រាទិន្នន័យស្ថិតិបុគ្គលិក(មុខវិជ្ជា គុណវុឌ្ឍិ ជំនាញនិងក្របខណ្ឌ)<br>- វិភាគតម្រូវការបុគ្គលិកក្នុងអង្គភាព ដើម្បីដំណើរការស្នើសុំនិងជ្រើសរើសបន្ថែម | នៅដើមឆ្នាំសិក្សា |
| - គ្រប់គ្រងការបំពេញការងាររបស់គ្រូ | - គ្រប់គ្រងវត្តមានរបស់គ្រូ<br>- ត្រួតពិនិត្យការរៀបចំ និងគ្រប់គ្រងរដ្ឋបាលថ្នាក់ និងឯកសារបង្រៀនរបស់គ្រូ<br>- ត្រួតពិនិត្យការអនុវត្តការពណ៌នាការងារ (Job Description) | |
| - រៀបចំយន្តការ លើកទឹកចិត្ត និង ផែនការអភិវឌ្ឍ សមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលា | - រៀបចំកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ របាយការណ៍ និងគ្រប់គ្រងការបំពេញការងាររបស់គ្រូបង្រៀន និងមន្ត្រីអប់រំនៅសាលារៀន<br>- ព្រាងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ និងផែនការអភិវឌ្ឍ វិជ្ជាជីវៈដោយផ្អែកលើស្វ័យវាយតម្លៃសមត្ថភាព (ផ្អែកលើឯកសារស្តង់ដាវិជ្ជាជីវៈ គ្រូបង្រៀន៖ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈនិងសីលធម៌វិជ្ជាជីវៈ)<br>- ពិភាក្សានិងឯកភាពលើកិច្ចព្រមព្រៀងការងារ ប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈ<br>ដាក់ជូនគណៈគ្រប់គ្រងសាលាអនុម័តលើកិច្ចព្រមព្រៀងប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ សម្រាប់គ្រូបង្រៀន | |
| | - កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ របាយការណ៍ និង គ្រប់គ្រងការបំពេញការងាររបស់ គណៈគ្រប់គ្រងសាលា<br>- ព្រាងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ ផ្អែកលើស្វ័យវាយតម្លៃសមត្ថភាព (ផ្អែកលើឯកសារស្តង់ដានាយកសាលា)<br>- ពិភាក្សាជាមួយគណៈកម្មការគ្រប់គ្រងសាលារៀនលើកិច្ចព្រមព្រៀងការងារ ប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ<br>- ពិនិត្យនិងកែតម្រូវកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំនិងផែនការអភិវឌ្ឍវិជ្ជាជីវៈតាមការឯកភាព<br>- ដាក់ជូនក្រុមប្រឹក្សាសាលារៀន អនុម័តលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ។ | |

ការអភិវឌ្ឍសមត្ថភាព ដើរតួនាទីស្នូលក្នុងការធានាបាននូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងអង្គភាព ឬសាលារៀន ជាពិសេសធានាបាននូវគុណភាពសិក្សារបស់សិស្សប្រកបដោយនវានុវត្តន៍។

នៅដើមឆ្នាំសិក្សាគណៈគ្រប់គ្រងសាលាត្រូវរៀបចំការប្រជុំជាមួយភាគីពាក់ព័ន្ធនៅកម្រិតសាលារៀន ដើម្បីពិភាក្សារៀបចំផែនការសកម្មភាពអនុវត្តផែនការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈសម្រាប់បុគ្គលិកដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ។

ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈនៅកម្រិតសាលារៀន អាចរៀបចំឡើង តាមរយៈការចូលជាសមាជិកនៃសហគមន៍សិក្សាវិជ្ជាជីវៈ។ សមាជិកភាព នឹងទទួលបានការបំប៉ន និងអនុវត្តសកម្មភាពសំខាន់ៗ រួមមាន ការស្រាវជ្រាវប្រតិបត្តិ (Action Research) ការសិក្សាស្រាវជ្រាវមេរៀន (Lesson study) និងស្វ័យឆ្លុះបញ្ចាំងការប្រតិបត្តិ (Reflective Practice)។

| អ្នកទទួលផល | សមាសភាព | តួនាទីនិងភារកិច្ច | ដំណើរការអនុវត្ត |
|---|---|---|---|
| **គណៈគ្រប់គ្រងសាលា** | • ប្រធាន (អាចជានាយក ដែលមានស្នាដៃ ឬតំណាងគណៈអភិបាល)<br>• អ្នកសម្របសម្រួល (តំណាងនាយកឬនាយករង នៃសាលាបណ្តាញឬកម្រង)។<br>• សមាសភាពទាំងនេះត្រូវបាន តែងតាំង ឬជ្រើសរើសតាមរយៈការបោះឆ្នោត | - សិក្សាស្រាវជ្រាវលើការដឹកនាំ និងគ្រប់គ្រង សាលា<br>- ចែករំលែកបទពិសោធ និងចំណេះដឹងថ្មីៗ លើការដឹកនាំនិងគ្រប់គ្រងសាលារៀន<br>- រិះរកគោលនយោបាយនិងយុទ្ធសាស្ត្រថ្មីៗ ក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀន<br>- ជួយសមាជិកក្នុងកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន<br>- ជួយសមាជិកឱ្យអនុវត្តតាមគន្លងគណៈគ្រប់គ្រងសាលា<br>- វិភាគលទ្ធផលសិក្សារបស់សិស្ស និងរកវិធីកែលម្អលើការបង្រៀន និងរៀន<br>-អភិវឌ្ឍសមត្ថភាពសមាជិកជាប្រចាំ | - ប្រធានក្រុម ដឹកនាំសមាជិកពាក់ព័ន្ធរៀបចំផែនការសកម្មភាព និងកំណត់ពេលវេលាជាក់លាក់ និងអ្នកទទួល ខុសត្រូវក្នុងការ ចែករំលែក<br>- ប្រធានក្រុម និងអ្នកសម្របសម្រួល ដឹកនាំការជួបជុំគ្នាយ៉ាងតិច២ដងក្នុងមួយខែ(តាមជាក់ស្តែង) |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| **បុគ្គលិកបង្រៀន និងមិនបង្រៀន** | •ប្រធានម្នាក់ និងអ្នកសម្របសម្រួលម្នាក់ (អាចជាគ្រូបង្រៀនឬក្រុមបច្ចេកទេសដែលមានស្នាដៃ និងសមត្ថភាព)។ សមាស ភាពទាំងនេះ ត្រូវបានតែងតាំងឬជ្រើសរើសតាមរយៈការបោះឆ្នោតរៀងរាល់មួយឆ្នាំម្តង។ សហគមន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន រៀបចំដោយប្រើប្រាស់ក្រុមបច្ចេកទេសតាមមុខវិជ្ជាឯកទេស និងកម្រិតថ្នាក់ ដែលមានស្រាប់ ឬតាមក្រុមមុខវិជ្ជា (វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រ សង្គម)។ | - សិក្សាស្រាវជ្រាវទាក់ទងនឹងការបង្រៀន និងរៀន<br>- អនុវត្តការសិក្សាមេរៀន និងធ្វើថ្នាក់និទស្សន៍<br>- ចងក្រងឯកសារនិងយុទ្ធសាស្ត្របង្រៀននិងរៀនមានប្រសិទ្ធភាព<br>- ចែករំលែកបទពិសោធការស្រាវជ្រាវ និងប្រសិទ្ធភាពនៃការបង្រៀននិងរៀន ដែលទទួលបានពីប្រភពផ្សេងៗ តាម វិធីសាស្ត្រផ្សេងៗ<br>- ជួយបំប៉ន និងលើកកម្ពស់សមត្ថភាពសមាជិក ពាក់ព័ន្ធនឹងការបង្រៀននិងរៀន | ប្រធានក្រុម ដឹកនាំសមាជិកពាក់ព័ន្ធរៀបចំផែនការសកម្មភាព អ្នកទទួលខុសត្រូវ និងកំណត់ពេលវេលាជាក់លាក់ក្នុងការចែករំលែកដោយមានការឯកភាពគ្នា<br>- ប្រធានក្រុម និងអ្នកសម្របសម្រួលសហការជាមួយគណៈ គ្រប់គ្រងសាលា និងនាយករងបច្ចេកទេស ដើម្បីដឹកនាំការសិក្សានិងមានការចូលរួមសម្របសម្រួលពី ថ្នាក់ដឹកនាំ មន្ទីរ និងស្រុក។ ការសិក្សាជាក្រុមនេះ ត្រូវធ្វើឡើងរៀងរាល់សប្តាហ៍នៃខែនីមួយៗ។<br>- ប្រធានក្រុម មានតួនាទីបន្ថែមមួយទៀត គឺរៀបចំផែនការចុះ សង្កេតថ្នាក់រៀន (សង្កេតគ្រូចេញថ្មីមានបទពិសោធតិច ឬថ្នាក់រៀនដែលមានលទ្ធផលសិក្សាទាប) ដើម្បីផ្តល់ដំបូន្មាននិងការគាំទ្រវិជ្ជាជីវៈ។ ការសង្កេតនេះ ត្រូវធ្វើឡើង២ដងក្នុង មួយខែ។ |
| រាល់ការប្រជុំ ឬសង្កេតថ្នាក់រៀន និងប្រឹក្សាយោបល់នានាត្រូវមាន របាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬកស្តុតាងក្នុងអង្គភាព។ សមាជិកម្នាក់ៗត្រូវ ចងក្រងខ្លឹមសារ និងរក្សាទុកកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន។ | | | |

តួអង្គដែលបម្រើការនៅសាលារៀន រួមមាននាយកសាលា បុគ្គលិករដ្ឋបាល (បុគ្គលិកមិនបង្រៀន) និងគ្រូបង្រៀន ដែលតួអង្គទាំងនោះមានតម្រូវការ ជំនឿចិត្ត និងគោលដៅរបស់ខ្លួនច្បាស់លាស់។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញទឡ្ហីករណ៍ថា កត្តាដែលជំរុញបុគ្គលិកឱ្យប្រឹងប្រែងសម្រេចបានសមិទ្ធផលខ្ពស់ គឺការជំរុញទឹកចិត្តពីខាងក្នុង (ចំណាប់អារម្មណ៍ និងការចង់ចេះចង់ដឹងផ្ទាល់ខ្លួន) និងពីខាងក្រៅ (ការផ្តល់ រង្វាន់ ឬការសរសើរ)។ ការលើកទឹកចិត្តធ្វើឡើងក្រោមរូបភាពជា៖ ឱកាសអភិវឌ្ឍសមត្ថភាព ការផ្តល់ប្រាក់ លើកទឹកចិត្ត ការដំឡើងឋានៈ ការលើកទឹកចិត្តផ្នែកស្មារតី (ការសរសើរ) និងដំណើរទស្សនកិច្ចសិក្សាក្នុងនិងក្រៅស្រុក និងជាពិសេសទទួលបានឱកាសចូលគន្លងអាជីពគ្រូបង្រៀន។ ក្នុងការអនុវត្តគន្លងអាជីព គ្រូបង្រៀន បុគ្គលិកអប់រំ និងគ្រូបង្រៀនទាំងអស់ទទួលបាននូវអត្ថប្រយោជន៍តាមបីរូបភាព៖ ១) ទទួលបានឋានៈវិជ្ជាជីវៈ ២) ប្រាក់បំណាច់ឋានៈវិជ្ជាជីវៈទៅតាមកម្រិតឋានៈវិជ្ជាជីវៈនីមួយៗ និង៣) ទទួលបានឱកាសក្នុងការអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំ។ ការលើកទឹកចិត្ត ផ្អែកលើលទ្ធផលវាយតម្លៃការបំពេញការងារ និងលទ្ធផលសិក្សារបស់សិស្ស។

ក) ការផ្តល់ឋានៈវិជ្ជាជីវៈ

នៅពេលទទួលបានជោគជ័យក្នុងដំណើរការវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀនបុគ្គលិកអប់រំនឹងទទួលបានឋានៈវិជ្ជាជីវៈទៅតាមគន្លងនីមួយៗ។ ការទទួលបានឋានៈវិជ្ជាជីវៈនេះមិនប៉ះពាល់ដល់តួនាទីនិងមុខតំណែងនៅក្នុងប្រព័ន្ធមុខងារសាធារណៈឡើយ។ ខាងក្រោម ជាការបរិយាយលម្អិតនៃការផ្តល់ឋានៈវិជ្ជាជីវៈដែលគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលានឹងទទួលបាន៖

| | |
|---|---|
| - គ្រូល្អ<br>- នាយកល្អ | - ផ្សព្វផ្សាយឋានៈវិជ្ជាជីវៈជាសាធារណៈទូទាំងប្រទេសក្នុងទិវាគ្រូបង្រៀន<br>- ផ្សព្វផ្សាយឋានៈវិជ្ជាជីវៈនៅលើគេហទំព័រផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- រៀបចំវីដេអូនៃការបង្រៀន និងកិច្ចសម្ភាសដើម្បីរៀបចំជាកម្រងឯកសារដើម្បីផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។ |
| - គ្រូឈានមុខ<br>- នាយកឈានមុខ | - ផ្សព្វផ្សាយឋានៈវិជ្ជាជីវៈជាសាធារណៈទូទាំងប្រទេសក្នុងទិវាគ្រូបង្រៀន<br>- ផ្សព្វផ្សាយឋានៈវិជ្ជាជីវៈនៅលើគេហទំព័រផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- រៀបចំវីដេអូនៃការបង្រៀន និងកិច្ចសម្ភាសដើម្បីរៀបចំជាកម្រងឯកសារដើម្បីផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំជាមួយគ្រូឈានមុខ នាយកឈានមុខ ឬអ្នក ឯកទេសអប់រំឈានមុខដទៃទៀត។ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| - គ្រូឆ្នើម<br>- នាយកឆ្នើម | - ផ្សព្វផ្សាយឋានៈវិជ្ជាជីវៈនៅលើគេហទំព័រផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- រៀបចំវីដេអូនៃការបង្រៀន និងកិច្ចសម្ភាសដើម្បីរៀបចំជាកម្រងឯកសារដើម្បីផ្សព្វផ្សាយនៅលើគេហទំព័រ ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំជាមួយគ្រូឆ្នើម នាយកឆ្នើម ដទៃទៀត<br>- ទទួលបានការរៀបចំកម្មវិធីទទួលឋានៈវិជ្ជាជីវៈផ្លូវការដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអនុញ្ញាតឱ្យសមាជិកគ្រួសារបានចូលរួមផងដែរ។ |

ខ) ប្រាក់បំណាច់ឋានៈវិជ្ជាជីវៈ

ក្រៅពីទទួលបានឋានៈវិជ្ជាជីវៈខាងលើ បុគ្គលិកអប់រំ នឹងទទួលបានប្រាក់បំណាច់ឋានៈវិជ្ជាជីវៈតាមឋានៈនីមួយៗ។ ប្រាក់បំណាច់ឋានៈវិជ្ជាជីវៈទាំង៩ នៅក្នុងគន្លងអាជីពគ្រូបង្រៀន ត្រូវបានស្នើ និងដាក់បញ្ចូលក្នុងអនុក្រឹត្យស្តីពីការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។ ប្រាក់បំណាច់ឋានៈវិជ្ជាជីវៈនេះ នឹងត្រូវពិនិត្យឡើងវិញស្របពេលវេលាជាមួយនឹងការពិនិត្យឡើងវិញនូវប្រាក់បំណាច់មុខងារសាធារណៈ។ ប្រាក់បំណាច់ឋានៈវិជ្ជាជីវៈនីមួយៗ នឹងត្រូវបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

គ) ឱកាសក្នុងការអភិវឌ្ឍសមត្ថភាព

ក្រៅពីទទួលបាននូវប្រាក់បំណាច់ឋានៈវិជ្ជាជីវៈ គ្រូបង្រៀន និងគណៈគ្រប់គ្រង នឹងទទួលបាននូវឱកាសបន្ថែមសម្រាប់អភិវឌ្ឍសមត្ថភាព។ ការអភិវឌ្ឍសមត្ថភាព សំដៅដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការបង្កើនគុណវុឌ្ឍិតាមគ្រប់រូបភាព*(ដូចបញ្ជាក់ខាងលើ)*។ ខាងក្រោម ជាការបរិយាយឱកាសនៃការអភិវឌ្ឍសមត្ថភាពដែលនឹងទទួលបានទៅតាមឋានៈវិជ្ជាជីវៈនីមួយៗ៖

| | |
|---|---|
| - គ្រូល្អ<br>- នាយកល្អ | - ទទួលបានកញ្ចប់ថវិកាក្នុងចំនួនជាក់លាក់ណាមួយក្នុង១ឆ្នាំ សម្រាប់អភិវឌ្ឍសមត្ថភាព<br>- ទទួលបានឱកាសចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា<br>- ទទួលបានឱកាសចូលរួមសិក្ខាសាលាចែករំលែកបទពិសោធជាមួយគ្រូ ដែលមានជំនាញច្បាស់លាស់<br>- ទទួលបានឱកាសចូលរួមទស្សនកិច្ចសិក្សាពិសេសទៅកាន់សាលាគំរូ ដើម្បីដកស្រង់បទពិសោធ<br>- មានឱកាសទទួលបានភារកិច្ចជាគ្រូដឹកនាំដើម្បីជួយគ្រូតាំងស៊ប់។ |

| | |
|---|---|
| - គ្រូឈានមុខ<br>- នាយកឈានមុខ | - ទទួលបានកញ្ចប់ថវិកាក្នុងចំនួនជាក់លាក់ណាមួយក្នុង១ឆ្នាំ សម្រាប់អភិវឌ្ឍសមត្ថភាព<br>- ទទួលបានឱកាសចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា<br>- ទទួលបានឱកាសចូលរួមសិក្ខាសាលាចែករំលែកបទពិសោធជាមួយគ្រូដែលមានជំនាញច្បាស់លាស់<br>- ទទួលបានឱកាសចូលរួមទស្សនកិច្ចសិក្សាពិសេសទៅកាន់សាលាគំរូផ្សេងៗ ដើម្បីដកស្រង់បទពិសោធ<br>- មានឱកាសទទួលបានភារកិច្ចជាគ្រូដឹកនាំដើម្បីជួយគ្រូ និងនាយក។ |
| - គ្រូផ្ដើម<br>- នាយកផ្ដើម | - ទទួលបានកញ្ចប់ថវិកាក្នុងចំនួនជាក់លាក់ណាមួយក្នុង១ឆ្នាំសម្រាប់អភិវឌ្ឍសមត្ថភាព<br>- ទទួលបានឱកាសចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា<br>- ទទួលបានឱកាសចូលរួមសិក្ខាសាលាចែករំលែកបទពិសោធជាមួយគ្រូដែលមានជំនាញច្បាស់លាស់<br>- ទទួលបានឱកាសចូលរួមទស្សនកិច្ចសិក្សាពិសេសទៅកាន់សាលាគំរូនៅក្នុងបណ្ដាប្រទេសផ្សេងៗដើម្បីដកស្រង់បទពិសោធ<br>- មានឱកាសទទួលបានភារកិច្ចជាគ្រូដឹកនាំដើម្បីជួយគ្រូ និងនាយក។ |

*ឧបសម្ព័ន្ធទី១៤៖ គ្របខណ្ឌគន្លងអាជីពគ្រូបង្រៀន*

*ឧបសម្ព័ន្ធទី១៥៖ សៀវភៅណែនាំស្ដីពីការអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំមគ្គុទេសក៍ស្ដីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនៅកម្ពុជា*



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៧.១៣ ការអប់រំសីលធម៌

ក្នុងការសម្រេចអាទិភាពស្នូលទី២របស់ក្រសួងអប់រំ យុវជន និងកីឡា ផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្របញ្ចកោណគឺការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស។

ការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការអភិវឌ្ឍសង្គមផ្អែកលើចំណេះដឹង ជំនាញគឺចាក់ឫសយ៉ាងជ្រៅនៅក្នុងចក្ខុវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងក្រមសីលធម៌ខ្ពស់បំផុត។ ក្នុងនោះ ការបណ្តុះឱ្យយុវជនមាននូវចរិយាសម្បទា ក៏ជាចំណុចស្នូលមួយដែលក្រសួងយកចិត្តទុកដាក់ខ្ពស់ផងដែរ។

នៅក្នុងស្តង់ដាសាលាគំរូត្រង់ចំណុចស្តង់ដាទី២ ការរៀន និងការបង្រៀន គឺបានបញ្ជាក់បង្ហាញអំពីការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌ ដែលមានន័យសាលារៀនអនុវត្តកម្មវិធីលើកកម្ពស់ចរិយាធម៌ដូចជា ការរៀបចំឱ្យមានរបៀប ភាពស្អាត សុភាព របៀបរៀបរយ ការទៀងពេល និងការធ្វើសមាធិជាដើម។

ការអនុវត្តអប់រំសីលធម៌ក្នុងវិស័យអប់រំគឺត្រូវការការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដូចជា នាយកសាលា គ្រូបង្រៀន គណៈគ្រប់គ្រងសាលា អាណាព្យាបាល សហគមន៍ ថ្នាក់ដឹកនាំអប់រំគ្រប់ឋានានុក្រម ជាពិសេសព្រះសង្ឃក្នុងពុទ្ធសាសនានៅកម្ពុជា។

នៅក្នុងសង្គមកម្ពុជា តាំងពីអតីតរហូតបច្ចុប្បន្ន ព្រះពុទ្ធសាសនាដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអប់រំសីលធម៌និងអប់រំចិត្តដល់កុមារ យុវជន និងជនគ្រប់វ័យទាំងអស់នៅកម្ពុជា។

ការអប់រំសីលធម៌មានរបៀបផ្សេងៗគ្នាទៅតាមបរិបទនៃប្រទេសនីមួយៗ។ ដោយឡែកនៅប្រទេសកម្ពុជា ការអប់រំសីលធម៌ផ្តោតលើការអប់រំកាយវាចាចិត្តតាមបែបព្រះពុទ្ធសាសនា ដោយហេតុថាប្រពៃណី ទំនៀមទម្លាប់ សីលធម៌ សុជីវធម៌ និងឥរិយាបថប្រជាជនខ្មែរ បានផ្សារភ្ជាប់ទៅនឹងប្រពៃណីព្រះពុទ្ធសាសនា។ ម្យ៉ាងទៀត ប្រជាជនខ្មែរភាគច្រើនលើសលប់គោរពប្រតិបត្តិព្រះពុទ្ធសាសនា ហើយព្រះពុទ្ធសាសនាក៏ជាសាសនារបស់រដ្ឋដែលត្រូវបានចារឹកទុកក្នុងច្បាប់រដ្ឋធម្មនុញ្ញត្រង់មាត្រា៤៣ដែរ។

ក្នុងសម័យមុនសាលារៀនភាគច្រើនស្ថិតនៅក្នុងវត្ត ដូច្នេះកុមារ និងយុវជនខ្មែរបានទៅសិក្សានៅតាមវត្តអារាមនានា ដើម្បីក្រេបយកចំណេះវិជ្ជា និងជំនាញផ្សេងៗជាច្រើន ដែលអាចយកមកប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃបាន ហើយអ្វីដែលគួរឱ្យកត់សម្គាល់នោះ ពួកគេមានទាំងចំណេះដឹង ចំណេះធ្វើ រួមទាំងការប្រតិបត្តិសីលធម៌ និងចរិយាធម៌ នាំឱ្យក្លាយទៅជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ។ បច្ចុប្បន្នដោយការអប់រំមានការរីកចម្រើននៅគ្រប់ទីកន្លែង ហើយសាលារៀននិងវត្តអារាមក៏បានឃ្លាតឆ្ងាយពីគ្នា ខណៈ

ការអប់រំសីលធម៌បែបព្រះពុទ្ធសាសនាតាមរយៈព្រះសង្ឃនោះ ក៏បានឃ្លាតឆ្ងាយពីសិស្សានុសិស្ស និងយុវជនខ្មែរមួយកម្រិតដែរ។

នៅក្នុងសម័យបច្ចេកវិទ្យាឌីជីថល យើងសង្កេតឃើញថា ការផ្តល់ចំណេះដឹងផ្នែកសីលធម៌និងការអប់រំកាយវាចាចិត្តបែបព្រះពុទ្ធសាសនាមានសារៈសំខាន់ និងចាំបាច់សម្រាប់កុមារនិងយុវជន។ ទន្ទឹមនឹងគ្នានេះដែរ ព្រះសង្ឃនិងអ្នកជំនាញផ្នែកសីលធម៌ ក៏ពុំទាន់អាចដើរតួនាទីក្នុងការចុះទៅជួយអប់រំសីលធម៌នៅតាមសាលារៀនឱ្យបានគ្រប់ទិសទី នៅគ្រប់ភូមិសិក្សាបានដែរ ដែលកន្លងមកគេសង្កេតឃើញមានកម្មវិធីនិមន្តព្រះសង្ឃចុះទៅតិចតួចប៉ុណ្ណោះ។ ដូច្នេះ ដើម្បីជំរុញឱ្យកុមារនិងយុវជនទទួលបានការបណ្តុះបណ្តាលអប់រំសីលធម៌ ចរិយាធម៌ គុណធម៌ និងការអប់រំកាយវាចាចិត្ត ត្រូវមានការបញ្ជ្រាបនៅគ្រប់ភូមិសិក្សា ហើយត្រូវភ្ជាប់ការបណ្តុះបណ្តាលការអប់រំសីលធម៌ និងការអប់រំចិត្តបែបព្រះពុទ្ធសាសនាដល់នាយក គ្រូបង្រៀន គណៈគ្រប់គ្រង និងអាណាព្យាបាល និងគរុនិស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដើម្បីអនុវត្តផ្ទាល់ក្នុងការអភិវឌ្ឍខ្លួនឯង ហើយយកចំណេះដឹងផ្នែកសីលធម៌ទៅបន្តបង្ហាត់បង្រៀន និងអប់រំដល់សិស្សានុសិស្សនៅតាមសាលារៀន។

ការអប់រំសីលធម៌ដល់សិស្សគឺជាប្រព័ន្ធដែលមានឥទ្ធិពលលើស្មារតី អារម្មណ៍ និងអាកប្បកិរិយារបស់សិស្ស ដើម្បីបង្កើតគុណសម្បត្តិផ្នែកសីលធម៌របស់ពួកគេ ដែលឆ្លើយតបទៅនឹងតម្រូវការនៃសីលធម៌សាធារណៈ។ ការអនុវត្តអប់រំសីលធម៌ឱ្យមានប្រសិទ្ធភាពគឺជាដំណើរការគរុកោសល្យដ៏សំខាន់ដែលស្របគ្នាទៅនឹងបទដ្ឋានសីលធម៌សកលក្នុងការរៀបចំជីវិតរបស់ក្មេងជំទង់ ដោយផ្តោតលើការគិតសកម្មភាព ទំនាក់ទំនង និងការប្រាស្រ័យទាក់ទង ទៅតាមអាយុ និងលក្ខណៈបុគ្គលរបស់ពួកគេ។

ការអប់រំសីលធម៌រួមមាន: ការបង្កើតមនសិការនៃការតភ្ជាប់ជាមួយសង្គម ការពឹងផ្អែកលើតម្រូវការការសម្របសម្រួល អាកប្បកិរិយាជាមួយនឹងផលប្រយោជន៍របស់សង្គម ការយល់ដឹងជាមួយនឹងឧត្តមគតិសីលធម៌តម្រូវការនៃសង្គម ភស្តុតាងនៃភាពស្របច្បាប់និងសនិទានភាពរបស់ពួកគេ។ ការផ្លាស់ប្តូរចំណេះដឹងខាងសីលធម៌ទៅជាជំនឿសីលធម៌ គឺជាការបង្កើតប្រព័ន្ធនៃជំនឿទាំងនេះ។ ការបង្កើតអារម្មណ៍សីលធម៌ដែលមានស្ថេរភាព វប្បធម៌ខ្ពស់នៃអាកប្បកិរិយា ដែលជាការបង្ហាញសំខាន់មួយនៃការគោរពរបស់មនុស្សចំពោះមនុស្ស។

ក. ការបង្កើតទម្លាប់សីលធម៌

ការអប់រំសីលធម៌ដល់សិស្សគឺជាដំណើរការស្មុគស្មាញ និងពហុមុខរួមទាំងបាតុភូតគរុកោសល្យ និងសង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនៃការអប់រំសីលធម៌គឺមានស្វ័យភាពក្នុងកម្រិតនៃការអនុវត្តជាក់លាក់មួយ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ខ. ភារកិច្ចចម្បងនៃការអប់រំសីលធម៌

**១.ការបង្កើតមនសិការសីលធម៌៖** គឺជាដំណើរការសកម្មនៃការឆ្លុះបញ្ចាំងពីទំនាក់ទំនងសីលធម៌ពលរដ្ឋ ដែលជាកត្តាជំរុញនៃការអភិវឌ្ឍមនសិការសីលធម៌គឺការគិតខាងសីលធម៌។ ដំណើរការនៃការប្រមូលផ្តុំថេរ និងការយល់ដឹងពីការពិតខាងសីលធម៌ ផ្អែកលើស្ថានភាពនិងការវិភាគការវាយតម្លៃដើម្បីធ្វើការសម្រេចចិត្តខាងសីលធម៌ដែលធ្វើឱ្យជម្រើសរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ។

**២.ការអប់រំនិងការអភិវឌ្ឍអារម្មណ៍សីលធម៌៖** ជាបទពិសោធខាងសីលធម៌នៃការធ្វើការហ្វឹកហាត់សតិសម្បជញ្ញៈគឺជាការរួបរួមនៃអារម្មណ៍ ដែលឆ្លុះបញ្ចាំងនៅក្នុងស្មារតី និងការយល់ដឹង ការវាយតម្លៃការគិតខាងសីលធម៌។ សីលធម៌របស់មនុស្សត្រូវបានបង្កើតឡើងដោយគោលការណ៍សីលធម៌ដែលត្រូវបានគ្រប់គ្រង និងដឹកនាំក្នុងប្រព័ន្ធនៃទំនាក់ទំនង និងជំរុញការគិតខាងសីលធម៌ជាប់ជានិច្ច។ អារម្មណ៍សីលធម៌មនសិការនិងការគិតគឺជាមូលដ្ឋាននិងជាកម្លាំងជំរុញការបង្ហាញឆន្ទៈខាងសីលធម៌។ ប្រភពនៃទម្លាប់សីលធម៌ស្ថិតនៅក្នុងការរួបរួមនៃស្មារតីស៊ីជម្រៅ និងការវាយតម្លៃអារម្មណ៍ផ្ទាល់ខ្លួនអំពីបាតុភូតទំនាក់ទំនងរវាងមនុស្ស និងគុណភាពសីលធម៌របស់ពួកគេ។ ទម្លាប់សីលធម៌ គឺជាអក្ខរក្រមនៃគំនិត និងជំនឿខាងសីលធម៌។

**៣.ការអភិវឌ្ឍជំនាញនិងទម្លាប់នៃអាកប្បកិរិយាប្រកបសីលធម៌៖** ជាវិធីនៃការជ្រៀតចូលរបស់អ្នកអប់រំចូលទៅក្នុងពិភពខាងវិញ្ញាណរបស់សិស្សដោយមធ្យោបាយដ៏ទន់ភ្លន់បំផុត។ សីលធម៌របស់មនុស្សមានលំដាប់ដូចខាងក្រោម៖ ស្ថានភាពជីវិត បទពិសោធខាងសីលធម៌ និងអារម្មណ៍ដែលបង្កើតឡើងដោយការយល់ដឹងខាងសីលធម៌នៃស្ថានភាពនិងហេតុផលនៃអាកប្បកិរិយា ការជ្រើសរើស និងការសម្រេចចិត្តគឺជាការជំរុញទឹកចិត្តដ៏មុតមាំទៅលើទង្វើមួយ។

គ. រចនាសម្ព័ន្ធ និងមុខងារនៃការអប់រំសីលធម៌

ខ្លឹមសារនៃការអប់រំសីលធម៌ដល់សិស្សត្រូវបានកំណត់ ដោយតម្រូវការរបស់សង្គមសម្រាប់ការបង្កើតបុគ្គលិកលក្ខណៈដែលត្រូវបានអភិវឌ្ឍយ៉ាងទូលំទូលាយទៅលើកម្រិតនៃសីលធម៌របស់ពួកគេ។ ភារកិច្ចនៃការអប់រំសីលធម៌នៅសាលារៀនគឺបង្កើតស្មារតីជាតិ និងមនសិការរបស់សិស្សក្នុងបំណងប្រាថ្នារស់នៅដោយសុខដុមជាមួយធម្មជាតិ មនសិការវិន័យ កាតព្វកិច្ច និងការទទួលខុសត្រូវ ការគោរពច្បាប់ គោរពចំពោះមនុស្សចាស់ ស្ត្រី និងមនុស្សផងគ្នា។ ការបង្កើតមនសិការជាតិនិងការយល់ដឹងដោយខ្លួនឯងជំរុញឱ្យមានសេចក្តីស្រឡាញ់ចំពោះទឹកដីកំណើតខ្លួន ការត្រៀមខ្លួនដើម្បីធ្វើការក្នុងនាមពលរដ្ឋល្អដែលមានភាពស្ទាត់ជំនាញក្នុងតម្លៃជាតិ (ភាសា ទឹកដី វប្បធម៌) និងស្នេហាជាតិ រួមចំណែកដល់ការ

ជានាសេចក្ដីថ្លៃថ្នូររបស់ជាតិ ដែលត្រូវទាក់ទាញឱ្យសិស្សានុសិស្សអនុវត្តជាក់ស្ដែង បង្កើតនូវអារម្មណ៍ថ្លៃថ្នូរ និងមោទនភាពជាតិមាតុភូមិ។

ឃ. ប្រសិទ្ធភាពនៃការអប់រំសីលធម៌សិស្សអាស្រ័យទៅលើកត្តាដូចខាងក្រោម៖

- ការបង្កើតបរិយាកាសផ្លូវចិត្តនៅក្នុងស្ថាប័នអប់រំនៃការគោរពបទដ្ឋានសីលធម៌
- ច្បាប់នៃសង្គមមនុស្ស ដែលអនុលោមតាមខ្លឹមសារនៃការអប់រំសីលធម៌ជាមួយនឹងគោលដៅ និងកម្រិតនៃការអភិវឌ្ឍសីលធម៌របស់សិស្ស ទំនាក់ទំនងសមហេតុផលរវាងពាក្យសម្ដី និងវិធីសាស្ត្រជាក់ស្ដែងនៃឥទ្ធិពលអប់រំ ដែលជានាឱ្យមានឯកភាពនៃស្មារតី និងអាកប្បកិរិយាខាងសីលធម៌។
- ការអនុម័តវិធានការអប់រំទាន់ពេលវេលាលើការទប់ស្កាត់បាតុភូតអសីលធម៌របស់សិស្សានុសិស្ស ជាពិសេសគោលការណ៍សីលធម៌ ដែលបានប្រកាសដោយសាលាឱ្យអនុវត្ត ដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យខ្ពស់បំផុតនៃសីលធម៌។

ការអប់រំសីលធម៌ដល់កុមារគឺជាចំណុចសំខាន់នៃប្រព័ន្ធទូទៅ ក្នុងដំណើរអភិវឌ្ឍដ៏ទូលំទូលាយរបស់បុគ្គល។ ការអប់រំសីលធម៌ចាប់ផ្ដើមដោយមានគោលបំណងឱ្យកុមារយល់ដឹងតម្លៃសីលធម៌របស់មនុស្សជាតិនិងសង្គមជាក់លាក់មួយ ដើម្បីបង្កើតគុណសម្បត្តិ ចរិតលក្ខណៈ ជំនាញ និងទម្លាប់នៃអាកប្បកិរិយាប្រកបដោយសីលធម៌។

ក្មេងម្នាក់បានកើតមកក្នុងពិភពលោកនេះបានស្រូបយកអ្វីៗគ្រប់យ៉ាងរបស់មនុស្ស៖ វិធីនៃការប្រាស្រ័យទាក់ទង អាកប្បកិរិយា ទំនាក់ទំនង ការប្រើប្រាស់សម្រាប់ការសង្កេតផ្ទាល់ខ្លួន និងការសន្និដ្ឋាន ការក្លែងបន្លំ ពេលពេញវ័យ គេឆ្លងកាត់ការសាកល្បងនិងកំហុស ហើយអាចធ្វើជាម្ចាស់លើបទដ្ឋានបឋមនៃជីវិត និងអាកប្បកិរិយានៅក្នុងសង្គមមនុស្ស។

ការរៀបចំយុវជនសម្រាប់ជីវិតការងារ អ្នកអប់រំបង្រៀនកូនសិស្សឱ្យមានភាពស្លូតបូត ស្មោះត្រង់ មានគោលការណ៍ បង្រៀនឱ្យចេះស្រឡាញ់មាតុភូមិ ចេះធ្វើការរួមគ្នា និងអាកប្បកិរិយាយកចិត្តទុកដាក់ចំពោះមនុស្ស។

ង. ការអនុវត្តអប់រំសីលធម៌ ចរិយាធម៌ និងគុណធម៌

ដើម្បីឱ្យសិស្សមានសីលធម៌ ចរិយាធម៌ និងគុណធម៌ ចេះអប់រំកាយវាចាចិត្ត មិនមែនអនុវត្តចំពោះតែសិស្សខ្លួនឯងទេ ហើយក៏មិនមែនអនុវត្តតែមុខវិជ្ជាសីលធម៌ពលរដ្ឋនោះដែរ។ ការអនុវត្តអប់រំសីលធម៌គឺត្រូវចូលរួមធ្វើទាំងអស់គ្នា ទាំងគណៈគ្រប់គ្រង នាយកសាលា លោកគ្រូ អ្នកគ្រូ សិស្ស



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អាណាព្យាបាលសិស្ស នៅគ្រប់ទិដ្ឋភាពនៃសង្គមរួមមាន សាលារៀន គ្រួសារ និងសង្គមទូទៅ ដើម្បីឱ្យសិស្សានុសិស្សក្លាយទៅជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អជាសសរទ្រូងរបស់ប្រទេសជាតិ។

ច. វិធីសាស្ត្រនៃការអប់រំសីលធម៌ដល់សិស្ស

ការអប់រំសីលធម៌ដល់សិស្សត្រូវផ្សារភ្ជាប់នឹងការបង្រៀនរៀន និងជីវិតប្រចាំថ្ងៃ ដើម្បីឱ្យការអប់រំសីលធម៌មានប្រសិទ្ធភាព ត្រូវបែងចែកជាពីររបៀបនៃការអនុវត្តគឺទី១ ការអនុវត្តជាប្រចាំ និងទី២ការសិក្សាទ្រឹស្តី។

**របៀបទី១ ការអនុវត្តប្រចាំថ្ងៃ៖**

- **ការសូត្រធម៌ និងធ្វើសមាធិ**

មុនពេលចូលរៀនគ្រូបង្រៀននាំសិស្សៈ

- **ទី១ សូត្រធម៌សង្ខេបខ្លី**( *មើលក្នុងសៀវភៅការអប់រំសីលធម៌និងការអប់រំចិត្ត*)ឬអាចសូត្រសង្ខេបៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។**

ប្រែថាៈ រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។ ( *សូត្រតែបាលីសុទ្ធ ឬពាក្យប្រែក៏បាន*)

- **ទី២ ធ្វើសមាធិ**

បន្ទាប់ពីសូត្រធម៌សង្ខេបរួច លោកគ្រូ អ្នកគ្រូដឹកនាំធ្វើសមាធិដោយអង្គុយស្ងប់ស្ងៀម ហើយណែនាំពីវិធីធ្វើសមាធិសម្រាប់សិស្ស តាមរយៈប្រើឥរិយាបថអង្គុយសមាធិ(លើកៅអី )គឺ៖

-ដាក់ជើងទាំងពីរទន្ទឹមគ្នា

-ដាក់ដៃស្តាំលើដៃឆ្វេង

-តម្រង់ដងខ្លួនឱ្យត្រង់

-តម្រង់មុខឱ្យត្រង់

-ផ្តោតលើដង្ហើមចេញចូល។

បន្ទាប់មក ឱ្យសិស្សប្រមូលអារម្មណ៍ចូលក្នុងថ្នាក់រៀន រួចយកចិត្តមកដាក់ត្រង់ដើមទ្រូង បន្ទាប់មកត្រូវពិនិត្យមើលខ្យល់ដង្ហើមចេញចូល ដោយមានសតិស្មារតីជាប់ជានិច្ច ហើយដឹងនូវខ្យល់ដង្ហើម

ចេញវែង ចូលវែង ដោយមិនឱ្យចិត្តគិតរឿងអ្វីៗទាំងអស់។ ធ្វើដូច្នេះ រយៈពេល ចន្លោះពី៥ទៅ៧នាទី សម្រាប់កម្រិតបឋមភូមិ និង ពី៧ទៅ១០នាទីសម្រាប់កម្រិតទុតិយភូមិ។

មុននឹងបញ្ចប់ការធ្វើសមាធិ១នាទីត្រូវបង្រៀនសិស្សឱ្យចេះផ្សាយមេត្តាដោយនាំឱ្យថាតាមដូច្នេះ៖

- សូមឱ្យខ្ញុំមានសេចក្តីសុខ សេចក្តីចម្រើន ប្រាស់ចាកទុក្ខទាំងពួង
- សូមឱ្យលោកឪពុកអ្នកម្តាយ លោកគ្រូអ្នកគ្រូមានសេចក្តីសុខ សេចក្តីចម្រើន ប្រាស់ចាកទុក្ខទាំងពួង
- សូមឱ្យមិត្តរួមថ្នាក់និងមនុស្សទាំងអស់មានសេចក្តីសុខ សេចក្តីចម្រើន ប្រាស់ចាកទុក្ខទាំងពួក
- សូមឱ្យមនុស្សសត្វទាំងអស់កុំបៀតបៀនគ្នានឹងគ្នា។

ការអនុវត្តសូត្រធម៌ និងធ្វើសមាធិនេះ បើមិនអាចអនុវត្តបាននៅតាមថ្នាក់រៀន រាល់ម៉ោងរៀន និងគ្រប់មុខវិជ្ជាទេ ក៏អាចឱ្យអនុវត្តនៅពេលគោរពទង់ជាតិ តាមរយៈឈរសូត្រធម៌ និងធ្វើសមាធិរួមគ្នា ដោយប្រើឥរិយាបថឈរ រយៈពេល៥ ទៅ៧ នាទី រៀងរាល់ថ្ងៃចន្ទ ឬក្នុងថ្ងៃណាមួយនៃសប្តាហ៍។ បន្ទាប់ពីគោរពទង់ជាតិរួច នាយកសាលា ឬនាយករង ឬគ្រូផ្នែកពង្រឹងវិន័យសាលាណែនាំសិស្សសូត្រធម៌ រួចធ្វើសមាធិដោយប្រើឥរិយាបថឈរសមាធិគឺ:

១.ដាក់ជើងទាំងពីរទន្ទឹមគ្នា ( *ជើងទាំងពីគម្លាតល្មមកុំឱ្យឈរទប់លំនឹងមិនត្រង់*)

២.ដាក់ដៃទាំងពីរទម្លាក់ចុះត្រង់ឬឱបដៃដាក់ទៅខាងមុខ

ឬខាងក្រោយ ដោយយកដៃស្តាំចាប់លើដៃឆ្វេង

៣.ឈរតម្រង់ដងខ្លួនឱ្យត្រង់

៤.ឈរតម្រង់មុខឱ្យត្រង់ កុំឈ្ងោកពេក ងើបពេក

៥.បិទភ្នែក (បើឈរមិននឹង បិទភ្នែកតែ៧៥%ក៏បាន)

៦.ផ្តោតលើដង្ហើមចេញចូល។ *បន្ទាប់មកអនុវត្តដូចការអង្គុយសមាធិខាងលើដែរ។*

វិធីឈរសមាធិនេះ អាចអនុវត្តក្នុងថ្នាក់រៀនបានដូចគ្នា មុនពេលចាប់ផ្តើមមុខវិជ្ជារៀនប្រចាំថ្ងៃ។ *(មើលលម្អិតក្នុងសៀវភៅវិធីសាស្ត្រគ្រប់គ្រងកំហឹង និងសៀវភៅវិធីសាស្ត្រគ្រប់គ្រងចិត្តមួយជំហានម្តងៗ)*

❖ **ការប្រើប្រាស់ពាក្យសំដី និងឥរិយាបថប្រកបសីលធម៌ក្នុងសាលារៀន**

- លោកគ្រូ អ្នកគ្រូត្រូវណែនាំសិស្សជាប្រចាំក្នុងការប្រើប្រាស់ពាក្យពេចន៍ ភាសានិយាយពេលគឺឱ្យសុភាពរាបសារ ពាក្យគោរពចំពោះលោកគ្រូ អ្នកគ្រូ និងការប្រើសង្ឃស័ព្ទ និងរាជស័ព្ទជាដើម។ *(មើលលម្អិតក្នុងសៀវភៅការអប់រំសីលធម៌ និងអប់រំចិត្ត)*



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- លោកគ្រូ អ្នកគ្រូត្រូវណែនាំសិស្សានុសិស្សជាប្រចាំក្នុងការប្រើឥរិយាបថ ដោយឱ្យពួកគេចេះប្រើឥរិយាបថ**ឱនលំទោន ចេះគោរព សំពះជម្រាបសួរ** លោកនាយក លោកគ្រូ អ្នកគ្រូជាប្រចាំ។ មួយវិញទៀត ណែនាំឱ្យសិស្សចេះគោរពតួនាទីជាសិស្ស និងការរាប់អានចំពោះមិត្តរួមថ្នាក់ ឱ្យចេះស្រឡាញ់ អត់ឱនគ្នា ចេះជួយគ្នា និងជៀសវាង រាល់អំពើហិង្សា និងការឈ្លោះប្រកែកគ្នាជាដើម។
- លើសពីនេះ ការអនុវត្តសីលធម៌ក្នុងបរិវេណសាលារៀន គឺនាយក លោកគ្រូ អ្នកគ្រូ ត្រូវណែនាំឱ្យអនុវត្តជាប្រចាំចំពោះការគោរព គណៈគ្រប់គ្រង នាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សផងគ្នា ដោយពាក្យសម្ដី និងឥរិយាបថសមរម្យជានិច្ច។ ពិសេសជាងនេះ ត្រូវណែនាំឱ្យចេះគោរពលើកដៃប្រណមសំពះចំពោះរូបបដិមាដែលជាទីសក្ការៈដូចជា **ព្រះពុទ្ធរូប រូបព្រះសំណាក់ព្រះបាទ ជ័យវរ្ម័នទី៧ រូបសំណាក់សម្ដេចសង្ឃរាជជួន ណាត**ជាដើម។
- នាយក លោកគ្រូ អ្នកគ្រូក៏ត្រូវណែនាំជាប្រចាំនូវសីលធម៌ក្នុងការប្រើប្រាស់ស្ថានទីសិក្សាដូចជា៖ ណែនាំឱ្យសិស្សទាំងអស់ចេះជួយថែទាំហេដ្ឋារចនាសម្ព័ន្ធសាលារៀន ចេះដឹងពីការវេចខ្ចប់ និងការចោលសម្រាមឱ្យមានរបៀបរៀបរយ ការចូលរួមធ្វើអនាម័យជាប្រចាំទាំងក្នុងថ្នាក់រៀន បរិវេណសាលា និងពិសេសការជួយសម្អាតធ្វើអនាម័យបន្ទប់ទឹក។
- លោកនាយក លោកគ្រូ អ្នកគ្រូក៏ត្រូវណែនាំជាប្រចាំនូវការអនុវត្តសីលធម៌ក្នុងគ្រួសារស្ដីពីតួនាទីកូនចំពោះឪពុកម្ដាយដូចជា៖
    - ការគោរពចំពោះឪពុកម្ដាយ
    - ការជួយកិច្ចការងារ
    - ការខិតខំរៀនសូត្រ
    - ការគោរពស្រឡាញ់បងប្អូន។ *(មើលលម្អិតក្នុងសៀវភៅ ការអប់រំសីលធម៌ និងអប់រំចិត្ត)*
- លោកនាយក លោកគ្រូ អ្នកគ្រូក៏ត្រូវណែនាំជាប្រចាំនូវការចូលរួមសកម្មភាពសហគមន៍៖
    - ការគោរពច្បាស់ចរាចរណ៍
    - ការបោសសម្រាម
    - ការចោលសម្រាម
    - ការគោរពនិងឱ្យតម្លៃសម្បត្តិសាធារណៈ។

- លោកនាយក លោកគ្រូ អ្នកគ្រូក៏ត្រូវណែនាំជាប្រចាំនូវការចូលរួមការអនុវត្តសីលធម៌នៅតាមទីសាធារណៈ៖
    - ការគោរពចំពោះរូបបដិមា
    - វត្តអារាម
    - ប្រាសាទ
    - ទីសក្ការៈបូជា
    - តំបន់ប្រវត្តិសាស្ត្រ
    - រមណីយដ្ឋានប្រវត្តិសាស្ត្រ
    - តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ
- លោកនាយក លោកគ្រូ អ្នកគ្រូក៏ត្រូវណែនាំជាប្រចាំនូវការអនុវត្តសីលធម៌ក្នុងជីវិតប្រចាំថ្ងៃ៖
    - របៀបសំពះ
    - ចរិយាធម៌ និងសុជីវធម៌ក្នុងជីវិតប្រចាំថ្ងៃ
    - សុជីវធម៌ពេលនៅក្នុងវត្តអារាម
    - ពេលទៅទស្សនកិច្ចនៅតាមទីកន្លែងផ្សេងៗ
    - នៅពេលធ្វើដំណើរតាមផ្លូវ
    - របៀបទទួលភ្ញៀវ និង
    - សុជីវធម៌ភ្ញៀវ។

❖ **មេរៀនសិក្សាទ្រឹស្តីសីលធម៌ផ្សារភ្ជាប់នឹងការអនុវត្តផ្ទាល់៖**

- ការប្រើសង្ឃស័ព្ទ រាជស័ព្ទ
- របៀបសំពះ
- ការគ្រប់គ្រងអត្តចរិត ឥរិយាបថ
- របៀបគ្រប់គ្រងចិត្ត(អារម្មណ៍)
- របៀបគ្រប់គ្រងកំហឹង
- ពុទ្ធប្បវត្តិ
- មង្គលសូត្រ
- សិង្គាលកសូត្រ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- របៀបទាក់ទងមនុស្សក្នុងសង្គមមនុស្ស
- មង្គលជីវិត
- វិធីសាស្ត្រដោះស្រាយហិង្សាតាមយន្តការសន្តិសហវិជ្ជមាន និង
- ព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងការអប់រំ។

❖ **ការអនុវត្តកម្មវិធីអប់រំសីលធម៌**

កម្មវិធីអប់រំសីលធម៌ជាកម្មវិធីមួយ ដែលមានការសហការដឹកនាំរៀបចំដោយព្រះសង្ឃ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អាជ្ញាធរ និងអាណាព្យាបាលនៅតាមសាលារៀននោះៗ៖

**ទី១.កម្មវិធីអប់រំសីលធម៌រួម៖** ជាកម្មវិធីអប់រំរួមគ្នា ដែលអាចរៀបចំឡើងរយៈពេលមួយព្រឹក ឬពេញមួយថ្ងៃ ផ្តោតលើការអនុវត្ត និងស្តាប់ធម៌ទេសនាស្តីពី **សីលធម៌ ចរិយាធម៌ គុណធម៌ គុណមាតាបិតា គុណគ្រូ តួនាទីកូននិងតួនាទីសិស្ស ព្រមទាំងការធ្វើសមាធិ**ជាដើម ដោយមានការចូលរួមពីនាយក គ្រូបង្រៀននិងសិស្សានុសិស្សទាំងអស់។ កម្មវិធីនេះជាកម្មវិធីធំមួយដែលត្រូវការសហការត្រៀមរៀបចំ ពីគ្រប់អ្នកពាក់ព័ន្ធ ហើយក្នុងសាលារៀននីមួយៗអាចប្រារព្ធធ្វើបានពី២ ទៅ៣ ដងក្នុងមួយឆ្នាំ។

**ទី២.កម្មវិធីចុះអប់រំតាមសាលា៖** ចំពោះសាលារៀនដែល មានព្រះសង្ឃ អ្នកអប់រំសីលធម៌ មានកម្មវិធីបង្រៀនសីលធម៌ អាចចុះជួយបង្រៀនតាមថ្នាក់រៀនមួយម៉ោង ក្នុងមួយសប្តាហ៍ម្តង។

**ទី៣.កម្មវិធីផ្តល់ឱវាទ៖** គណៈគ្រប់គ្រងអាចនិមន្តព្រះសង្ឃ ដែលមានចំណេះដឹងផ្នែកការអប់រំសីលធម៌ ផ្តល់ឱវាទរួម នៅពេលគោរពទង់ជាតិ ក្នុងមួយសប្តាហ៍ ឬកន្លះខែម្តង ដោយប្រើរយៈពេលពី២០ ទៅ៣០នាទី។ មួយវិញទៀត បើសាលារៀនមានព្រះសង្ឃជាគណៈកម្មការស្រាប់ ក៏អាចនិមន្តព្រះអង្គឱ្យមកជួយផ្តល់ឱវាទផងដែរ។

**ទី៤.អប់រំសីលធម៌ផ្សារភ្ជាប់កម្មវិធីនានា៖**

- ការនាំសិស្សានុសិស្សទៅវត្តអារាម និងបូជនីយដ្ឋានផ្សេងៗ
- ការអប់រំសីលធម៌ចំពោះបរិស្ថាន
- ការដឹកនាំសិស្សានុសិស្សដាំកូនឈើ និងថែរក្សា ការពារដើមឈើ
- ការបណ្តុះការស្រឡាញ់ដើមឈើនៅក្នុងសាលារៀន និងតាមភូមិស្រុកជាដើម
- ការបង្កើតកម្មវិធីបំប្លែសដើមឈើធំៗ ទាំងនៅក្នុងបរិវេណនិងក្រៅសាលារៀន
- ការបង្កើតកម្មវិធីទស្សនកិច្ចសិក្សាទៅកាន់តំបន់ដែលមានព្រៃឈើច្រើន
- បណ្តុះការហ្វឹកហាត់ឱ្យចេះធ្វើការងារជាក្រុមតូចៗ រហូតដល់ក្រុមធំនៅក្នុងសាលា

- ការបណ្ដុះស្មារតីស្រឡាញ់មនុស្សជាតិ ដោយគ្មានការរើសអើងជាតិសាសន៍
- ការបណ្ដុះមនសិការជាតិ ស្មារតីស្រឡាញ់ប្រទេសជាតិ
- ការប្រព្រឹត្តប្រកបដោយសីលធម៌សម្រាប់ប្រទេសជាតិ និងពិភពលោក
- ការបណ្ដុះគំនិតថា ពួកយើងជាផ្នែកមួយនៃពិភពលោក ហើយពិភពលោកក៏ជាផ្នែកមួយនៃពួកយើងដែរ។

**ទី៥.ការអប់រំសីលធម៌បែបឌីជីថល៖** ព្រះសង្ឃ និងអ្នកជំនាញសីលធម៌អាចបង្កើតជាអែប (APP)ការអប់រំសីលធម៌សម្រាប់សិស្សានុសិស្ស សហការជាមួយអ្នកជំនាញ ដោយប្រមូលចងក្រងគោលអប់រំសីលធម៌សំខាន់ៗបញ្ចូលក្នុងអែប ដើម្បីជាមេរៀនសម្រាប់សិស្សានុសិស្សអាចសិក្សាបានគ្រប់ទិសទីនិងគ្រប់ពេល ដែលដើរទៅព្រមជាមួយសម័យបច្ចេកវិទ្យាឌីជីថលគឺជា «ការអប់រំសីលធម៌បែបឌីជីថល»។ អែបការអប់រំសីលធម៌នេះ នឹងធ្វើឱ្យសិស្សអាចសិក្សាស្វែងយល់បន្ថែមក្នុងការតម្រង់ទិសការអនុប្រចាំថ្ងៃប្រកបដោយសីលធម៌ខ្ពស់។

*ឧបសម្ព័ន្ធទី១៦៖ សំណុំឯកសារការអប់រំសីលធម៌*

### ៧.១៤ ការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍

ចំណុចនៃការអនុវត្តការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ គឺឆ្លើយតបទៅនឹងស្តង់ដាទី ៣.ការចូលរួមរបស់សហគមន៍ នៃស្តង់ដាសាលាមធ្យមសិក្សាគំរូ។

ក.ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន (ត្រូវយកតាមសេចក្តីណែនាំលេខ០៩ អយក.សណន ស្តីពីការបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ)

នៅដើមឆ្នាំសិក្សា នាយកសាលា ដឹកនាំការប្រជុំជាមួយភាគីពាក់ព័ន្ធនៅកម្រិតសាលារៀន ដើម្បីដំណើរការបោះឆ្នោតជ្រើសរើសសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ដើម្បីចូលរួមក្នុងការងារដឹកនាំ និងគ្រប់គ្រងសាលារៀនប្រកបដោយអភិបាលកិច្ចល្អ និងដើម្បីលើកកម្ពស់លទ្ធផលសិក្សាសិស្ស។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*ឧបសម្ព័ន្ធទី១៧៖ សេចក្តីណែនាំលេខ០៩ អយក.សណន ស្តីពីការបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ*

ខ. របៀបនៃការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍

ភាពជាដៃគូរវាងសាលារៀននិងសហគមន៍ សំដៅដល់ទំនាក់ទំនងបែបសហការរវាង គ្រឹះស្ថានអប់រំ ដូចជាសាលារៀន ជាមួយនឹងរោងចក្រ សហគ្រាស និងស្ថាប័នជំនួញផ្សេងៗ រហូតដល់អាជ្ញាធរមូលដ្ឋាន (ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ) ដែលមានទីតាំងនៅក្នុងឬក្រៅសហគមន៍នោះ។ គោលបំណងនៃភាពជាដៃគូនេះ គឺដើម្បីកសាងឱកាសជាផលប្រយោជន៍សម្រាប់ភាគីទាំងសងខាង ក៏ដូចជាដើម្បីពង្រឹងបទពិសោធផ្នែកអប់រំ និងអនាគតការងារសម្រាប់សិស្សានុសិស្សផងដែរ។

នៅក្នុងទំនាក់ទំនងភាពជាដៃគូរវាងសាលារៀននិងសហគមន៍មួយ សាលារៀនអាចបង្កឱកាសឱ្យគ្រឹះស្ថានជំនួញផ្សព្វផ្សាយអំពីសេវាកម្ម ឬសង្វាក់ផលិតកម្មរបស់ខ្លួនដល់សិស្សដោយប្រយោល ក៏ដូចជា ឱកាសក្នុងការសហការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងអង្គភាពរបស់ខ្លួន។ ជាផលត្រឡប់មកវិញ គ្រឹះស្ថានជំនួញអាចផ្តល់ឱ្យសិស្សនូវបទពិសោធការងារជាក់ស្តែង តាមរយៈការសង្កេតការងារ ការបង្កើតកម្មវិធីរួមគ្នាណាមួយ ឬការសហការគ្នាលើគម្រោងស្នាដៃរបស់ក្រុមសិស្សជាដើម។ ការណ៍នេះអាចជួយសិស្សឱ្យទទួលបាននូវជំនាញជាក់ស្តែង ចំណេះដឹងអំពីសហគ្រាស និងបទពិសោធការងារដ៏មានតម្លៃ ដែលអាចជួយរៀបចំអនាគតអាជីពការងាររបស់សិស្សបានល្អប្រសើរ។

ជាទូទៅ ភាពជាដៃគូរវាងសហគ្រាស និងសហគមន៍មូលដ្ឋាន ដើរតួនាទីជាស្ពានដ៏សំខាន់ក្នុងការបំពេញគម្លាតរវាងការអប់រំ និងកម្លាំងពលកម្ម ដើម្បីពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងការរៀបចំសិស្សានុសិស្សឱ្យទទួលបានជោគជ័យក្នុងវិស័យអាជីពការងារដែលពួកគេបានជ្រើសរើស។

នៅក្នុងក្របខណ្ឌគម្រោង STEP UP ក្រសួងអប់រំ យុវជន និងកីឡា ដាក់បញ្ចូលការអនុវត្តសកម្មភាពភាពជាដៃគូរវាងសាលារៀន និងសហគមន៍មូលដ្ឋានចំនួន៦ សកម្មភាព ដែលជាខ្សែនភាព

បន្តពីគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ សម្រាប់សាលារៀនទាំងអស់ក្នុងគោលដៅរបស់គម្រោងអនុវត្តដែលសកម្មភាពទាំងនោះរួមមាន៖

គ. កម្មវិធីជំនួបជាមួយសហគមន៍ក្នុងមូលដ្ឋាន

វត្ថុបំណង៖ ជំរុញ និងលើកកម្ពស់ការកសាងទំនាក់ទំនងរវាងក្រុមហ៊ុនសហគ្រាស អាជីវកម្ម គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល សហគ្រិនស្ត្រី សមាគម អង្គការសង្គមស៊ីវិលមូលដ្ឋាន មជ្ឈមណ្ឌលការងារនិងសាលារៀនឱ្យក្លាយទៅជាទម្លាប់ ដើម្បីជំរុញប្រសិទ្ធភាពនៃដំណើរការរៀននិងបង្រៀនព្រមទាំងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

គោលការណ៍ណែនាំ

ជាទូទៅ សាលារៀន ដើរតួនាទីសំខាន់ក្នុងការផ្តល់ការអប់រំដល់សិស្សឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីពួកគេអាចក្លាយខ្លួនជាពលរដ្ឋពេញលេញរបស់សង្គមជាតិ។ ក្នុងនាមជាអ្នកផ្តល់សេវាអប់រំ និងជាអ្នកសម្របសម្រួលដំណើរការសិក្សារបស់សិស្ស សាលារៀន ដោយមានគ្រូប្រឹក្សាតាម សាលារៀនជាសេនាធិការ ត្រូវផ្តួចផ្តើមឱ្យមានកម្មវិធីជំនួបរវាងសាលារៀន និងភាគីពាក់ព័ន្ធដែលមានដូចជា ក្រុមហ៊ុនសហគ្រាស អាជីវកម្ម សហគ្រិនស្ត្រី គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល សមាគម អង្គការសង្គមស៊ីវិលមូលដ្ឋាន និងមជ្ឈមណ្ឌលការងារ ដើម្បីជំរុញឱ្យដំណើរការរៀន និងបង្រៀន សមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រីក្នុងវិស័យអប់រំ និងលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ ព្រមទាំងផ្តល់ឱកាសឱ្យ សិស្សស្រីសិស្សប្រុសអាចផ្សារភ្ជាប់ការសិក្សានៅសាលារៀនទៅនឹងពិភពការងារជាក់ស្តែងតាមរូបភាពផ្សេងៗ នៃកិច្ចសហការដែលនឹងត្រូវបង្កើតឡើង។

សាលារៀន ត្រូវរៀបចំឱ្យមានកម្មវិធីជំនួបជាមួយភាគីពាក់ព័ន្ធនេះ នៅក្នុងសាលារៀនជាប្រចាំដោយអាចធ្វើឡើងយ៉ាងហោចណាស់ ០២ដង ក្នុងមួយឆ្នាំសិក្សា (ដើមឆ្នាំសិក្សា និងពាក់កណ្តាលឆ្នាំសិក្សា) ឬ១ដង /ត្រីមាសដើម្បីពិនិត្យលទ្ធភាពរួមគ្នាក្នុងការបង្កើតកិច្ចសហការរៀបចំកម្មវិធីការងារសំខាន់ៗដូចដែលនឹងមានបង្ហាញក្នុងចំណុចបន្តបន្ទាប់ខាងក្រោមនេះស្រាប់។ ដើម្បីជំរុញកិច្ចការនេះឱ្យមានប្រសិទ្ធភាព គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន ត្រូវចាត់ចែងរៀបចំកំណត់កាលបរិច្ឆេទ និងលិខិតអញ្ជើញ ចូលរួមប្រជុំ ទៅកាន់គ្រប់ភាគីពាក់ព័ន្ធ ដោយមានគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាអ្នកដឹកនាំកិច្ចប្រជុំ (បើអាចទៅរួច)។ តាមរយៈកិច្ចប្រជុំនេះ សំឡេងនៃការចូលរួមរបស់ភាគីពាក់ព័ន្ធខាងលើ និងក្លាយជាធាតុចូលដ៏សំខាន់ក្នុងការជំរុញការអភិវឌ្ឍសាលារៀន និងការរៀន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

សូត្ររបស់សិស្ស ហើយក៏ជាផ្នែកមួយនៃការបង្កើនប្រសិទ្ធភាពនៃការងារបណ្តាញរបស់គ្រូប្រឹក្សាតាមសាលារៀនផងដែរ។

ឃ. វេទិកាចែករំលែកបទពិសោធដោយវាគ្មិន

វត្ថុបំណង៖ ផ្តល់ឱ្យសិស្សនូវឱកាសក្នុងការជួបប្រាស្រ័យ និងសន្ទនាដោយផ្ទាល់ជាមួយអ្នកដែលមានបទពិសោធក្នុងការសិក្សា ការបំពេញការងារ ការដឹកនាំអាជីវកម្ម ដើម្បីពួកគេបានជាទុនក្នុងការត្រៀមខ្លួន បង្កើតឱកាស និងជម្រើសផ្ទាល់ខ្លួននាពេលអនាគតបានសមរម្យ។

គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំវេទិកាចែករំលែកបទពិសោធ ដោយអញ្ជើញ វាគ្មិនជាតំណាងមកពីមជ្ឈមណ្ឌលការងារ ឬក្រុមហ៊ុនសហគ្រាស ឬសហគ្រិនស្ត្រីជោគជ័យ ឬអតីតសិស្ស ឆ្នើមប្រចាំសាលាជាដើម (ស្នើឱ្យផ្តោតលើវត្តមានស្ត្រីចូលរួម) មកធ្វើបទបង្ហាញជូនដល់ក្រុមសិស្សគោលដៅ (គួរតែថ្នាក់ទី១១ ឬថ្នាក់ទី១២) ដោយប្រើរយៈពេល ០១ ព្រឹក ឬ០១ រសៀល។ ប្រធានបទនៃការចែករំលែកនេះ គួរត្រូវបានផ្តោតជាសំខាន់លើ ព័ត៌មានអប់រំ ព័ត៌មានទីផ្សារការងារ និងព័ត៌មានអំពីអាជីពការងារ ភាពជោគជ័យរបស់ស្ត្រីលើវិស័យការងារផ្សេងៗ ជូនដល់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលវាឆ្លើយតបនឹងស្លោកដែលជាគោលដៅចុងក្រោយនៃការអប់រំនោះគឺ រៀនដើម្បីធ្វើការ ធ្វើការដើម្បីរកប្រាក់ រកប្រាក់ដើម្បីរស់ រស់ដើម្បីបម្រើ។ ការចែករំលែកព័ត៌មានក្នុងវេទិកានេះ នឹងផ្តល់ឱកាសឱ្យសិស្សទូទៅ ពិសេសសិស្សស្រី មើលឃើញនូវរូបភាពការងារ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការងារ លក្ខខណ្ឌគាំទ្រដល់វិស័យការងារ សក្តានុពលផ្ទាល់ខ្លួនចំពោះការងារ គុណតម្លៃ និងលទ្ធភាពរបស់ស្ត្រីក្នុងការបំពេញការងារបានស្មើមុខនឹងបុរសដែរ។

គ្រូប្រឹក្សាតាមសាលារៀន ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការរៀបចំ និងអញ្ជើញវាគ្មិនជំនាញ ឱ្យជួយធ្វើបទបង្ហាញដើម្បីចែករំលែកបទពិសោធ លើកទឹកចិត្ត និងគាំទ្រផ្នែកស្មារតីដល់សិស្ស។ កម្មវិធីនេះ ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់វាគ្មិនជាស្ត្រី។

ង. វេទិកាជជែកពិភាក្សា (វាគ្មិនច្រើន)

វត្ថុបំណង៖ ផ្តល់ឱ្យសិស្សនូវឱកាសក្នុងការជួបប្រាស្រ័យ និងសន្ទនាដោយផ្ទាល់ជាមួយអ្នក

ដែលមានបទពិសោធក្នុងការសិក្សា ការបំពេញការងារ ការដឹកនាំអាជីវកម្ម មកពីប្រភពផ្សេងៗគ្នា ដើម្បីពង្រីកការយល់ដឹងរបស់សិស្សអំពីពិភពការងារការជ្រើសរើសផ្លូវសិក្សានិងអាជីពបានកាន់តែទូលំទូលាយ។

គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំវេទិកាជជែកពិភាក្សា ដោយអញ្ជើញវាគ្មិនមកពីស្ថាប័នផ្សេងគ្នាចំនួន៣ ឬ៤ នាក់ (លើកទឹកចិត្តឱ្យមានវាគ្មិនជាស្ត្រីចូលរួម) មកបកស្រាយលើប្រធានបទជាក់លាក់ណាមួយ មកចែករំលែកជូនដល់ក្រុមសិស្ស (គួរតែថ្នាក់ទី១១ ឬ ថ្នាក់ទី១២) ក្នុងរយៈពេល១ ព្រឹក ឬ១រសៀល។ ការរៀបចំវេទិកាក្នុងទម្រង់ជា Panel Discussion នេះ តម្រូវឱ្យមានអ្នកសម្របសម្រួលកម្មវិធីម្នាក់ (អាចជាគ្រូប្រឹក្សាតាមសាលារៀន)។ ប្រធានបទនៃការចែករំលែកនេះ គួរត្រូវបានផ្តោតជាសំខាន់លើព័ត៌មានអប់រំ ព័ត៌មានទីផ្សារការងារ និងព័ត៌មានអំពីអាជីពការងារ ភាពជោគជ័យរបស់ស្ត្រីលើ វិស័យការងារផ្សេងៗជូនដល់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ។ ការចែករំលែកព័ត៌មានក្នុងវេទិកានេះ នឹងផ្តល់ឱកាសបន្ថែមទៀតឱ្យសិស្សទូទៅ ពិសេសសិស្សស្រី មើលឃើញនូវរូបភាពការងារ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការងារ លក្ខខណ្ឌគាំទ្រដល់វិស័យការងារ សក្តានុពលផ្ទាល់ខ្លួនចំពោះការងារ គុណតម្លៃ និងលទ្ធភាពរបស់ស្ត្រីក្នុងការបំពេញការងារបានស្មើមុខនឹងបុរសដែរ។

ច. ទស្សនកិច្ចសិក្សា

វត្ថុបំណង៖ លើកទឹកចិត្តសិស្សឱ្យផ្សារភ្ជាប់ចំណាប់អារម្មណ៍ការងារ ទៅនឹងពិភពការងារជាក់ស្តែងតាមរយៈការចុះទស្សនកិច្ចសិក្សានៅតាមគ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល ក្រុមហ៊ុនសហគ្រាសអាជីវកម្ម ក្នុងមូលដ្ឋាន ឬមជ្ឈមណ្ឌលការងារ។

គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងភាពជាដៃគូសហការ ដែលសំដៅដល់កិច្ចសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឯកជនដូចជា ធនាគារ ផ្សារទំនើប បណ្ណាគារ សហគ្រាសខ្នាតមធ្យម សហគ្រាសខ្នាតតូចជាដើម។ ការផ្តល់ឱកាសឱ្យសិស្សថ្នាក់ទី១២ បានចុះទស្សនកិច្ចសិក្សា នៅតាមធនាគារ ផ្សារទំនើប បណ្ណាគារ ក្រុមហ៊ុនសហគ្រាសក្នុងមូលដ្ឋាន អាចជួយសិស្សឱ្យមើលឃើញអំពីសង្វាក់ផលិតកម្មជាក់ស្តែងនៃការបំពេញការងារដែលជាចំណែកគាំទ្រយ៉ាងសំខាន់ដល់សិស្សក្នុងការទាញចំណាប់អារម្មណ៍សិស្សឱ្យសាកល្បងបន្សុំចំណង់ចំណូលចិត្ត ផែនការសិក្សាជំនាញនិងអាជីពនាថ្ងៃអនាគតទៅនឹងពិភពការងារដែលពួកគេ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បានឃើញ។ ការណ៍នេះនឹងជួយសិស្សឱ្យកាន់តែស្រឡាញ់ចូលចិត្តការសិក្សានិងមានឆន្ទៈពុះពាររៀនសូត្រ ដើម្បីចាប់យកជំនាញសមស្របតាមចំណង់ចំណូលចិត្តរបស់ខ្លួននាពេលអនាគត។ សាលារៀនត្រូវស្វែងរកដៃគូវិស័យឯកជន ដើម្បីឱ្យសិស្សបានចុះទស្សនកិច្ចសិក្សា និងរៀបចំចាត់ចែងឱ្យមានកិច្ចព្រមព្រៀងរយៈពេលខ្លី ឬមធ្យមរវាងសាលារៀន ជាមួយនឹងវិស័យឯកជននោះ។

គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងលោកគ្រូ អ្នកគ្រូទាំងអស់ ត្រូវសហការគ្នាកៀរគរវិស័យឯកជន ដែលជាគោលដៅបណ្តាញសម្រាប់សិស្សថ្នាក់ទី ១២ បានចុះទស្សនកិច្ចសិក្សា (រយៈ ពេល១ ព្រឹក ឬ១ រសៀល ឬ១ ថ្ងៃ)។ គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀនត្រូវចរចារ និងរៀបចំឱ្យមានជាកិច្ចព្រមព្រៀងរវាងសាលារៀន និងវិស័យឯកជននានា ដោយមានចែងអំពីចំនួនសិស្សត្រូវចូលរួមម្តងៗតាមភាពជាក់ស្តែង។ យន្តការជ្រើសរើសសិស្សចុះទស្សនកិច្ចសិក្សាត្រូវរៀបចំឡើងដោយគណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀននិងតំណាងវិស័យឯកជន។ សាលាត្រូវរៀបចំក្រុមសិស្សចុះទស្សនកិច្ចសិក្សាផ្អែកលើគោលការណ៍សមភាពយេនឌ័រដោយផ្តល់ឱកាសនិងបង្កលទ្ធភាពដល់សិស្សស្រី ដើម្បីឱ្យពួកគេអាចចូលរួមការចុះទស្សនកិច្ចសិក្សាដូចសិស្សប្រុសដែរ។

***ឧបសម្ព័ន្ធទី១៨៖*** *ឯកសារណែនាំប្រតិបត្តិស្តីពី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាសម្រាប់គណៈគ្រប់គ្រងសាលារៀននិងគ្រូប្រឹក្សាតាមសាលារៀន*

ឆ. ការចុះសង្កេតការងារ

វត្ថុបំណង៖លើកទឹកចិត្តសិស្សឱ្យផ្សារភ្ជាប់ចំណាប់អារម្មណ៍ការងារទៅនឹងពិភពការងារជាក់ស្តែងតាមរយៈការសង្កេតការងាររយៈពេលខ្លីនៅតាមគ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាលក្រុមហ៊ុនសហគ្រាសអាជីវកម្មក្នុងមូលដ្ឋាន ឬមជ្ឈមណ្ឌលការងារ។

គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀនក្នុងភាពជាដៃគូសហការ សំដៅដល់កិច្ចសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឯកជន

ដូចជា ធនាគារ ផ្សារទំនើប បណ្ណាគារ សហគ្រាសខ្នាតមធ្យម សហគ្រាសខ្នាតតូច ឬមជ្ឈមណ្ឌលការងារជាដើម។ ការផ្ដល់ឱកាសឱ្យសិស្សថ្នាក់ទី១១ បានហាត់ការរយៈពេលខ្លី (៣ថ្ងៃ ទៅ៥ថ្ងៃ) នៅតាមធនាគារ ផ្សារទំនើប បណ្ណាគារ ឬក្រុមហ៊ុនសហគ្រាសក្នុងមូលដ្ឋាននេះ អាចជួយសិស្សឱ្យមើលឃើញអំពីចំណង់ចំណូលចិត្ត ជំនាញ ភាពខ្លាំង និងចំណុចត្រូវពង្រឹងខ្លួនឯង ចំពោះប្រភេទការងារដែលខ្លួនចូលចិត្ត។ ការណ៍នេះនឹងជួយសិស្សឱ្យកាន់តែស្រឡាញ់ចូលចិត្តការសិក្សានិងមានឆន្ទៈពុះពាររៀនសូត្រ ដើម្បីចាប់យកជំនាញសមស្របតាមចំណង់ចំណូលចិត្តរបស់ខ្លួន នាពេលអនាគត។ សាលារៀនត្រូវស្វែងរកដៃគូសហការ ដើម្បីឱ្យសិស្សបានចុះហ្វឹកហាត់ការងារ និងចាត់ចែងឱ្យមានកិច្ចព្រមព្រៀងរយៈពេលមធ្យមរវាងសាលារៀន និងស្ថាប័ននោះ។

គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងលោកគ្រូ អ្នកគ្រូទាំងអស់ ត្រូវសហការគ្នាកៀរគរវិស័យឯកជន ដែលជាគោលដៅបណ្ដាញសម្រាប់សិស្សថ្នាក់ទី១១ បានចុះហ្វឹកហាត់ការងាររយៈពេលខ្លី (៣ថ្ងៃ ទៅ ៥ថ្ងៃ)។ គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន ត្រូវចរចារ និងរៀបចំឱ្យមានជាកិច្ចព្រមព្រៀងរវាងសាលារៀន និងដៃគូសហការនានា ដោយមានចែងអំពីចំនួនសិស្ស (មិនលើសពី៥នាក់) លក្ខខណ្ឌជ្រើសរើសសិស្ស និងរយៈពេលនៃការហ្វឹកហាត់ការងាររបស់សិស្ស ទៅតាមស្ថានភាពជាក់ស្ដែង។ យន្តការជ្រើសរើសសិស្សហ្វឹកហាត់ការងារ ត្រូវរៀបចំឡើងដោយគណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងតំណាងស្ថាប័នដែលទទួលជាក់ស្ដែង។ សាលារៀន ត្រូវរៀបចំក្រុមសិស្សចុះហាត់ការ ផ្អែកលើគោលការណ៍សមភាពយេនឌ័រ ដោយផ្ដល់ឱកាស និងបង្កលទ្ធភាពដល់សិស្សស្រីដើម្បីឱ្យពួកគេអាចចូលរួមការហ្វឹកហាត់ការងារបានដូចសិស្សប្រុសដែរ។ សិស្សហ្វឹកហាត់ការងារ អាចនឹងមានថវិកាឧបត្ថម្ភមួយចំនួនសម្រាប់ហូបចុក ទៅតាមលទ្ធភាពនៃការចរចារដូចដែលមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀង។

*ឧបសម្ព័ន្ធទី១៩៖ ឯកសារណែនាំប្រតិបត្តិស្ដីពី មគ្គុទ្ទេសក៍អាជីព និងការផ្ដល់ប្រឹក្សាសម្រាប់គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន*



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជ. ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូច

វត្ថុបំណង៖ ជំរុញ និងលើកទឹកចិត្តសិស្សឱ្យចូលរួមទទួលយកបទពិសោធ យល់ដឹងពីព័ត៌មានទីផ្សារការងារក្នុងមូលដ្ឋាន និងត្រៀមលក្ខណៈសម្បត្តិផ្ទាល់ខ្លួនបានល្អដើម្បីឈោងចាប់ឱកាសការងារ។

គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ត្រូវពិនិត្យលទ្ធភាពពេលវេលានៅចុងឆ្នាំសិក្សា ដោយធ្វើការសហការជាមួយបណ្ដាក្រុមហ៊ុនសហគ្រាស អាជីវកម្ម សហគ្រិនស្ត្រី បណ្ណាគារ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សិប្បកម្មក្នុងមូលដ្ឋាន និងមជ្ឈមណ្ឌលការងារ ដើម្បីរៀបចំបង្កើតព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូចមួយនៅសាលារៀន។ ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានចូលរួម នឹងតម្រូវឱ្យដាក់តាំងបង្ហាញនូវផលិតផលស្នាដៃ អាជីវកម្ម បញ្ជីតម្រូវការជំនាញ និងកម្លាំងពលកម្ម ដោយបរិយាយអំពីលក្ខខណ្ឌចូលបម្រើការ តួនាទីភារកិច្ចក្នុងមុខតំណែងនីមួយៗ... ព្រមជាមួយការរៀបចំឱ្យមានអ្នកចាំធ្វើបទបង្ហាញខ្លីជូនអ្នកទស្សនាស្ដង់ (លើកទឹកចិត្តដល់ស្ត្រីជាអ្នកចាំធ្វើបទបង្ហាញ) ក្នុងរយៈពេល១ ថ្ងៃពេញ។ ការរៀបចំនេះ ទាមទារនូវកិច្ចសហការស្អិតរមួតជាមួយមជ្ឈមណ្ឌលការងាររាជធានី ខេត្ត ដែលជាភ្នាក់ងារសាធារណៈផ្ដល់សេវាការងារ និងព័ត៌មានទីផ្សារការងារ។ ជាមួយគ្នានេះ សាលារៀនត្រូវ សម្របសម្រួលរៀបចំទីតាំង និងបញ្ជូរសមរម្យតាមលទ្ធភាពដែលអាចធ្វើបាន ព្រមទាំងចាត់ចែងសិស្សចូលរួមទស្សនា ដោយផ្ដោតជាសំខាន់លើក្រុមសិស្សមធ្យមសិក្សាទុតិយភូមិ។ កម្មវិធីនេះ នឹងជួយផ្ដល់មូលដ្ឋានបន្ថែមដល់សិស្សក្នុងការធ្វើស្វ័យសម្រេចចិត្តជ្រើសរើស និងកំណត់គោលដៅ ការអប់រំបន្ត និងអាជីពរបស់ខ្លួនបានកាន់តែប្រសើរថែមទៀត។

ដើម្បីជាការលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមដាក់បញ្ជូរតាំងពិព័រណ៍នេះ សាលារៀនគួររៀបចំលិខិតថ្លែងអំណរគុណដោយមានចុះហត្ថលេខានិងប្រថាប់ត្រារបស់អង្គភាពត្រឹមត្រូវ ផ្ដល់ជូននៅចុងបញ្ចប់កម្មវិធី។

## ៧.១៥ ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភរបស់សិស្ស

ចំណុចការអនុវត្តការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់សិស្ស គឺឆ្លើយតបទៅនឹងការអនុវត្តស្តង់ដាទី៤.ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន នៃស្តង់ដាសាលាមធ្យមសិក្សាគំរូ។

ការលើកកម្ពស់សុខភាពសិក្សាជាការងារអាទិភាពមួយដែលចូលរួមសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ស្ដីពីការអប់រំនៅកម្ពុជា "គុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកទេសឌីជីថលក្នុងការបង្កើនសេដ្ឋកិច្ច និងសុខុដុមជីវិតបុគ្គល និងសង្គម"។

ការអនុវត្តកម្មវិធីសុខភាពសិក្សានៅកម្ពុជាមានការវិវត្តជាជំហានៗស្របទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព បង្កើនផលិតភាពការងារខ្ពស់ សុខភាពរឹងមាំ និងកំណើនសេដ្ឋកិច្ចឆ្ពោះទៅសម្រេចចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការលើកកម្ពស់សុខភាពសិក្សា ដោយបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីសុខភាពសិក្សា សំណុំយុទ្ធសាស្ត្រ និងសកម្មភាពអន្តរកម្មរវាងគ្រឹះស្ថានសិក្សា និងសេវាកម្មសុខភាពនានា តាមរយៈការផ្តល់សេវាអប់រំសុខភាព ការបង្ការជំងឺ ការបង្កើតបន្ទប់សុខភាព សេវាពិនិត្យសុខភាពនិងកាយសម្បទា សេវាសង្គ្រោះបឋម សេវាអាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព សេវាលើកកម្ពស់អនាម័យ បរិស្ថាន និងការផ្គត់ផ្គង់ទឹកស្អាតជាដើម។

## ការអនុវត្តគោលការលើកកម្ពស់សុខភាពសិក្សា

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅនិងគ្រូបង្រៀនគ្រប់កម្រិតថ្នាក់ ចូលរួមរៀបចំអនុវត្ត "ការលើកកម្ពស់សុខភាពសិក្សា" ស្របតាមបរិបទថ្មីនៃការវិវត្តផ្នែកសុខភាពសាធារណៈសំដៅធានាដល់សុខភាព សុវត្ថិភាព និងផាសុកភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន។

គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅនេះបានរំលេចនូវសូចនាករស្តង់ដា ដែលត្រូវអនុវត្តដោយអនុលោមតាមយុទ្ធសាស្ត្រនីមួយៗនៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ផ្សារភ្ជាប់ជាមួយគោលការណ៍ប្រតិបត្តិស្តង់ដា ដែលបានពីបទពិសោធជាក់ស្តែងនៃការអនុវត្តសកម្មភាពនានានៅតាមគ្រឹះស្ថានសិក្សានាពេលកន្លងមក។ បន្ថែមលើសពីនេះ មានឧបសម្ព័ន្ធមួយចំនួនសម្រាប់ផ្ទៀងផ្ទាត់ ត្រួតពិនិត្យការអនុវត្តជាក់ស្តែងប្រចាំថ្ងៃ ដើម្បីធានាថា គ្រឹះស្ថានសិក្សាអាចដំណើរការប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូបដោយមិនប្រកាន់ភេទ អាយុ ពិការភាព ឋានៈគ្រួសារ ព្រមទាំងអ្នកងាយរងគ្រោះនោះទេ។

## ក្រុមគោលដៅប្រើប្រាស់

គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅនេះនឹងក្លាយជាឧបករណ៍ជំនួយស្មារតីថ្មីមួយសម្រាប់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូនៅតាមគ្រឹះស្ថានសិក្សា ដែលមានបំណងចង់រៀបចំគ្រឹះស្ថានសិក្សារបស់ខ្លួនស្របតាមបរិបទថ្មីនៃការវិវត្តផ្នែកសុខភាពសាធារណៈសំដៅធានាដល់សុខភាព សុវត្ថិភាពនិងផាសុកភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សាអាចរៀបចំការងារ "លើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា" ជាជំហានៗតាមសមត្ថភាព ធនធានដែលមាន និងអាចរកបានដោយមានភាពទន់ភ្លន់បត់បែនតាមស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថានសិក្សានីមួយៗ។ ផ្តើមចេញពីការវាយតម្លៃលើស្ថានភាពគ្រឹះស្ថានសិក្សា ដោយ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ធ្វើការផ្ទៀងផ្ទាត់នូវសូចនាករដែលមាន ឬអាចបំពេញបាន។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូអ្នកគ្រូនិងអ្នកពាក់ព័ន្ធផ្សេងទៀតអាចពិភាក្សាគ្នារិះរកមធ្យោបាយដើម្បីរៀបចំផែនការមេក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សារបស់ខ្លួន ចាប់ផ្តើមពីកែលម្អស្ថានភាពសូចនាករដែលមិនទាន់មាន ពិសេសផ្តើមចេញពីចំណុចតូចៗដែលអាចធ្វើបានជាមុន។ ធ្វើបែបនេះ វាជាជំហានលើកទឹកចិត្តខ្លួនឯងក្នុងការបន្តជំហានទៅមុខទៀត តាមផែនការគ្រោងទុករហូតដល់អាចបំពេញបាននូវសូចនាករស្តង់ដាសំខាន់ៗដែលជាផ្នែកមិនអាចខ្វះបាន ដើម្បីប្រែក្លាយទៅជា "គ្រឹះស្ថានសិក្សាអនុវត្តការលើកកម្ពស់សុខភាពស្តង់ដា"។

*ឧបសម្ព័ន្ធទី២០៖ គោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាបំណេះដឹងទូទៅ*

### ៧.១៦ ការគ្រប់គ្រងទិន្នន័យអប់រំសាលារៀន

ចំណុចការអនុវត្តការគ្រប់គ្រងទិន្នន័យអប់រំសាលារៀន គឺឆ្លើយតបទៅ នឹងការអនុវត្តស្តង់ដាទី ៤. ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន នៃស្តង់ដាសាលាមធ្យមសិក្សាគំរូ។

ក. ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាម Google Sheet

Google Sheets អាចជួយក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានសាលាតាមវិធីជាច្រើន៖ Google Sheets ផ្តល់នូវវិធីដែលមានរចនាសម្ព័ន្ធ និងរៀបចំដើម្បីរក្សាទុក និងគ្រប់គ្រងទិន្នន័យដែលទាក់ទងនឹងសិស្ស គ្រូ ថ្នាក់ ថ្នាក់ វត្តមាន និងព័ត៌មានសាលាពាក់ព័ន្ធផ្សេងទៀត។ អ្នកប្រើប្រាស់ជាច្រើនអាចចូលប្រើប្រាស់ និងកែសម្រួល Google Sheet តែមួយក្នុងពេលដំណាលគ្នា ដែលអនុញ្ញាតឱ្យមានការសហការគ្នាយ៉ាងងាយស្រួលក្នុងចំណោម គ្រូបង្រៀន អ្នកគ្រប់គ្រង និងសមាជិកបុគ្គលិកផ្សេងទៀត។ នេះលើកកម្ពស់ការងារជាក្រុម បើកការអាប់ដេតតាមពេលវេលាជាក់ស្តែង និងលុបបំបាត់តម្រូវការសម្រាប់ការគ្រប់គ្រងកំណែ។ វាផ្តល់នូវមុខងារ និងរូបមន្តដែលភ្ជាប់មកជាមួយជាច្រើន ក៏ដូចជាសមត្ថភាពក្នុងការបង្កើតគំនូសតាង និងក្រាហ្វ។ នេះអនុញ្ញាតឱ្យមានការវិភាគទិន្នន័យប្រកបដោយប្រសិទ្ធភាព រួមទាំងការបង្កើតរបាយការណ៍ តាមដានវឌ្ឍនភាពរបស់សិស្ស ការកំណត់អត្តសញ្ញាណនិន្នាការ និងធ្វើការសម្រេចចិត្តដែលផ្អែកលើទិន្នន័យ។

ជាមួយនឹងការប្រើប្រាស់រូបមន្ត ស្គ្រីប និងកម្មវិធីបន្ថែម Google អាចធ្វើកិច្ចការដដែលៗដោយស្វ័យប្រវត្តិ សន្សំពេលវេលាសម្រាប់គ្រូបង្រៀន និងអ្នកគ្រប់គ្រង។ ឧទាហរណ៍ សន្លឹកចូលរួមដោយ

ស្វ័យប្រវត្តិអាចត្រូវបានភ្ជាប់ទៅមូលដ្ឋានទិន្នន័យរបស់សិស្ស ឬទម្រង់អនឡាញ ដោយកាត់បន្ថយការបញ្ចូលទិន្នន័យដោយដៃ។

ខ. ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងសាលារៀន (SIS)

ប្រព័ន្ធ SIS គឺជាប្រព័ន្ធដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងព័ត៌មានអប់រំ និងជំរុញការអប់រំផ្នែកបច្ចេកវិទ្យា។ ប្រព័ន្ធនេះ មានមុខងារសំខាន់ៗដូចជា៖

- ផ្ទាំងទិន្នន័យរួម (Dashboard) សម្រាប់ក្រសួងអយក. មន្ទីរអយក. និងសាលារៀន
- មុខងារគ្រប់គ្រងព័ត៌មានសិស្ស
- មុខងារគ្រប់គ្រងគ្រូបង្រៀន
- មុខងារគ្រប់គ្រងពិន្ទុតាមរយៈទូរស័ព្ទដៃ សម្រាប់គ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់
- មុខងារគ្រប់គ្រងទិន្នន័យសាលារៀន
- មុខងារការគ្រប់គ្រងតាមអនឡាញ
- មុខងារគ្រប់គ្រងធាត

ប្រព័ន្ធនេះ មាន APP សម្រាប់គ្រូបន្ទុកថ្នាក់ គ្រូមុខវិជ្ជា សិស្ស និងអាណាព្យាបាល ក្នុងនោះមានមុខងារសំខាន់ៗដូចជា កំណត់កាលវិភាគសិក្សា សៀវភៅសិក្សាគោល ការបញ្ចូលពិន្ទុសិស្ស ចុះវត្តមានតាម QR Code និងការចុះឈ្មោះតាមអនឡាញ។ ដោយឡែក មុខងារចុះឈ្មោះតាមអនឡាញនេះ សិស្សានុសិស្សអាចចុះឈ្មោះដោយខ្លួនឯងផ្ទាល់ ឬអាព្យាបាលអាចចុះឈ្មោះឱ្យសិស្ស។ ការប្រើប្រាស់មុខងារនេះផ្តល់ភាពងាយស្រួលសម្រាប់សាលារៀនដោយមិនចាំបាច់ចំណាយពេលវេលាយូរ និងក្រដាស។ បន្ទាប់ពីការចុះឈ្មោះ សាលារៀននឹងទទួលបានទិន្នន័យភ្លាមៗ។

